ក N°95/15→27/12/201

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១១-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១១០ ស្តីពី ការបញ្ចប់តំណែងឯកឧត្តម **ជា ចំរើន** ពីទីប្រឹក្សាជាន់ខ្ពស់ នៃរដ្ឋសភា ក្នុងនីតិកាលទី ៥ ក្រោយពីឯកឧត្តមបានស្នើសុំលាឈប់ ១០០៥៩

១១-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១១១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ព្រហ្ម វិចិត្រសុភ័ណ្ឌ** ពីទីប្រឹក្សាផ្ទាល់ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១០០៦០

១៧-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៣៣ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្រ្តីរាជការ ៤៥ រូប របស់អង្គភាពប្រឆាំងអំពើពុករលួយ ១០០៦១

១៧-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៣៤ ស្តីពី ការតែងតាំងលោកជំទាវ **អេងលី ពិផល** ជា ឯកអគ្គរាជទូតអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១០០៦៤

១៧-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៣៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិដល់លោក **សួន សុភាព** នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ១០០៦៥

១៧-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៣៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រីដល់លោកវរសេនីយ៍ឯក **ម៉ៅ វណ្ណៈ** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១០០៦៦

១៧-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៣៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ហ័ង ជី ជៀន** (HUANG CHIH CHIEN) ជនជាតិចិន សញ្ជាតិចិន ១០០៦៧

១៧-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៣៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ី មីនជីន** (SHIH MIN-JEN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ១០០៦៨

១៩-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៣៩ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **ហ៊ុន ម៉ានី** នូវគ្រឿងឥស្សរិយយស ជាតូបការ ១០០៦៩

២៤-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៤០ ស្តីពី ការផ្ទេរភារកិច្ចឯកឧត្តម **គុល សំអុល** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ ពីអភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង ឱ្យមកបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ១០០៧០

២៤-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៤១ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ១០០៧១

២៤-១២-២០១៥ -ព្រះរាជក្រឹត្យ នស/រកត/១២១៥/១១៤២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ដល់សព នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ២០ រូប ១០០៧៦

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៣-១២-២០១៥-អនុក្រឹត្យលេខ ១៨១ អនក្រ.បក ស្តីពី ការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ១០០៧៨

២៤-១២-២០១៥ -អនុក្រឹត្យលេខ ១៨៥ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៥៩៧,៣១ ហិកតា នៅស្រុកសំបូរ ខេត្តក្រចេះ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិសមូហភាព ជូនសហគមន៍ជនជាតិដើមភាគតិចព្នង ០១ សហគមន៍ និងការផ្តល់សិទ្ធិលើក្បាលដី ១០១២៩

២៣-១២-២០១៥-អនុក្រឹត្យលេខ ១២៤៤ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១០១៣៣

២៣-១២-២០១៥-អនុក្រឹត្យលេខ ១២៤៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១០១៣៧

២៣-១២-២០១៥-អនុក្រឹត្យលេខ ១២៤៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០១៣៩

២៣-១២-២០១៥-អនុក្រឹត្យលេខ ១២៤៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១០១៤០

២៣-១២-២០១៥-អនុក្រឹត្យលេខ ១២៤៨ អនក្រ.តត ស្តីពី ការតែងតាំងនាយកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ១០១៤៣

២៣-១២-២០១៥-អនុក្រឹត្យលេខ ១២៤៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០១៤៥

២៣-១២-២០១៥-អនុក្រឹត្យលេខ ១២៥០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១០១៤៦

២៤-១២-២០១៥ -អនុក្រឹត្យលេខ ១២៥១ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ១០១៤៨

២៤-១២-២០១៥ -អនុក្រឹត្យលេខ ១២៥២ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ១០១៤៩

២៤-១២-២០១៥ -អនុក្រឹត្យលេខ ១២៥៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០១៥០

២៤-១២-២០១៥ -អនុក្រឹត្យលេខ ១២៥៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១០១៥២

III. ការិយាល័យក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៥-១២-២០១៥ -ប្រកាសរួមលេខ ១៧៣០ សហវ.ប្រក ស្តីពី ការគ្រប់គ្រងចំណូលពីតំបន់រមណីយដ្ឋានទេសចរណ៍ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ១០១៥៤

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២៥-៩-២០១៥ -ប្រកាសលេខ ៥៩០ ឧស.កឧ.ប្រក.០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន គ្លូប៊ល អឺភែរីល ចិចថាយ (ខេមបូឌា) មេនូហ្វេកឆឺរីង ភីធីអ៊ី អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១០១៥៩

២៥-៩-២០១៥ -ប្រកាសលេខ ៥៩១ ឧស.កឧ.ប្រក.០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) បង្កើតរោងចក្រ ផលិតតុក្កតា និងសម្ភារៈប្រើក្នុងពិធីជប់លៀង ១០១៦២

២៥-៩-២០១៥ -ប្រកាសលេខ ៥៩៤ ឧស.កឧ.ប្រក.០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ខេភីថល អាយលែន (ខេមបូឌា) បង្កើតរោងចក្រ ជ្រលក់ពណ៌ និងខាត់អំបោះដេរ ១០១៦៥

២៥-៩-២០១៥ -ប្រកាសលេខ ៥៩៥ ឧស.កឧ.ប្រក.០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យី ដា មេនូហ្វេកឆឺរី ខូ អិលធីឌី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ បោកគក់ ប៉ាក់ និងបោះពុម្ព ១០១៦៨

២៩-៩-២០១៥ -ប្រកាសលេខ ៥៩៧ ឧស.កឧ.ប្រក.០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ថុង ខាង (ខេមបូឌា) បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ១០១៧១

២៩-៩-២០១៥ -ប្រកាសលេខ ៥៩៨ ឧស.កឧ.ប្រក.០៩ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេសអ៊ីភីអាយអេ (ខេមបូឌា) ហ្គាមេន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ១០១៧៤

៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២១-០១-២០១៥ -លិខិតលេខ ០៦៦៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **កែវ ពន្លឺ ខូ អិលធីឌី** ១០១៧៧

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/ ១១១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជ រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១១១០ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងឯកឧត្តម លោកជំទាវ ជាទីប្រឹក្សាជាន់ខ្ពស់ នៃរដ្ឋសភា ក្នុងនីតិកាលទី៥
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី** **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

ត្រាស់បង្គាប់

មាត្រា១ : បញ្ចប់តំណែងឯកឧត្តម **ជា ចំរើន** ពីទីប្រឹក្សាជាន់ខ្ពស់ នៃរដ្ឋសភា ក្នុងនីតិកាលទី៥ ក្រោយពីឯកឧត្តម បានស្នើសុំលាឈប់ ។

មាត្រា២ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១៥១៧.១១២៥

លេខៈ១១៧២ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៧២៥ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ៣ឆ្នាំ លើកទី៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បញ្ចប់មុខតំណែងឯកឧត្តម **ព្រហ្ម វិចិត្រសុភ័ណ្ឌ** ពីទីប្រឹក្សាផ្ទាល់ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

មាត្រា២ : តែងតាំងលោកជំទាវ **ឈឹម សុភាព** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម **ព្រហ្ម ញាណវិចិត្រ** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

មាត្រា៣ : ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស. ១៥១៧. ១១៧៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥

លេខ: ១១៥៥ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការ ៤៥ រូប របស់អង្គភាពប្រឆាំងអំពើពុករលួយ ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ចាប់តាំងពីថ្ងៃទី **០៨ ខែ សីហា ឆ្នាំ ២០១៥** តទៅ ៖

១- លោក **ហេង សុខលី** អនុមន្ត្រី ថ្នាក់លេខ ៣

២- លោកស្រី **ឌួង សុជីវី**	អនុមន្ត្រី	ថ្នាក់លេខ ៣
៣- លោកស្រី **សេង លីណា**	អនុមន្ត្រី	ថ្នាក់លេខ ៣
៤- លោក **ហ៊ី ដានិត**	អនុមន្ត្រី	ថ្នាក់លេខ ៣
៥- លោក **ឌិត មឃៈ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦- លោក **ឈួយ រតនៈ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧- លោក **សាន សុទិបុល**	អនុមន្ត្រី	ថ្នាក់លេខ ៤
៨- លោក **លាង សុផល**	អនុមន្ត្រី	ថ្នាក់លេខ ៤
៩- លោកស្រី **ហ៊ុន ពុទ្ធាវី**	អនុមន្ត្រី	ថ្នាក់លេខ ៤
១០- លោកស្រី **មឿង រស្មី**	អនុមន្ត្រី	ថ្នាក់លេខ ៤
១១- លោក **ម៉ា សាន់សុវណ្ណា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១២- លោក **ញៀន សុខា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៣- លោក **ហេង ជីវ័ន្ត**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៤- លោក **ព្រឿង ចេង**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៥- លោក **ជា សុផានា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៦- លោកស្រី **សូត្រ លក្ខិណា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៧- លោកស្រី **លីម ម៉ូលីហ្សា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៨- លោក **ហ៊ុន ឡាលីន**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៩- លោក **ហែម សម្បត្តិ**	អនុមន្ត្រី	ថ្នាក់លេខ ៤
២០- លោក **នួន នរន្ទេ**	អនុមន្ត្រី	ថ្នាក់លេខ ៤
២១- លោក **ថាង ឧត្តម**	អនុមន្ត្រី	ថ្នាក់លេខ ៤
២២- លោកស្រី **ឯក ច័ន្ទនិមល**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៣- លោក **សុន សុភ័ក្រ**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៤- លោក **ឡា រស្មីវឌ្ឍ**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៥- លោក **អន ប៊ុនណា**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៦- លោក **ជឹម ពិសិដ្ឋ**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៧- លោកស្រី **អ៊ុំ មល្លិកា**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៨- លោក **ផន សំអុន**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៩- លោក **ខន និត្យសុភាព**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣០- លោក **ទូច ហ្សលីន**	អនុមន្ត្រី	ថ្នាក់លេខ ៣
៣១- លោក **ឈន រតនា**	អនុមន្ត្រី	ថ្នាក់លេខ ៤

៣២- លោក **ឈុន ហាយតិរុន**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៣- លោកស្រី **ថៃ បូរមី**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៤- លោកស្រី **ហុង សុខម៉េង**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៥- លោកស្រី **សរ ចាន់តារ៉ា**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៦- លោក **អ៊ុំ សាវ៉ច់**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៧- លោក **ហេង ណារ័ត្ន**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៨- លោក **អ៊ុំ ច័ន្ទដារ៉ា**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣៩- លោកស្រី **ញ៉ែម ស្រីនាង**	អនុមន្ត្រី	ថ្នាក់លេខ ៤
៤០- លោក **ភុយ និត្យតារា**	អនុមន្ត្រី	ថ្នាក់លេខ ៤
៤១- លោក **ម៉ឹង ឋានៈនីដែន**	អនុមន្ត្រី	ថ្នាក់លេខ ៤
៤២- លោកស្រី **យុង ម៉ី**	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៣- លោក **ឡុយ លៀង**	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៤- លោក **ឡុង វិជ្ជា**	អនុមន្ត្រី	ថ្នាក់លេខ ៤
៤៥- លោក **ឈៅ សុខា**	អនុមន្ត្រី	ថ្នាក់លេខ ៤

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧៣រស.១៥១២.១១៥០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥

លេខ:១១៥១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង:

លោកជំទាវ **អេងលី ពិផល**

ជា

ឯកអគ្គរាជទូតអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

នរោត្តម សីហមុនី

នរោត្តម សីហមុនី

៣៩លា.១៥១២.១១៥១

បានប្រូវចាប់ព្រះរាជលញ្ចករហើយ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ : ...០៣៧/១៥ រវ. ចច
រាជធានីភ្នំពេញ ថ្ងៃទី ...២៧... ខែ ...ធ្នូ.....ឆ្នាំ..២០១៥
សម្តេចចៅហ្វាវាំង វរាភិជ្ជជ័យ អធិបតីស្រីង្គារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/ ១១៧៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០២០០/១០៤ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិដល់លោក **សួន សុភាព** ពី វរមន្ត្រីថ្នាក់លេខ១ មក ឧត្តមមន្ត្រីថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣.ស. ១៥.១២. ១១៥២

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥

លេខ: ៦១៥៦ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់លោកវរសេនីយ៍ឯក **ម៉ៅ វណ្ណៈ** អត្តលេខ ៥៦២៧៥ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤លា.១៥៤៤.១១៥៣

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥

លេខៈ ១១៥៧/ស.ណ
សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ័ង ជី ជែន** (HUANG CHIH CHIEN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៦៦ នៅខេត្តហ្វូជៀន សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧រស.១៥១២.១១៥៤

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥

លេខៈ ១១៤១ ស.ណ
សំណៅដែលមានតម្លៃជាការចេញផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ី មីនជីន** (SHIH MIN-JEN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៥៦ នៅក្រុងតៃប៉ិ សាធារណរដ្ឋចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១៥១២.១១៥៥

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៥

លេខ:១១៤៧ ស.ណ
សំណៅចែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/ ១១៣៩

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន**
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្ដម **ហ៊ុន ម៉ានី**

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ**

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣ទស. ១៥១២. ១១៥៦

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥

លេខ:១១៤៣ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្ទេរភារកិច្ចឯកឧត្តម **កុល សំអុល** ឋានន្តរស័ក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ១ ពីអភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង ឱ្យមកបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ។

មាត្រា ២ : តែងតាំងឯកឧត្តម **ម៉ុម សារឿន** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ជាអភិបាល នៃគណៈអភិបាលខេត្តស្ទឹងត្រែង។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ព.រ.ស. ១៥១២.១១៥៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥

លេខៈ ១៤៥៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/១១៤១

ស្តីពី

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ត្រាស់បង្គាប់

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

ព្រះរាជក្រឹត្យនេះ កំណត់ពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដែលសរសេរជាអក្សរកាត់ថា **គ.ជ.គ.ម.** ជាសេនាធិការឱ្យរាជរដ្ឋាភិបាលដើម្បីដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការងារគ្រប់គ្រងគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិឬមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជំពូកទី២

សមាសភាពរបស់ គ.ជ.គ.ម.

មាត្រា២ .-

គ.ជ.គ.ម. មានសមាសភាពដូចខាងក្រោម៖

- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា	ប្រធាន
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	អនុប្រធាន
- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងការពារជាតិ	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
- ឥស្សរជនជាន់ខ្ពស់ ១រូប	អនុប្រធានប្រចាំការ
- ឥស្សរជនជាន់ខ្ពស់ ១រូប	អនុប្រធាន
- ឥស្សរជន ១រូប	អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
- រដ្ឋមន្ត្រីក្រសួងផែនការ	សមាជិក
- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម	សមាជិក
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
- រដ្ឋមន្ត្រីក្រសួងបរិស្ថាន	សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	សមាជិក
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល	សមាជិក
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម	សមាជិក
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍	សមាជិក
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល	សមាជិក
- រដ្ឋមន្ត្រីក្រសួងព័ត៌មាន	សមាជិក
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន	សមាជិក

- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី	សមាជិក
- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	សមាជិក
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	សមាជិក
- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	សមាជិក
- រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា	សមាជិក
- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ	សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	សមាជិក
- អនុប្រធានអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិង សង្គ្រោះជនពិការដោយសារមីន	សមាជិក
- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
- អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ	សមាជិក
- អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ	សមាជិក
- អគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ	សមាជិក

សមាសភាពជាក់ស្តែងរបស់ **គ.ជ.គ.ម.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

ជំពូកទី៣

តួនាទីនិងភារកិច្ចរបស់ គ.ជ.គ.ម.

មាត្រា៣ ..

គ.ជ.គ.ម. មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្ត កម្មវិធីនិងគម្រោងក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ
- ផ្តល់គោលការណ៍ណែនាំនិងការអនុវត្តសម្រាប់គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយលើកកម្ពស់ចំណេះដឹងការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំការឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញដើម្បីសុវត្ថិភាពនិងភាពធន់
- លើកយោបល់ជូនរាជរដ្ឋាភិបាល ដើម្បីមានវិធានការរាល់ករណីទាំងឡាយណាដែលនឹងបង្កឱ្យមានគ្រោះមហន្តរាយនិងធ្វើឱ្យមានគ្រោះមហន្តរាយកើតឡើង
- សម្របសម្រួលការអនុវត្តសកម្មភាពការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍប្រកបដោយចីរភាព យេនឌ័រ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ អភិវឌ្ឍនិងពង្រឹងស្ថាប័ន យន្តការ និងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់ជាន់ថ្នាក់ ពិសេសថ្នាក់មូលដ្ឋានសហគមន៍ ធានាដល់ការឆ្លើយតបបានល្អប្រសើរ ពេលមានគ្រោះអាសន្ន
- ស្វែងរកធនធានសម្រាប់អនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធីនិងគម្រោងពាក់ព័ន្ធ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

- ពង្រឹងកិច្ចសហប្រតិបត្តិការ កិច្ចសហការជាមួយដៃគូអភិវឌ្ឍ ផ្នែកសាធារណៈ ផ្នែកឯកជន សង្គមស៊ីវិល ដើម្បីជាគុណប្រយោជន៍ការកាត់បន្ថយគ្រោះមហន្តរាយ
- ពង្រឹងពង្រីកកិច្ចសហការក្នុងតំបន់និងអន្តរជាតិលើការគ្រប់គ្រងគ្រោះមហន្តរាយ
- គ្រប់គ្រងព័ត៌មាននិងប្រាស្រ័យទាក់ទងពាក់ព័ន្ធការងារគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
- លើកសំណើជូនរាជរដ្ឋាភិបាលអំពីតម្រូវការនិងការត្រៀមបម្រុង ថវិកា ធនធាន និងសម្ភារៈ និង អំពាវនាវរកជំនួយឆ្លើយតបសង្គ្រោះបន្ទាន់និងការស្តារឡើងវិញ
- ទទួលអនុវត្តការកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនពីរាជរដ្ឋាភិបាល។

ជំពូកទី៤

ការប្រព្រឹត្តទៅរបស់ គ.ជ.គ.ម.

មាត្រា៤ .-

គ.ជ.គ.ម. ត្រូវប្រជុំយ៉ាងតិច១ដងក្នុង១ឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។

ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធានប្រចាំការតាមការចាំបាច់។

មាត្រា៥ .-

គ.ជ.គ.ម. អាចអញ្ជើញតំណាងក្រសួងស្ថាប័ន ផ្នែកសាធារណៈ ផ្នែកឯកជន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ចូលរួមប្រជុំពិគ្រោះយោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយណាដែលទាក់ទងនឹងក្របខ័ណ្ឌការងារគ្រប់គ្រងគ្រោះមហន្តរាយ។

មាត្រា៦ .-

គ.ជ.គ.ម. មានគណៈកម្មាធិការប្រតិបត្តិមួយដែលមានសមាសភាពដូចខាងក្រោមៈ

- អនុប្រធានប្រចាំការ **គ.ជ.គ.ម.**	ប្រធាន
- អនុប្រធាន **គ.ជ.គ.ម.** ២រូប	អនុប្រធាន
- អគ្គលេខាធិការ **គ.ជ.គ.ម.**	សមាជិក។

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការប្រតិបត្តិនៃ **គ.ជ.គ.ម.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

មាត្រា៧ .-

គ.ជ.គ.ម. អាចមានទីប្រឹក្សាបច្ចេកទេសនិងអ្នកជំនាញមួយចំនួនតាមការចាំបាច់។

មាត្រា៨ .-

គ.ជ.គ.ម. ត្រូវមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ប្រតិបត្តិការងារប្រចាំថ្ងៃ។ អគ្គលេខាធិការដ្ឋាន **គ.ជ.គ.ម.** ដឹកនាំដោយអគ្គលេខាធិការមួយរូបនិងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ជ.គ.ម.** ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា៩ .-

គ.ជ.គ.ម. មានសិទ្ធិប្រើរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

ហ

ជំពូកទី៥
ប្រភពធនធាននិងមូលនិធិ

មាត្រា១០ .-

ការចំណាយសម្រាប់ដំណើរការ **គ.ជ.គ.ម.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

គ.ជ.គ.ម. មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាននិងមូលនិធិ ដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

ជំពូកទី៦
អន្តរប្បញ្ញត្តិ

មាត្រា១១ .-

មន្ត្រីរាជការដែលបានទទួលការតែងតាំងមុនព្រះរាជក្រឹត្យនេះចូលជាធរមាន នៅរក្សាមុខតំណែងនិងបុព្វសិទ្ធិដដែលរហូតដល់មានការតែងតាំងមន្ត្រីរាជការសាជាថ្មី ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ជំពូកទី៧
អវសានប្បញ្ញត្តិ

មាត្រា១២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១៣ .-

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស. ១២១៥. ១១៥៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា

សុខ អាន

លេខ ១២៥៩ ស.ណ

សំណៅដែលមានគន្លងជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/១២១៥/ ១១៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ដល់សព នាយទាហាន ថ្នាក់ឧត្តមសេនីយ៍និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី	**រស់**	**តិរុណា**	អត្តលេខ ០០១៩៣១
២-ឧត្តមសេនីយ៍ត្រី	**យឹម**	**យាន**	អត្តលេខ ០០០៨៩៣
៣-ឧត្តមសេនីយ៍ត្រី	**ស្រី**	**សុចិន្ត**	អត្តលេខ ០០៣៨១៦

ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក	**សុខ**	**ហេង**	អត្តលេខ ០០៩០៣៨
២-វរសេនីយ៍ឯក	**សុខ**	**នារី**	អត្តលេខ ០០២០៤៧
៣- វរសេនីយ៍ឯក	**គោគ**	**សារ៉េន**	អត្តលេខ ០០៩៥៥១
៤- វរសេនីយ៍ឯក	**ប្រាក់**	**ថន**	អត្តលេខ ០០៤៩៨៤
៥- វរសេនីយ៍ឯក	**មាស**	**សាផន**	អត្តលេខ ០១០៤៣៦
៦- វរសេនីយ៍ឯក	**ឈៀង**	**អ៊ី**	អត្តលេខ ០១៥៦៨១
៧- វរសេនីយ៍ឯក	**ទេព**	**សម្បត្តិ**	អត្តលេខ ០១០៤៧៤
៨- វរសេនីយ៍ឯក	**និន**	**សំអាត**	អត្តលេខ ០០០៩៤៣
៩- វរសេនីយ៍ឯក	**ម៉ម**	**សុខន**	អត្តលេខ ០១០៤៧២
១០- វរសេនីយ៍ឯក	**បាញ់**	**ឡេង**	អត្តលេខ ០០១០២៨
១១- វរសេនីយ៍ឯក	**ស៊ូ**	**សម្បត្តិ**	អត្តលេខ ០០៣៩១២
១២- វរសេនីយ៍ឯក	**ហម**	**យឿន**	អត្តលេខ ០០៣៩៤៤

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

១៣- វរសេនីយ៍ឯក **ព្រំ ហ៊ាង** អត្តលេខ ០០១០៣៣
១៤- វរសេនីយ៍ឯក **ប្រាក់ ចណ្ណារិទ្ធ** អត្តលេខ ០០៩០០៩
១៥- វរសេនីយ៍ឯក **ឃួង សាគុណា** អត្តលេខ ០១០០២៩
១៦- វរសេនីយ៍ឯក **ពៅ ស៊ីដេង** អត្តលេខ ០២៥៧១៤
១៧- វរសេនីយ៍ឯក **ស៊ុន ណារី** អត្តលេខ ០១៧៣៤៩

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧. ១៥១៤. ១១៦០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥

លេខ: ១១៦៥ស.ណ
សំណៅចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៨១...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញអនុក្រឹត្យលេខ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥

សម្រេច

មាត្រា១ .-

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ដែលមានចក្ខុវិស័យដល់ឆ្នាំ២០៣៥ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

មាត្រា២ .-

ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញនេះ អាចធ្វើការកែសម្រួលក្នុងរយៈពេល៥(ប្រាំ)ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញមុនពេលកំណត់អាចប្រព្រឹត្តទៅបាន ក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មាត្រា៣ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.១៨៦.អនក្រ.បក ចុះថ្ងៃទី.២៣...ខែ.......ធ្នូ...........ឆ្នាំ២០១៥

ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ

ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ២០៣៥

មាតិកា

ទំព័រ

១- សេចក្ដីផ្ដើម ៤

២- ចក្ខុវិស័យនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ ៦

៣- គោលបំណង និងគោលដៅនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ ៦

៣.១- គោលបំណង ៦

៣.២- គោលដៅ ៦

៤- យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ ៨

៤.១- ភ្នំពេញ-ប៉ូលអភិវឌ្ឍន៍ស្នូល ៨

៤.១.១- រាជធានីតូចមួយនៃអាស៊ីអាគ្នេយ៍ដែលត្រូវជម្នះឧបសគ្គសំខាន់ជាច្រើន ៨

៤.១.២- ទំហំនៃការរៀបចំដែនដី ៨

៤.១.៣- ប៉ូលសេវាកម្មកណ្ដាលសម្រាប់ប្រជាជនចំនួន៦លាននាក់ ៩

៤.១.៤- រាជធានីភ្នំពេញគឺជាចលករសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ៩

៤.១.៥- ភាពចាំបាច់នៃការធ្វើក្របខ័ណ្ឌប្លង់មួយថ្មី ១០

៤.២- ភ្នំពេញ-ទីក្រុងប្រកបដោយគុណភាពអន្តរជាតិ ១០

៤.២.១- រាជធានីភ្នំពេញគឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ១០

៤.២.២- មុខងារសំខាន់ៗសម្រាប់រាជធានីភ្នំពេញ ១៣

៤.២.៣- ពង្រឹងគុណសម្បត្តិនៃការទាក់ទាញនិងការប្រកួតប្រជែងរបស់រាជធានី ភ្នំពេញ ១៥

៤.២.៤- តុល្យភាពរវាងអភិក្រមខាងក្នុងនិងអភិក្រមខាងក្រៅ ១៥

៤.២.៥- ការពង្រីកផ្ទៃដីទីក្រុងធំ(មេត្រូប៉ូលីតែន) និងការកើនឡើងទ្វេដងនៃចំនួន ប្រជាជនឆ្នាំ២០៣៥ .... ១៦

៤.២.៦- កម្រិតទីមួយនៃការរៀបចំអភិវឌ្ឍន៍ ការធ្វើសមាហរណកម្មទៅក្នុងតំបន់...១៨

៤.៣- ការបម្រុងទុកនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្តមេចាំបាច់ ១៩

៤.៣.១- បណ្ដាញផ្លូវជាតិ ជាផ្លូវខ្សែក្រវាត់ព័ទ្ធជុំវិញទីក្រុងដ៏ធំ ១៩

៤.៣.២- ការបោះទីតាំងកំពង់ផែទាំងឡាយ ការរក្សាទុកកំពង់ផែនៅក្នុងទីក្រុង ១៩

៤.៣.៣- បណ្ដាញផ្លូវដែក ការស្ដារឡើងវិញនូវបណ្ដាញផ្លូវដែកដែលមាន ស្រាប់និងស្ថានីយរថភ្លើងថ្មីមួយនៅផ្នែកខាងលិចទីក្រុង ២០

ទំព័រ

៤.៣.៤- អាកាសយានដ្ឋានសព្វថ្ងៃអាចឆ្លើយតបសេចក្តីត្រូវការរហូតដល់ត្រឹមឆ្នាំ២០២០ ....២១
៤.៣.៥- យ៉ាងហោចណាស់ត្រូវមានទីកន្លែងផៃស្ងួតមួយដែលមានអន្តរគួនាទី......២៣

៤.៤- ការរៀបចំការអភិវឌ្ឍនគរូបនីយកម្មក្នុងកម្រិតទីក្រុងធំ....................២៤
៤.៤.១- ភាពបន្ទាន់នៃការកំណត់នូវបណ្តាញលម្ហសាធារណៈ ២៤
៤.៤.២- បណ្តាញផ្លូវតាមកម្រិតថ្នាក់ ២៤
៤.៤.៣- បណ្តាញពណ៌បៃតង(សួននិងដើមឈើ)និងពណ៌ខៀវ(ទឹក) ២៤
៤.៤.៤- ការបម្រុងទុកនូវប៉ូលអភិវឌ្ឍបន្ទាប់នានាក្នុងកម្រិតទីប្រជុំជនក្រុង....................២៥
៤.៤.៥- ភាពចាំបាច់ប្រព័ន្ធដឹកជញ្ជូនរួម ២៦

៤.៥- បេតិកភណ្ឌតំបន់ពិសេសនានានិងទេសភាពរបស់ទីក្រុង ២៦
៤.៥.១- តើត្រូវយកគំរូអភិវឌ្ឍន៍មួយណាសម្រាប់រាជធានីភ្នំពេញ?....................២៦
៤.៥.២- ការលើកតម្កើងតំបន់ចតុមុខ ២៧
៤.៥.៣- ការលើកតម្កើងការអភិវឌ្ឍតំបន់បឹងកក់....................២៨
៤.៥.៤- ការលើកតម្កើងបឹងនានានៅភាគខាងជើង ២៨
៤.៥.៥- ការរៀបចំផ្ទៃអាងចម្រោះទឹកកខ្វក់ខាងត្បូងទីក្រុង (បឹងជើងឯក)....................២៩
៤.៥.៦- ការរៀបចំទីតាំងទីលានចាក់សំរាម ២៩
៤.៥.៧- ការបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ទទួលអគារខ្ពស់ៗ....................២៩
៤.៥.៨- នយោបាយលំនៅឋានដីធ្លីនិងអចលនវត្ថុ ៣០

៥- ផែនការសកម្មភាព ៣២
៥.១- ការផ្សព្វផ្សាយ ៣៣
៥.២- គម្រោងសំខាន់ៗដែលត្រូវការចាំបាច់នូវការអនុម័តបន្ទាន់ ៣៣
៥.៣- បទប្បញ្ញត្តិនគរូបនីយកម្ម....................៣៣
៥.៤- សកម្មភាពអភិវឌ្ឍន៍បន្តនិងវិនិយោគសាធារណៈ ៣៤

៦- សេចក្តីសន្និដ្ឋាន ៣៤
- ផែនទីរូបភាព ....

១- សេចក្តីផ្តើម

ការធ្វើប្លង់គោលនគរូបនីយកម្មរាជធានីភ្នំពេញ ត្រូវបានរៀបចំឡើង(ជាច្រើនលើក)តាំងពីជាងមួយសតវត្សរ៍មកហើយ ប៉ុន្តែ មានតែគម្រោងប្លង់គោលនគរូបនីយកម្មដែលបានរៀបចំដោយក្រសួងកសិកម្មនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៥០ តែមួយគត់ដែលត្រូវបានអនុម័តឲ្យប្រើប្រាស់នៅឆ្នាំ១៩៥៦។

ប្លង់គោលនាពេលនោះគឺជាឧបករណ៍គោលដ៏សំខាន់មួយ(ក្នុងការគ្រប់គ្រងនិងតម្រង់ទិស) ការអភិវឌ្ឍទីក្រុងភ្នំពេញចាប់ពីសម័យទទួលបានឯករាជ្យរហូតដល់សម័យមានសង្គ្រាម។ ពោលវាជាឯកសារដែលត្រូវបានគេប្រើប្រាស់ជាមគ្គុទ្ទេសក៍ សម្រាប់ការធ្វើបទប្បញ្ញត្តិនគរូបនីយកម្ម និងក៏ជាមគ្គុទ្ទេសក៍សម្រាប់គម្រោងធំៗដទៃទៀតដូចជាពហុកីឡដ្ឋានអូឡាំពិក សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បុរីកីឡា ដីឡូត៍នៅជុំវិញពហុកីឡដ្ឋានអូឡាំពិក ទួលគោក សាលមហោស្រពព្រះសុរាម្រឹត វិមានឯករាជ្យ...។ល។ ដើម្បីឆ្លើយតបនឹងសេចក្តីប្រាថ្នា(មហិច្ឆតា)ធំៗរបស់ប្រទេស។

ប៉ុន្តែការធ្វើប្លង់គោលពេលនោះបានគ្របដណ្តប់ត្រឹមព្រំដែនកំណត់ក្រុងមួយ ដែលមានទំហំមួយតូចនៅឡើយ ពោលគឺនៅត្រឹម៤ខណ្ឌចាស់កណ្តាលក្រុងសព្វថ្ងៃដែលដីធ្លីត្រូវបានប្រើប្រាស់អស់តាំងពីទសវត្សរ៍ឆ្នាំ១៩៦០ សម្រាប់អនុវត្តតាមផែនការពង្រីកទីក្រុងទៅគ្រប់តំបន់នានានៅពេលនោះ។ ចាប់ពីទសវត្សរ៍ឆ្នាំ១៩៧០រហូតមកដល់បច្ចុប្បន្ន គ្រប់ការសាកល្បងដើម្បីកំណត់នូវការរៀបចំធ្វើប្លង់គោលនគរូបនីយកម្មនានា ត្រូវទទួលបរាជ័យទាំងអស់ ដោយសារកង្វះធនធានមនុស្សនិងគ្មានមធ្យោបាយគ្រប់គ្រាន់ដែលអាចប្រើប្រាស់បាន និងដោយសារប្រទេសគ្មានស្ថិរភាព ជាពិសេសក្នុងរបបខ្មែរក្រហម ដែលភ្នំពេញមិនត្រឹមតែមិនអាចបន្តការអភិវឌ្ឍ តែត្រូវបានរងការបំផ្លិចបំផ្លាញ និងស្ទើរតែត្រូវបានបោះបង់ចោលទាំងស្រុង ក្លាយជាទីក្រុងដែលគ្មានមនុស្សរស់នៅ។ ចាប់ពីក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ ភ្នំពេញត្រូវស្តារជាបន្តបន្ទាប់។ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ពិសេសចាប់ពីឆ្នាំ១៩៩៨ដែលប្រទេសកម្ពុជាបានស្គាល់ស្ថិរភាពពេញលេញទូទាំងប្រទេសកើតពីនយោបាយឈ្នះ-ឈ្នះរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បាតុភូតនៃការអភិវឌ្ឍទីក្រុងមានល្បឿនយ៉ាងលឿនដោយបានផ្លាស់ប្តូរមាឌមាត្រដ្ឋានយ៉ាងឆាប់រហ័សតាមគំរូនៃការអភិវឌ្ឍមួយដែលរីកសាយដូចស្នាមតំណក់ប្រេងដែលស្រក់លើក្រដាស បន្តពីគម្រោងប្លង់នគរូបនីយកម្មនៃទីក្រុងចាស់។ ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃតំបន់នានាជាយក្រុងក្នុងកាលៈទេសៈមួយដែលនៅមិនទាន់មានប្លង់គោលតម្រង់ទិសបាននាំឲ្យលេចចេញនូវនគរូបនីយកម្មមួយដែលមិនសូវមានលក្ខណៈគ្រង់ស្មើ អតុល្យភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងនាំឲ្យមានភាពមិនគ្រប់ជ្រុងជ្រោយឬភាពខ្វះចន្លោះនៃប្រសិទ្ធភាពគ្រប់គ្រងលម្ហសាធារណៈ បរិក្ខារសាធារណៈនិងមធ្យោបាយដឹកជញ្ជូនដូចជាទោចក្រយានយន្តរថយន្ត។ ជាបទពិសោធជាក់ស្តែងកន្លងនៅខាងក្នុងទំនប់កប់ស្រូវ ដែលទំនប់នេះត្រូវបានគេសាងនៅភាគខាងជើងភ្នំពេញនៅដើមទសវត្សរ៍ឆ្នាំ១៩៧០សម្រាប់ក្រវាត់សុវត្ថិភាពក្រុង ក្លាយជាតំបន់អភិវឌ្ឍចម្រុះមិនរាបស្មើ មានការអភិវឌ្ឍដោយដុំតូចៗពង្រាយពុំស្មើសាច់[illegible]

ការវិវត្តស្បែកខ្លានៅលើដែនដីដ៏ធំ ដែលជាដីសម្រាប់សាងសង់ទីក្រុងផងនិងជាដីសម្រាប់កសិកម្មផង នៅពេលដែលតំបន់នេះនៅមានការខ្វះខាតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធចាំបាច់ខ្លះសម្រាប់គាំទ្រក៏ដោយ (ភ្លើងអគ្គិសនី ទឹកស្អាត ផ្លូវថ្នល់) ក៏នៅមានការបោះទីតាំងថ្មីនៃដីឡូត៍និងរោងចក្រនានាដែលជួនកាលស្ថិតនៅចម្ងាយរាប់គីឡូម៉ែត្រពីទីប្រជុំជន។

ជាមួយគ្នានេះ ការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃតំបន់អាស៊ីអាគ្នេយ៍ បានបង្កើតឡើងនូវការប្រមូលផ្តុំនៃភាពសំបូរបែបថ្មីៗជាច្រើន ដែលនឹងតម្រូវឲ្យមានការរៀបចំគម្រោងរៀបចំដែនដីធំៗក្នុងក្រុង ដូចជាគម្រោងរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបសាស្ត្រសម្រាប់គាំទ្រធំៗ និងការបង្កើតឡើងនូវរចនាសម្ព័ន្ធគ្រប់គ្រងក្រុងធំមួយដ៏មានប្រសិទ្ធភាព។ ក្នុងបរិបទនេះ រាជធានីភ្នំពេញត្រូវតែស្វះស្វែងរកមធ្យោបាយដើម្បីទាក់ទាញនិងកៀរគរនូវហិរញ្ញប្បទានពីប្រភពនានា សំដៅធ្វើឱ្យសម្រេចគម្រោងអភិវឌ្ឍន៍សំខាន់ទាំងនេះ។ ក៏ប៉ុន្តែអ្វីដែលជាបញ្ហាប្រឈមនោះ គឺការបណ្តែតបណ្តោយទៅតាមវិនិយោគិននានា ដែលគ្មានគម្រោងពិតប្រាកដ និងភាពមិនទៀងទាត់ក្នុងការវិនិយោគ ដែលនាំឱ្យខូចប្រយោជន៍ដល់ការតម្រង់ទិសធំៗ សម្រាប់ការអភិវឌ្ឍទីក្រុងនាពេលអនាគត។

ម្យ៉ាងទៀត យើងក៏ត្រូវតែគិតគូរពីការកើនឡើងទ្វេដងនៃចំនួនប្រជាជននិងផ្ទៃដីសម្រាប់ការកសាងពង្រីកទីក្រុងចាប់ពីពេលនេះរហូតដល់ឆ្នាំ២០៣៥ ដែលតម្រូវឱ្យមានការបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធនិងបរិក្ខារសាធារណៈធំៗ បន្ថែមទៀតសម្រាប់ដែនដីរាជធានីភ្នំពេញមួយជាក្រុងធំ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិនៃរាជរដ្ឋាភិបាលកម្ពុជាដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ** បានសម្រេចនូវជោគជ័យធំៗជាច្រើនពិសេសការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការធ្វើឱ្យសេដ្ឋកិច្ចមានកំណើនឡើងវិញ បន្ទាប់ពីត្រូវបានរងផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចសកលលោកនាឆ្នាំ២០០៩ និងការសម្រេចបាននូវវឌ្ឍនភាពក្នុងដំណើរអភិវឌ្ឍន៍សង្គមកិច្ចសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៥។ ទន្ទឹមនេះ កម្ពុជាបានធ្វើសមាហរណកម្មខ្លួនយ៉ាងជោគជ័យនិងពេញលេញចូលទៅក្នុងតំបន់និងពិភពលោក ហើយកំពុងដើរតួនាទីយ៉ាងសកម្មក្នុងបេសកកម្មជាអន្តរជាតិធំៗ និងក្នុងកិច្ចសហប្រតិបត្តិការនានា ប្រកបដោយថាមភាពនិងចីរភាពក្នុងឋានៈជាសមាជិកស្មើភាពនិងស្មើសិទ្ធិលើឆាកអន្តរជាតិ។ វឌ្ឍនភាពស្ថិរភាពសង្គមរបស់ប្រទេសកម្ពុជា និងនិន្នាការនៃការកើនឡើងយ៉ាងឆាប់រហ័សនៃនគរូបនីយកម្ម បានតម្រូវឱ្យមានការរៀបចំជាថ្មី ឲ្យមានគម្រោងប្លង់គោលនេះឡើង សម្រាប់ប្រើប្រាស់ជាឧបករណ៍គន្លឹះប្រកបដោយប្រសិទ្ធភាព ដែលអាចគ្របដណ្តប់បានទាំងទិដ្ឋភាពច្បាប់និងបច្ចេកទេសសំដៅធ្វើការតម្រង់ទិស និងគ្រប់គ្រងការអភិវឌ្ឍរាជធានីភ្នំពេញឲ្យប្រកបដោយនិរន្តរភាព ឆ្លើយតបបានទៅនឹងនិន្នាការអភិវឌ្ឍន៍របស់ប្រទេសទាំងក្នុងក្របខ័ណ្ឌជាតិទាំងក្នុងពេលបច្ចុប្បន្ននិងក្នុងពេលអនាគត។

២- ចក្ខុវិស័យនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍

ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយជាតិស្តីពីការរៀបចំដែនដីរបស់រាជរដ្ឋាភិបាលកម្ពុជា ចក្ខុវិស័យនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ រាជធានីភ្នំពេញ គឺ*ភ្នំពេញជាក្រុងរាជធានី ជាបេះដូងរបស់ប្រទេសកម្ពុជាដែលស្ថិតនៅលើចំណុចពិសេសនៃប្រសព្វទន្លេបួន ហៅថាទន្លេបួនមុខ ដែលជាអត្តសញ្ញាណតែមួយគ្មានពីរ ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ចពាណិជ្ជកម្ម វប្បធម៌ ប្រកបដោយសក្តានុពលប្រកួតប្រជែង ជាមួយការអភិវឌ្ឍមួយប្រកបដោយវឌ្ឍនភាព សមធម៌ និងចីរភាព។*

ការតម្រង់ទិសអភិវឌ្ឍន៍ផ្នែកនគរូបនីយកម្មសំដៅធានាការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រដ្ឋក្នុងដែនដីរាជធានីឱ្យមានប្រសិទ្ធភាព និងមាននិរន្តរភាព ពិសេសដើម្បីតម្រង់ទិសការវិនិយោគសាធារណៈនិងឯកជន ក៏ដូចជាការវិនិយោគរបស់ដៃគូអភិវឌ្ឍទាំងអស់ចាប់ពីពេលនេះរហូតដល់ឆ្នាំ២០៣៥។ យុទ្ធសាស្ត្រនេះនឹងជួយសាលារាជធានីភ្នំពេញ ប្រជាជនទាំងអស់ វិនិយោគិន ព្រមទាំងដៃគូអភិវឌ្ឍនានា ឱ្យចូលរួមអភិវឌ្ឍទីក្រុងប្រកបដោយសណ្តាប់ធ្នាប់ល្អ ហើយក៏ធ្វើឱ្យមានវឌ្ឍនភាពដល់ការវិនិយោគនានាដោយកាត់បន្ថយឬបញ្ចៀសបាននូវហានិភ័យនានាជាអតិបរមា ។

៣- គោលបំណងនិងគោលដៅនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍

៣.១- គោលបំណង

គោលបំណងនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍នគរូបនីយកម្មរាជធានីភ្នំពេញគឺៈ

- តម្រង់ទិសការប្រើប្រាស់ដីធ្លី និងធានាតម្លៃសក្តានុពល ដែលមានស្រាប់របស់ទីក្រុងប្រកបដោយប្រសិទ្ធភាពខ្ពស់ ចីរភាព និងសមធម៌ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការធានាសន្តិសុខស្បៀងសោភណភាព និងគុណភាពបរិស្ថាន
- តម្រង់ទិសការអភិវឌ្ឍដោយតុល្យភាព សមភាព និងភាពស៊ីចង្វាក់គ្នា រវាងរាជធានីភ្នំពេញ ទីក្រុងតូចបន្ទាប់ ខេត្តរបស់ប្រទេស និងទីក្រុងរបស់ប្រទេសនានា
- ធានាការលើកស្ទួយអត្តសញ្ញាណរាជធានីភ្នំពេញ ដើម្បីធ្វើសមាហរណកម្មទៅក្នុងតំបន់ និងប្រកួតប្រជែងជាមួយទីក្រុងនានានៅក្នុងតំបន់ សម្រាប់ការអភិវឌ្ឍនៅក្នុងបរិបទដែលផ្តល់នូវលទ្ធភាពធំជាងពេលមុន ទាំងលើផ្នែកបច្ចេកទេសនិងផ្នែកហិរញ្ញវត្ថុ។

៣.២- គោលដៅ

គោលដៅនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍រាជធានីគឺសំដៅៈ

- អភិវឌ្ឍន៍ប្រកបដោយចីរភាព ធានាបាននូវការផ្គត់ផ្គង់សេចក្តីត្រូវការ និងការទទួលខុសត្រូវចំពោះផលប្រយោជន៍របស់មនុស្សបច្ចុប្បន្ននិងអ្នកជំនាន់ក្រោយ។

- គ្រប់គ្រងការពារប្រើប្រាស់សក្តានុពល និងអភិវឌ្ឍធនធានធម្មជាតិ ដោយកំណត់ឱ្យច្បាស់លាស់ជាមុននូវទីតាំងឬតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការអភិវឌ្ឍថ្មី (តំបន់ដែលទើបបញ្ចូលពីខេត្តកណ្តាល) និងការអភិរក្សនូវតំបន់ ដែលសំបូរសំណង់បេតិកភណ្ឌប្រវត្តិសាស្ត្រក្នុងទីក្រុងចាស់
- រក្សានូវការប្រើប្រាស់ដីធ្លីសម្រាប់រយៈពេលវែងដើម្បីឱ្យមានតុល្យភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថានព្រមទាំងសោភណភាពរាជធានីភ្នំពេញ
- ប្រើប្រាស់នូវសក្តានុពលដែលមានពីធម្មជាតិ (ទីតាំងតំបន់ចតុមុខ និងបឹងធម្មជាតិនានា) ឱ្យប្រសើរនិងមានប្រសិទ្ធភាព ទៅតាមលក្ខណៈពិសេសនៃតំបន់នីមួយៗ
- លើកកម្ពស់កម្រិតជីវភាពប្រជាជន ទីក្រុង ឱ្យកាន់តែប្រសើរ និងកាត់បន្ថយជាអតិបរមានូវគម្លាតរវាងសង្កាត់កណ្តាលក្រុងនិងសង្កាត់ជាយក្រុង
- ធានាការប្រើប្រាស់ ការអភិវឌ្ឍ និងការគ្រប់គ្រងដី តាមផែនការរៀបចំដែនដី និងផែនការប្រើប្រាស់ដី ប្រកបដោយសមភាពយេនឌ័រ និងគាំទ្រដល់ជីវភាពរស់នៅរបស់ក្រុមជនងាយរងគ្រោះ
- រៀបចំបន្ស៊ីការគ្រប់គ្រងដី ការអភិវឌ្ឍថ្មី និងការការពារតំបន់នីមួយៗនៃរាជធានីភ្នំពេញឱ្យមានភាពសុខដុមរមនាជាមួយគ្នា និងឱ្យស្របទៅនឹងលក្ខខណ្ឌ និងផែនការមេនៃការរៀបចំដែនដីរបស់ប្រទេស
- ទប់ស្កាត់និងកាត់បន្ថយនូវហានិភ័យនៃគ្រោះធម្មជាតិនានា ដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍។

ដើម្បីសម្រេចនូវគោលបំណងនិងគោលដៅខាងលើ សាលារាជធានីភ្នំពេញ ត្រូវរៀបចំឯកសារគោលនយោបាយបញ្ជាក់អំពីសេចក្តីប្រាថ្នាធំៗ នៃការអភិវឌ្ឍរបស់រដ្ឋលើដែនដីរាជធានីសម្រាប់អនាគតឆ្នាំ២០៣៥អមដោយផែនទីគោល(Master Schema)ដែលជាឯកសារបច្ចេកទេសបន្ថែមទៅលើឯកសារយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ទីក្រុងនេះ ដោយកំណត់យកផែនទីមានមាត្រដ្ឋាន១/៥០០០០ ខ្នាតUTM WG84 រៀបចំឡើងនៅឆ្នាំ២០១៥ ដោយមានការដាក់បញ្ចូលនូវគ្រប់ហេដ្ឋារចនាសម្ព័ន្ធធំៗនៃផ្លូវដែលមានទំហំធំលើសពី២០ម៉ែត្រឡើង ខ្សែផ្លូវដែក ប្រឡាយ មេនានា បឹង បរិក្ខារសាធារណៈធំៗដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន ស្ថានីយរថយន្តក្រុង ដែលជាលក្ខខណ្ឌចាំបាច់គាំទ្រដល់ការអភិវឌ្ឍទីក្រុង។ ឯកសារបទប្បញ្ញត្តិនគរូបនីយកម្មតាមសង្កាត់នីមួយៗ ដែលនឹងត្រូវកំណត់នៅពេលក្រោយដោយមន្ទីរនានារបស់សាលារាជធានី ដោយមានការពិគ្រោះយោបល់រវាងប្រជាជនក្នុងមូលដ្ឋាន និងអាជ្ញាធរសង្កាត់ស្របទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។ ចំពោះឯកសារប្លង់ប្រើប្រាស់ដីធ្លីលម្អិត ខ្នាតតំបន់ និងបទប្បញ្ញត្តិនគរូបនីយកម្មនានា ដែលនឹងត្រូវតាក់តែងក្រោយមកទៀតដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ និងទីចាត់ការរៀបចំក្រុងរបស់សាលារាជធានីភ្នំពេញ អនុលោមទៅតាមផែនទីគោលនៃយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ទីក្រុងនេះ។

៤- យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍

ផ្អែកតាមគោលនយោបាយជាតិរៀបចំដែនដី និងសៀវភៅស្តីពីការវិភាគវិនិច្ឆ័យសេដ្ឋកិច្ចសង្គម និងបរិស្ថាន រាជធានីភ្នំពេញនឹងត្រូវរៀបចំអភិវឌ្ឍន៍តាមយុទ្ធសាស្ត្រតម្រង់ទិសដូចតទៅៈ

៤.១- ភ្នំពេញ-ប៉ូលអភិវឌ្ឍន៍ស្នូល

៤.១.១- រាជធានីតូចមួយនៃអាស៊ីអាគ្នេយ៍ដែលត្រូវជម្នះឧបសគ្គសំខាន់ជាច្រើន

ជាមួយនឹងប្រជាជនរស់នៅអចិន្ត្រៃយ៍ចំនួន១ ៣២៥ ៦៨១នាក់[១] (រូបភាពទី១នៃឯកសារឧបសម្ព័ន្ធ) **ភ្នំពេញស្ថិតនៅលើទីតាំងភូមិសាស្ត្រមួយ** ដែលហាក់ដូចជានៅឆ្ងាយពីលំហូរធំៗនៃសេដ្ឋកិច្ចពិភពលោក និងជាទីក្រុងតូចមួយបើប្រៀបធៀបទៅនឹងទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍មានដូចជា ហ្សាការតា ម៉ានីល បាងកក ហូជីមិញ សិង្ហបុរី។ ក្នុងស្ថានភាពនេះ រាជធានីភ្នំពេញត្រូវជម្នះឧបសគ្គសំខាន់ៗ ដើម្បីកំណត់និងលើកតម្លៃឡើងវិញនូវទីតាំងនិងអត្តសញ្ញាណរបស់ខ្លួននៅក្នុងតំបន់ និងធ្វើឱ្យប្រសើរឡើងនូវក្នុងបណ្តាញនៃការផ្លាស់ប្តូរពាណិជ្ជកម្មឈានទៅពង្រឹងឱ្យបាននូវគុណសម្បត្តិទាក់ទាញនិងការប្រកួតប្រជែងរបស់ខ្លួន។

៤.១.២- ទំហំនៃការរៀបចំដែនដី

រាជធានីភ្នំពេញជាទីក្រុងរាជធានីសំខាន់តែមួយគត់របស់កម្ពុជា ដែលហ៊ុមព័ទ្ធដោយតំបន់ជនបទនៅឡើយ។ ភ្នំពេញ និងទីប្រជុំជនជុំវិញ មានប្រជាជន១០%នៃប្រជាជនសរុបរបស់ប្រទេស ១៣ ៣៨៨ ៩១០នាក់ (តាមជំរឿន២០០៨របស់វិទ្យាស្ថានជាតិស្ថិតិ) ស្មើនឹង៥៣% នៃប្រជាជននៅតាមទីប្រជុំជនក្នុងប្រទេស។ មានតែទីប្រជុំជនខេត្តបាត់ដំបង សៀមរាប និងមង្គលបុរី (សិរីសោភ័ណ)ទេ ដែលមានប្រជាជនលើសពី១០០ ០០០នាក់ ទីក្រុងព្រះសីហនុ (ខណ្ឌមិត្តភាព) កំពុងមានកំណើនប្រជាជនយ៉ាងឆាប់រហ័ស (ស្មើ១៥%ក្នុងមួយឆ្នាំ) ហើយនឹងតាមទាន់ទីក្រុងធំៗទីពីរ ទាំងបីនៅពេលឆាប់ៗខាងមុខនេះ។ ទីប្រជុំជនជាងដប់ទៀតមានប្រជាជន នៅចន្លោះពី ២៥ ០០០ ទៅ៦០ ០០០នាក់ និងស្ថិតនៅលើអ័ក្សទំនាក់ទំនងធំៗ ដែលកំណត់បានជារចនាសម្ព័ន្ធទំនាក់ទំនងរបស់ប្រទេស។

គោលនយោបាយរៀបចំដែនដី នឹងជំរុញនូវការគ្រោងឱ្យមានទីក្រុងធំទី២បន្ទាប់ពីរាជធានីភ្នំពេញ ដើម្បីបង្កើតឱ្យមានការអភិវឌ្ឍប្រកបដោយសមភាព តុល្យភាព រួមចំណែកទទួលចែករំលែកនូវបន្ទុកសេវាកម្មសាធារណៈ ឲ្យមានកម្រិតប្រសើរឡើង សម្រាប់ដែនដីទាំងមូលរបស់ប្រទេស។ នេះជាមធ្យោបាយមួយដើម្បីសម្រាលនូវសម្ពាធនៃកំណើនហួសហេតុប្រជាជនក្នុងតំបន់ប្រមូលផ្តុំតែមួយ ជាពិសេសក្នុងទីកណ្តាលរាជធានីភ្នំពេញ[២] ដែលត្រូវតែគ្រប់គ្រងការពង្រាយការអភិវឌ្ឍឱ្យបានល្អ។ ការអភិវឌ្ឍដោយផ្អែកលើប៉ូលនានានៅលើអ័ក្ស

[១] ទីប្រជុំជនមានប្រជាជន ១៥០ ០០០ នាក់បន្ថែមទៀតនៅក្រៅក្រុង ជាពិសេសនៅតាខ្មៅ និងតាមបណ្តាលផ្លូវជាតិលេខ ១ ៥ ៥ និង៦

[២] បច្ចុប្បន្នប្រជាជននៅទីក្រុងភ្នំពេញកើនឡើង៥០០០០នាក់ក្នុង១ឆ្នាំ ក្នុងនោះមាន១៥០០០ ជាជនអន្តោប្រវេសន៍ រាជធានីភ្នំពេញទ... បម្លាស់ទី២០% ពីទីអន្តរតំបន់ ជាពិសេសមកពីខេត្តនៅក្បែរៗក្រុង។

រាជធានីភ្នំពេញ-ក្រុងព្រះសីហនុ គឺជាគោលការណ៍អភិវឌ្ឍន៍មួយនៅក្នុងតំបន់និរតីនៃប្រទេស។ តំបន់វាលទំនាបហាក់ដូចជាមានទំហំថយចុះពី៥១% ក្នុងពេលសព្វថ្ងៃនេះ មក៤៨%នៅឆ្នាំ២០៣៥។ ឯទីក្រុងភ្នំពេញអាចនឹងមានកំណើនយឺតជាងទីក្រុងទី២ផ្សេងៗទៀត។ លទ្ធផលរំពឹងទុកសំខាន់នៃការអភិវឌ្ឍប្រទេស នឹងស្ថិតលើការរៀបចំទីក្រុងទី២ទាំងនោះដែលនឹងមានប្រជាជនកើនឡើង៥ដងនៅពេលដែលរាជធានីភ្នំពេញមានប្រជាជនកើនឡើងតែពីរដងប៉ុណ្ណោះ។

៤.១.៣- ប៉ូលសេវាកម្មកណ្តាលសម្រាប់ប្រជាជនចំនួន៦លាននាក់

តាមពិតទៅរាជធានីភ្នំពេញ គឺជាប៉ូលសេវាកម្មកណ្តាលមួយក្នុងតំបន់ដែលប្រមូលផ្តុំនូវប្រជាជនជាង៦លាននាក់នៅក្នុងកាំរង្វង់ចម្ងាយ១០០គីឡូម៉ែត្រជុំវិញ (រូបភាពទី២និងទី៣នៃឯកសារឧបសម្ព័ន្ធ) ដែលប្រហាក់ប្រហែលនឹងទីក្រុងធំៗមួយចំនួននៅអាស៊ីអាគ្នេយ៍ ដូចជាទីក្រុងបាងកកបម្រើប្រជាជន៩លាននាក់ ទីក្រុងហាណូយបម្រើប្រជាជន៨លាននាក់ ទីក្រុងហូជីមិញ ៧លាននាក់ សិង្ហបុរី ៥លាននាក់ និងទីក្រុងកូឡាឡាំពួរ ៤លាននាក់។

ការពង្រឹងនូវតួនាទីរបស់ទីក្រុងសំខាន់ៗនៃខេត្តនានា និងការជំរុញឱ្យលេចឡើងនូវរចនាសម្ព័ន្ធនគរូបនីយកម្ម ដែលមានការអភិវឌ្ឍប្រកបដោយគុណភាពសុខដុមនីយកម្មជាមួយគ្នាជាកត្តាសំខាន់មួយក្នុងការជំរុញការអភិវឌ្ឍដែនដីទាំងមូល។ ប៉ុន្តែគោលនយោបាយនេះមិនត្រូវធ្វើជ្រុលហួសហេតុនាំឱ្យខូចគុណប្រយោជន៍នៃការលើកតម្កើងតម្លៃរាជធានីភ្នំពេញ ដែលជាអ្នកផ្តល់សេវាសម្រាប់ប្រទេសទាំងមូលនោះទេ ជាពិសេស គឺសម្រាប់ប្រជាជនជាង៦លាននាក់(ដែលស្មើនឹងជិតពាក់កណ្តាលនៃប្រជាជនសរុបរបស់ប្រទេស) ដែលរស់នៅក្នុងតំបន់វាលទំនាបស្ថិតនៅក្នុងរង្វង់១០០គីឡូម៉ែត្រជុំវិញ ដែលចំនួននេះនឹងកើនឡើងទ្វេដងនៅឆ្នាំ២០៣៥។

៤.១.៤- រាជធានីភ្នំពេញគឺជាចលករសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា

ការវិនិយោគទុនដើម្បីលើកកម្ពស់ទីក្រុងគឺជាភាពចាំបាច់និងផ្តល់ផលប្រយោជន៍ដល់ទីក្រុង

រាជធានីភ្នំពេញមានមុខងារជារាជធានីដែលជាទីប្រមូលផ្តុំនូវសកម្មភាពនយោបាយ និងសេដ្ឋកិច្ច ដែលអាចមានផលិតផលក្នុងស្រុកសរុបរហូតដល់ប្រហែល ១,៣ប៊ីលានដុល្លារអាមេរិក (នៅឆ្នាំ២០០៣) គឺស្មើនឹង៣១%នៃផលិតផលក្នុងស្រុកសរុបរបស់ជាតិ ហើយដែលបច្ចុប្បន្នផលទុនសរុបប្រចាំឆ្នាំបានកើនលើសពី១ ០០០ដុល្លារអាមេរិកទៅហើយសម្រាប់ប្រជាជនម្នាក់ គឺស្មើជិត៤ដងច្រើនជាងផលិតផលក្នុងស្រុកសរុបមធ្យមនៃប្រជាជនម្នាក់ដែលរស់នៅតាមខេត្តនានា។ ដូច្នេះរាជធានីភ្នំពេញមានភាពធូរធារជាងតំបន់ដទៃទៀតនៃប្រទេសកម្ពុជា។ ប៉ុន្តែរាជធានីភ្នំពេញក៏នៅតែមានភាពទន់ខ្សោយនៅឡើយ បើប្រៀបធៀបនឹងផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់នៅទីក្រុងបាងកកដែលមានចំនួនច្រើនជាងនេះ១០ដង[៣] (រូបភាពទី៤នៃឯកសារឧបសម្ព័ន្ធ)។

[៣]ផលិតផលក្នុងស្រុកដុលជាមធ្យមក្នុងប្រជាជនម្នាក់គឺប្រហែល២៧០ដុល្លារអាមេរិក នៅប្រទេសកម្ពុជា៨០០ដុល្លារអាមេរិក នៅប្រទេសវៀតណាម និង២៤០០ នៅប្រទេសថៃ(ទិន្នន័យឆ្នាំ២០០០)

ជាមួយគ្នានេះ ទោះបីភ្នំពេញគឺជាកន្លែងប្រមូលផ្តុំនូវភាពសំបូរបែបធូរធារមួយក៏ដោយ ក៏នៅពឹងផ្អែកយ៉ាងខ្លាំងលើកត្តាខាងក្រៅ ដោយត្រូវដោះស្រាយនូវបញ្ហាធំៗមួយចំនួន ពិសេសការវិនិយោគទុនចាំបាច់ជាច្រើនដើម្បីផលប្រយោជន៍រួមផង និងដើម្បីជំរុញនូវភាពទាក់ទាញរបស់ទីក្រុងផង។ ដូច្នេះ មិនត្រូវបង្អង់ការអភិវឌ្ឍរាជធានីភ្នំពេញដោយបង្វែរការអភិវឌ្ឍជាអាទិភាពទៅតំបន់ដទៃទៀតរបស់ប្រទេសទេ ពីព្រោះរាជធានីគឺជាកញ្ចក់ឆ្លុះបញ្ចាំង ហើយក៏ជាចលករសេដ្ឋកិច្ចមួយរបស់ប្រទេសផងដែរ ជាមួយកំណើនសេដ្ឋកិច្ច១២%នៅរាជធានីភ្នំពេញ។ សម្រាប់ការធ្វើវិនិយោគទុនបរទេសមួយចំនួន ជម្រើសមិនមែនស្ថិតនៅចន្លោះរវាងរាជធានីភ្នំពេញនិងខេត្តនានានោះទេ គឺរវាងរាជធានីភ្នំពេញនិងទីក្រុងធំៗនានាដែលជាគូប្រជែងនៅតំបន់អាស៊ីអាគ្នេយ៍។

៤.១.៥- ភាពចាំបាច់នៃការធ្វើក្របខ័ណ្ឌប្លង់មួយថ្មី

ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ការអភិវឌ្ឍរាជធានីភ្នំពេញត្រូវបានអនុវត្តតាមប្លង់រូបវន្តនគរូបនីយកម្មមួយដែលត្រូវបានរៀបចំឡើងយ៉ាងហ្មត់ចត់ ជាទីក្រុងព័ទ្ធដោយទំនប់(ការលើកទំនប់ដើម្បីចាក់បំពេញដីសម្រាប់សាងសង់ ការរៀបជាផ្លូវខ្វាត់ខ្វែងដើម្បីកសាងទីក្រុង និងផែនការនគរូប-នីយកម្មធំៗ ដែលមួយផ្នែកត្រូវបង្កើតឡើងដើម្បីការពារទប់ស្កាត់គ្រោះទឹកជំនន់)។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងប្លង់នេះបានកំណត់មានទីក្រុងមួយ ដែលត្រៀមសម្រាប់ការទទួលយកប្រជាជនឲ្យចូលមករស់នៅតែត្រឹម៥០ម៉ឺននាក់ប៉ុណ្ណោះ។ លើសពីចំនួននេះ ភ្នំពេញត្រូវតែមានការគិតគូរឡើងវិញជាចាំបាច់ដើម្បីជៀសវាងនូវវិបត្តិនគរូបនីយកម្ម។ ជាក់ស្តែង បន្ទាប់ពីមានចំណូលយ៉ាងគំហុកនៃប្រជាជនថ្មីពីជនបទមកទីក្រុងកើនឡើង នៅពាក់កណ្តាលដើមទសវត្សរ៍ឆ្នាំ១៩៧០ (ទីក្រុងមានប្រជាជនប្រែប្រួលពី៧០០ ០០០ ទៅ១,៣លាននាក់ ក្នុងរយៈពេល៥ឆ្នាំក្រោយមក) នាំឲ្យមានប្រជាជនច្រើនដែលហួសពីការមិនអាចគ្រប់គ្រងបាន។ បច្ចុប្បន្នប្រជាជនក្នុងរាជធានីភ្នំពេញបានបន្តកើនឡើងជាបន្តបន្ទាប់ ការទទួលយកប្រជាជនពីទីជនបទឲ្យចូលមករស់នៅវិញបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅទសវត្សរ៍ទី៨នៃសតវត្សរ៍ទី២១ ការបើកចំហសេដ្ឋកិច្ចដល់អន្តរជាតិ និងផ្អែកលើសន្ទុះនៃការស្តារឡើងវិញ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០មក រាជធានីភ្នំពេញបានទទួលនូវកំណើនយ៉ាងលឿន។ ជាមួយគ្នានេះ ក៏មានការរីកដុះដាលសំណង់និងនគរូបនីយកម្មកាន់តែខ្លាំងឡើងៗ ហើយគម្រោងអភិវឌ្ឍនានាត្រូវបានកើនឡើងជាបន្តបន្ទាប់ ធ្វើឱ្យដែនដីនៃរាជធានីរីកលាតសន្ធឹងកាន់តែធំទូលាយជាងមុនដែល ទាមទារឲ្យរាជធានីភ្នំពេញត្រូវមានគោលនយោបាយអភិវឌ្ឍជាយុទ្ធសាស្ត្រនគរូប-នីយកម្មមួយជាចាំបាច់សម្រាប់ទស្សនវិស័យឆ្នាំ២០៣៥។

៤.២- ភ្នំពេញ-ទីក្រុងប្រកបដោយគុណភាពអន្តរជាតិ

៤.២.១- រាជធានីភ្នំពេញគឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា(មាត្រាទី៦នៃរដ្ឋធម្មនុញ្ញ)

មុខងាររាជធានីរបស់ភ្នំពេញ តម្រូវឱ្យស្របនឹងវត្តមានស្ថាប័នសំខាន់ៗនានាស្ថិតនៅក្នុងភូមិសាស្ត្រនេះរាប់ទាំងស្ថាប័នកំពូលនានារបស់រដ្ឋ អង្គការនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និង...

មុខងារនេះត្រូវបានបញ្ជាក់ដោយវត្តមានរបស់ព្រះបរមរាជវាំង ព្រឹទ្ធសភា រដ្ឋសភា ក្រសួងយុត្តិធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម អគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទីស្តីការនៃគ្រប់ក្រសួង ធនាគារជាតិ សារមន្ទីរជាតិ បណ្ណាល័យជាតិ មជ្ឈមណ្ឌលតម្កល់ឯកសារជាតិ រាជបណ្ឌិត្យសភាកម្ពុជា ពហុកីឡដ្ឋានជាតិអូឡាំពិក រោងមហោស្រពជាតិ ទីស្នាក់ការនៃគ្រឹះស្ថានសាធារណៈនានាដែលមានលក្ខណៈជាតិដូចជា រាជាយស្ម័យយានកម្ពុជា ក្រុមហ៊ុនអគ្គិសនីកម្ពុជា អាជ្ញាធរជាតិប្រេងកាតកម្ពុជា គណៈកម្មាធិការជាតិទន្លេមេគង្គ កាកបាទក្រហមកម្ពុជា អាជ្ញាធរដើម្បីការថែរក្សានិងរៀបចំតំបន់អង្គរ(អប្សរា) ព្រមទាំងតំណាងនៃអង្គការបរទេសនានា តំណាងអង្គទូត (៥២តំណាងបច្ចុប្បន្ននេះ) និងទីភ្នាក់ងារអភិវឌ្ឍរបស់តំណាងអង្គទូតទាំងនេះ (មាន៧សព្វថ្ងៃនេះ) តំណាងអង្គការពហុភាគី: ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី គណៈកម្មការអឺរ៉ុប តំណាងទាំង១៤នៃអង្គការសហប្រជាជាតិ។

ឆ្លើយតបជាមួយមុខងារទាំងនេះ ដែលភ្នំពេញត្រូវតែមានផែនការជាយុទ្ធសាស្ត្រមួយដែលមានកម្រិតខ្ពស់ ក្នុងនោះជាអាទិ៍ទាក់ទងនឹងវិស័យរៀបចំដែនដី ការគ្រប់គ្រងទីក្រុងនិងសន្តិសុខ ព្រមទាំងគុណភាពនៃទីក្រុងក្នុងការបង្ហាញអំពីអត្តសញ្ញាណ ពោលគឺ*រាជធានីភ្នំពេញគឺជាកញ្ចក់ឆ្លុះបញ្ចាំងពីគុណភាពតំណាងឱ្យជាតិទាំងមូល*។

ម្យ៉ាងទៀតក៏មានជាភាពតំណាងមួយធំជាងគេក្នុងវិស័យរដ្ឋបាល និងសេវាសាធារណៈនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន ដែលក្នុងនោះមានសាលារាជធានីភ្នំពេញ រដ្ឋាករទឹកស្វយ័តភ្នំពេញ កំពង់ផែស្វយ័តភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សភាពាណិជ្ជកម្មភ្នំពេញ ក្លឹបពាណិជ្ជកម្មសំខាន់ៗដទៃទៀតនៅក្នុងប្រទេស ដែលមានភាពសកម្មក្នុងវិស័យពាណិជ្ជកម្មដែលមានលក្ខណៈអន្តរជាតិ។

រាជធានីភ្នំពេញប្រមូលផ្តុំមន្ត្រីរាជការជាង ៨៦ ០០០នាក់ ក្នុងនោះ ១/៤ ធ្វើការបម្រើឱ្យសាលារាជធានីភ្នំពេញ សកម្មក្នុងការអភិវឌ្ឍ ការផ្តល់សេវាសាធារណៈ និងជំរុញសកម្មភាពសេដ្ឋកិច្ចដ៏ធំៗ បង្កលក្ខណៈឲ្យវិស័យឯកជនអាចទាញយកគុណប្រយោជន៍យ៉ាងធំធេងពីស្ថានភាពអំណោយផលនេះ ជាក់ស្តែងភ្នំពេញធ្លាប់បានបង្ហាញនូវសមត្ថភាពអាចទទួលភ្ញៀវគណៈប្រតិភូជាតិនិងអន្តរជាតិ ក្នុងឱកាសជំនួបកំពូលនានា និងការប្រជុំទាំងឡាយ (សមាជរបស់អាស៊ានសមាជពិភពលោក ការប្រកួតកីឡានានា ការតាំងពិព័រណ៍អន្តរជាតិនានា ទស្សនីយភាព។ល។

ដោយរាជធានីភ្នំពេញជាមជ្ឈមណ្ឌលនៃអំណាចកំពូលខាងលើទាំងនេះ ទើបនាំឱ្យមានការបោះទីតាំងនៃក្រុមហ៊ុនឯកជនធំៗសំខាន់ៗនានាផងដែរ។ នេះជាតម្រូវការមួយផ្នែកដែលនាំឱ្យមានការចូលចិត្តបោះទីតាំងប្រកបអាជីវកម្មទាំងនេះនៅរាជធានីភ្នំពេញ ពីសំណាក់វិនិយោគិននានា។

វិស័យសេវាកម្មនានា(ទេសចរណ៍ ការបោះពុម្ព មេធាវី ការិយាល័យសិក្សា ស្ថាបត្យករ អ្នកជំនាញការគណនេយ្យ សេវាកម្មសម្រាប់ក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្មការដឹកជញ្ជូន ...) ក៏ត្រូវបានប្រមូលផ្តុំដោយសារវត្តមាននៃអំណាចសាធារណៈនិងឯកជនទាំងនោះ។ ម្យ៉ាងទៀត...

ការងារចំនួន១/៣ របស់ប្រជាជនកម្ពុជាក៏បានប្រមូលផ្តុំនៅភ្នំពេញ ក្នុងចំណោមការងារទាំងនោះ មានការងារនានាដែលគ្រប់គ្រងចំណូលដ៏លើសលប់យ៉ាងច្រើនបំផុត (៥៨%នៃផលិតផលក្នុងស្រុកសរុបរបស់រាជធានីភ្នំពេញគឺត្រូវបានមកពីសកម្មភាពសេវាកម្ម)។

វិស័យទេសចរណ៍ : មានសណ្ឋាគារនិងផ្ទះសំណាក់ចំនួន៥៩៦កន្លែងដែលមានចំនួនបន្ទប់ច្រើនជាង៧ ៥០០បន្ទប់(ដែលក្នុងនោះ មាន១ ២៥០បន្ទប់ស្ថិតនៅក្នុងខ្នាតអន្តរជាតិ) និងភោជនីយដ្ឋានមាន៣៦៤ មូលដ្ឋានដែលធ្វើឱ្យទីក្រុងភ្នំពេញក្លាយជាទីក្រុងទេសចរណ៍ទីមួយរបស់ប្រទេសកម្ពុជា ទោះបីជាសក្តានុពលវប្បធម៌ទេសចរណ៍ និងកម្សាន្តមិនត្រូវបានគេទាញយកផលប្រយោជន៍អស់ក៏ដោយ សណ្ឋាគារថ្មីៗកំពុងត្រូវបានគេសាងសង់ពង្រីក(សណ្ឋាគារណាហ្គា សណ្ឋាគារកាំបូឌីយ៉ាណា សណ្ឋាគារភ្នំពេញ សណ្ឋាគារឡឺរ៉ូយ៉ាល់ សណ្ឋាគារសូហ្វីតែលភូកេត្រា ...។ និងបង្កើតយ៉ាងឆាប់រហ័សនូវសក្តានុពលនៃការទទួលភ្ញៀវគ្រប់ខ្នាតទាំងអស់។

វិស័យអប់រំ : សាកលវិទ្យាល័យសាធារណៈ និងសាកលវិទ្យាល័យឯកជនសំខាន់ៗ បានប្រមូលផ្តុំនៅរាជធានីភ្នំពេញ ជាមួយហេតុផលពិតប្រាកដ និងចាំបាច់ពីការប្រមូលផ្តុំនៃទីតាំងភូមិសាស្ត្រនៃមធ្យោបាយអប់រំនានា ដើម្បីបញ្ចេញឱ្យឃើញនូវការសិក្សាកម្រិតមួយខ្ពស់ និងសេវាកម្មអប់រំប្រកបដោយគុណភាព។ បណ្តានិស្សិតនិងសិស្សវិទ្យាល័យមានចំនួន២១ ០០០នាក់ស្មើនឹង២/៣នៃសិស្សនិស្សិតទាំងនេះ ស្ថិតនៅក្នុងវិស័យអប់រំឯកជន។

ជាមួយវត្តមានរបស់ប្រជាជនរស់នៅអចិន្ត្រៃយ៍១ ២៥០ ០០០នាក់ និងចំនួនប្រជាជនដែលធ្វើបម្លាស់ទីទៅមក ចំនួនប្រហែល២៥០ ០០០នាក់បន្ថែមលើនេះទៀតនោះ ភ្នំពេញបានបង្កើតជាទីផ្សារការប្រើប្រាស់មួយធំជាងគេបំផុតនៅក្នុងប្រទេស ដែលសកម្មភាពពាណិជ្ជកម្មយ៉ាងសកម្ម ក្នុងនោះមានផ្សារប្រហែល៩១(២៥ ០០០ស្តង់) មជ្ឈមណ្ឌលពាណិជ្ជកម្ម និងផ្សារទំនើបចំនួន១២ និងការលក់ដូររាប់ពាន់នៅតាមបណ្តោយផ្លូវនានា។

វិស័យដឹកជញ្ជូនទំនិញនិងអ្នកដំណើរ ក៏មានលក្ខណៈសំខាន់ណាស់ដែរសម្រាប់ឱ្យមានការទទួលជួបជាលក្ខណៈអន្តរជាតិនៅក្នុងភ្នំពេញក្នុងលក្ខខណ្ឌដ៏ប្រសើរ និងអាចឱ្យមានការតភ្ជាប់ នូវបណ្តាញចែកចាយនានាទៅដល់បណ្តាខេត្តក្នុងប្រទេស។ បទពិសោធថ្មីៗ ក្នុងអំឡុងពេលនៃការធ្វើជាប្រធាននៃជំនួបកំពូលអាស៊ានរបស់ប្រទេសកម្ពុជា បានបង្ហាញឱ្យឃើញថារាជធានីភ្នំពេញបានឈានទៅដល់កម្រិតគុណភាពដ៏ខ្ពស់មួយ ក្នុងការទទួលបដិសណ្ឋារកិច្ចនូវពិធីទាំងនេះ។ ការអភិវឌ្ឍនគរូបនីយកម្មនៃរាជធានីជាអាទិ៍ទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធដឹកជញ្ជូន ការធ្វើចរាចរណ៍យានយន្ត អនាម័យបរិស្ថានមិនត្រូវធ្វើឱ្យថយចុះពីកម្រិតគុណភាពជាអន្តរជាតិនេះទេ។

គោលបំណងនៃការអភិវឌ្ឍរាជធានីក៏គឺជាការផ្គុំគ្នារវាងការអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាពបំផុតនៃសុខដុមនីយកម្ម ជាមួយប្រជាជនគ្រប់ស្រទាប់ថ្នាក់រួមទាំងអ្នកក្រីក្រ ជនក្រីក្រ និងលើកកម្ពស់តម្លៃសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន សំដៅឱ្យមានការអភិវឌ្ឍមួយប្រកបដោយចីរភាពដល់អ្នកជំនាន់ក្រោយ។/.

ការសម្រេចចិត្តរបស់រដ្ឋាភិបាល ក្នុងការតម្រង់ទិសឆ្ពោះទៅរកទីប្រជុំជនបន្ទាប់នានានូវកម្លាំងផលិតកម្ម ក្នុងនោះមានជាពិសេសទីក្រុងព្រះសីហនុនិងតំបន់ព្រំដែន ដើម្បីទីផ្សារនាំចេញនឹងអាចឱ្យមានការអភិវឌ្ឍប្រកបដោយសមភាព និងធ្វើឱ្យប្រសើរឡើងនៅក្នុងក្របខ័ណ្ឌនៃការរៀបចំដែនដីដែនដីរបស់ប្រទេសជាតិទាំងមូល ព្រមទាំងអាចឱ្យកម្ពុជាជំរុញនូវគុណសម្បត្តិដែលអាចប្រកួតប្រជែងបានជាមួយប្រទេសដទៃ។ ដូច្នេះ ឧស្សាហកម្មដែលអាចមានទាំងផលិតផលឧស្សាហកម្មធុនធ្ងន់ នឹងមិនត្រូវបោះទៅតាំងនៅរាជធានីភ្នំពេញទេ នៅពេលដែលផលិតផលពីឧស្សាហកម្មទាំងនោះជាគោលដៅសម្រាប់នាំចេញ។ ប៉ុន្តែគួរតែបោះទីតាំងនៅលើក្បែរតំបន់កំពង់ផែសមុទ្រតំបន់ក្បែរព្រំដែនទើបជាការប្រសើរ។

យោងតាមភាពតូចចង្អៀតនៃដែនដីរបស់ភ្នំពេញ និងបញ្ហាប្រឈមនឹងហានិភ័យនានាគួរគប្បីធ្វើពិពិធកម្មកសិកម្មមានការផលិតផលដំណាំបន្លែបង្ការនានា និងការចិញ្ចឹមត្រីសាច់សម្រាប់ចិញ្ចឹមទីក្រុងទាំងមូល និងសម្រាប់នាំចេញ។ ការបម្រុងទុកនូវដីសម្រាប់សកម្មភាពសេដ្ឋកិច្ចសម្រាប់ធានាការធ្វើការបម្រុងទុកនូវផលិតផលសម្រាប់ផ្គត់ផ្គង់ និងការប្រើប្រាស់នានានៅក្នុងរាជធានី មាននៅតំបន់ខ្លះនៃជាយក្រុងភ្នំពេញ តែផលិតផលទាំងនេះមិនទាន់អាចបំពេញតម្រូវការទាំងស្រុងឡើយ។ ការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនៃរាជធានីភ្នំពេញសព្វថ្ងៃបានឈានចូលមកដល់ដំណាក់កាលមួយដែលបរិក្ខារក្រុង មានតម្រូវការកម្រិតខ្ពស់ជាងកាលពីទសវត្សរ៍ឆ្នាំ១៩៧០ក្នុងខណៈដែលប្រជាជនមានចំនួនស្មើគ្នា។ បច្ចុប្បន្ន កំណើនប្រជាជនមានចំនួនប្រហាក់ប្រហែល១ ០០ ០០០នាក់ នៅក្នុងខណ្ឌកណ្តាលក្រុងទាំង៤ បើប្រៀបធៀបនឹងចំនួនប្រហែល៩០០ ០០០នាក់នៅក្នុងខណ្ឌជាយក្រុងទាំង៨ ដូចនេះត្រូវតែបន្តការខិតខំប្រឹងប្រែងថែមទៀត ដើម្បីឱ្យទីក្រុងមានគុណភាពដល់កម្រិតអន្តរជាតិឡើងវិញ ពិសេសត្រូវបង្វែរទិសការកសាងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនានាទៅតំបន់ជាយក្រុង ដែលសព្វថ្ងៃមានចំនួនប្រជាជនច្រើនជាងនៅខណ្ឌកណ្តាលក្រុងទាំង៤ទៅហើយនោះ។

៤.២.២- មុខងារសំខាន់ៗ សម្រាប់រាជធានីភ្នំពេញ

ក្នុងមុខងារដ៏សំខាន់របស់ខ្លួនរាជធានីភ្នំពេញមានតួនាទីជានយោបាយ រដ្ឋបាលកណ្តាល និងជាចំណុចទំនាក់ទំនងជាលក្ខណៈសាកល និងដោយផ្ទាល់ជាមួយនឹងវត្តមាន តំណាងអង្គទូតនានា អង្គការអន្តរជាតិ ហើយនិងទីស្នាក់ការកណ្តាលរបស់សហគ្រាសធំៗ...។ ទន្ទឹមគ្នានេះ រាជធានីភ្នំពេញ បំពេញនាទីជាលក្ខណៈប្រយោលជាចំណុចផ្តុំនៃសេវាកម្មភ័ស្តុភារសម្រាប់ការផ្គត់ផ្គង់ដល់ទីផ្សារក្នុងស្រុក សណ្ឋាគារ និងភោជនីយដ្ឋាន ការបោះពុម្ព ការតំណាងនានា។ មុខងារនេះធានាផ្តល់នូវទីផ្សារការងារមួយផ្នែកធំ និងបង្កើតនូវចំណែកធំមួយនៃផលិតផលក្នុងស្រុកសរុបរបស់ក្រុង ផ្នែកសេវាកម្មដែលបានរួមចំណែកដល់៥៨%ទូទាំងប្រទេស ធ្វើឱ្យអាចឱ្យក្រុងភ្នំពេញមានស្ថិរភាពមួយដែលមានមុខងារមួយច្បាស់លាស់ និងស្ថិរភាពសេដ្ឋកិច្ចមួយចំនួន។ តួនាទីរបស់រាជធានីនេះ ទាមទារនូវគុណភាពសម្រាប់សេវាមួយចំនួនរបស់ទីក្រុង ...

ភាពនៃការគ្រប់គ្រងទីក្រុងទាំងមូល ដែលជាមគ្គុទ្ទេសក៍សម្រាប់ការតម្រង់ទិសទាំងឡាយក្នុងការធ្វើគម្រោងអភិវឌ្ឍន៍។

ដោយសាររាជធានីភ្នំពេញជាមជ្ឈមណ្ឌលនៃក្បាលម៉ាស៊ីនដឹកនាំនយោបាយ ដែលមានប្រព័ន្ធគមនាគមន៍ធំសំខាន់ៗ និងមានបរិក្ខារសាធារណៈច្រើន ធ្វើឱ្យភ្នំពេញមានភាពទាក់ទាញ និងចំណាប់អារម្មណ៍ពីវិនិយោគិនដើម្បីទទួលបានហេដ្ឋារចនាសម្ព័ន្ធគាំទ្រទាំងឡាយសម្រាប់ការវិនិយោគផ្នែកឧស្សាហកម្ម រហូតធ្វើឲ្យមកដល់បច្ចុប្បន្ននេះ ភ្នំពេញក្លាយជាមានភាពឈានមុខជាងគេផ្នែកឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង[4]។ រោងចក្រទាំងឡាយរួមទាំងបណ្តារោងចក្រដែលមានទីតាំងនៅរាជធានីភ្នំពេញ ជាអ្នករួមបង្កើតការងារ បានធ្វើមួយភាគធំនោះ នៅមានលក្ខណៈផុយស្រួយនៅឡើយ ដោយហេតុថារោងចក្រនិងសកម្មភាពផលិតកម្មទាំងនេះ ត្រូវស្ថិតនៅក្រោមបរិបទនៃការប្រកួតប្រជែងអន្តរជាតិដែលការប្រកួតប្រជែងនេះនឹងរីកកាន់តែធំឡើងដោយបាត់ភាពអនុគ្រោះពីប្រទេសទទួលទិញ។ ចំនួនការងារដែលទាក់ទងនឹងមុខងាររបស់រាជធានីទាំងនេះ មិនទាន់គ្រប់គ្រាន់អាចឆ្លើយតបនឹងការកើនឡើងរបស់ប្រជាជនដែលមានប្រមាណ៥០ ០០០នាក់ក្នុង១ឆ្នាំនោះឡើយ។ ដើម្បីធានានូវអត្រាការងារស្របច្បាប់ដ៏ប្រសើរមួយ (ការងារដែលចុះបញ្ជីជាផ្លូវការ) ចាំបាច់ត្រូវតែបង្កើតឡើងនូវគោលនយោបាយមួយនៃការធ្វើពិពិធកម្មនូវមុខងារនានានៃសេដ្ឋកិច្ច ដោយរួមបញ្ចូលនូវការអភិវឌ្ឍវិស័យឧស្សាហកម្មធុនស្រាលនានានិងវិស័យសំណង់។

លើសពីនេះ ត្រូវមានការចាប់អារម្មណ៍ផងដែរ និងត្រូវតែរៀបចំការអភិវឌ្ឍវិស័យទេសចរណ៍ ព្រោះឧស្សាហកម្មទេសចរណ៍គឺជាប្រភពចំណូលមួយនៃសេដ្ឋកិច្ច។ មុខងាររបស់រាជធានីក៏នឹងកាន់តែសំខាន់ឡើងទៀតនៅឱកាសនៃការធ្វើសមាហរណកម្មរបស់ប្រទេសកម្ពុជាទៅក្នុងសមាគមអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក(WTO) ដែលនឹងនាំឱ្យមានសកម្មភាពទេសចរណ៍ជាលក្ខណៈពាណិជ្ជកម្មដ៏សំខាន់មួយ។

ជាមួយនឹងវត្តមានអត្រាច្រើនជាង៥០%នៃបន្ទប់សណ្ឋាគារ៣០%នៃបន្ទប់ផ្ទះសំណាក់និង៦០%នៃទីភ្នាក់ងារនិងក្រុមហ៊ុនទេសចរណ៍របស់ប្រទេសកម្ពុជា រាជធានីភ្នំពេញមានសកម្មភាពទេសចរណ៍យ៉ាងសកម្ម ដែលមានអ្នកស្នាក់នៅ១លាននាក់/ឆ្នាំ គឺប្រហែល២ដងលើសខេត្ត-សៀមរាប។ ចំនួនអត្រាទេសចរណ៍ធុរកិច្ចនៅរាជធានីភ្នំពេញ ក៏បានជះឥទ្ធិពលដល់ការកើនឡើងនៃទេសចរណ៍វប្បធម៌នៅខេត្តសៀមរាបផងដែរ។ សំណង់បេតិកភណ្ឌ រមណីយដ្ឋាន-បុរាណវិទ្យា ទេសភាពទីក្រុង ទេសភាពតាមដងទន្លេវាលឆ្មារ ទន្លេបឹងទាំងឡាយសុទ្ធតែនៅល្អស្អាតនៅឡើយ រួមទាំងរូបភាពទេសភាពល្អនៃជនបទជាយក្រុងដែលមានភាពទាក់ទាញ និងដែលជាតំបន់មិនសូវមានដង់ស៊ីតេប្រជាជនខ្ពស់នោះអាចឱ្យរាជធានីភ្នំពេញមានសក្តានុពលអភិវឌ្ឍន៍ដ៏ធំសម្បើមមួយ។ គួបផ្សំនឹងទេសចរណ៍ធុរកិច្ចដែលទាក់ទងនឹងមុខងាររបស់រាជធានីដែលមានស្រាប់ ក្នុងពេលអនាគត រាជធានីភ្នំពេញនឹងក្លាយជាមុំសេដ្ឋកិច្ច ជាកន្លែងទេសចរណ៍ឆ្លងកាត់មួយរវាងទេសចរណ៍វប្បធម៌នៅអង្គរ និងទេសចរណ៍លម្ហែកាយ និងកម្សាន្តនៅមាត់សមុទ្រ

[4]ឧស្សាហកម្មទាំងនេះមានប្រហែល ៣០% នៃផលិតផលក្នុងស្រុកដុលសរុបរបស់រាជធានីភ្នំពេញ ហើយឧស្សាហកម្មដទៃទៀត មានតិចជាង៥%នៃផលិតផលដុលទៅទៀត។

សមុទ្រ ដែលជាកត្តាធ្វើឱ្យរាជធានីភ្នំពេញត្រូវតែអភិវឌ្ឍនូវគុណសម្បត្តិទេសចរណ៍របស់ខ្លួនទាំងអស់នេះ។ ដូច្នេះ ត្រូវតែមានគោលនយោបាយចាំបាច់មួយដែលទទួលខុសត្រូវក្នុងការការពារ និងលើកតម្កើងតម្លៃបេតិកភណ្ឌស្ថាបត្យកម្មនិងទេសភាព ហើយនិងការការពារលើកតម្កើងបរិយាកាសទីក្រុងដ៏ល្អ។

៤.២.៣- ពង្រឹងគុណសម្បត្តិនៃការទាក់ទាញនិងការប្រកួតប្រជែងរបស់រាជធានីភ្នំពេញ

រាជធានីភ្នំពេញមានគុណសម្បត្តិមួយចំនួនធំ អាចប្រៀបធៀបជាមួយបណ្តាទីក្រុងនានាលើពិភពលោកបានជាអាទិ៍ តម្លៃដីធ្លីនិងតម្លៃពលកម្ម សមត្ថភាពនៃប្រព័ន្ធគមនាគមន៍កម្រិតអន្តរជាតិ[៥]និងទីតាំងភូមិសាស្ត្ររបស់ខ្លួនស្ថិតនៅលើអ័ក្ស និងចំណុចកណ្តាលរវាងទីក្រុងបាងកក-ហូជីមិញ។ ប៉ុន្តែ ចំណុចខ្សោយមួយចំនួនធំត្រូវតែកាត់បន្ថយជាអាទិ៍ការខ្វះសេចក្តីទុកចិត្តពីសំណាក់វិនិយោគិនទាំងឡាយ តម្លៃខ្ពស់នៃថាមពលនានានិងទូរគមនាគមន៍ និងភាពខ្វះខាតនៃកម្លាំងពលកម្មដែលមានជំនាញ និងប្រកបដោយគុណភាព។ ការផ្តល់អាទិភាពរបស់រដ្ឋាភិបាលក្នុងការផលិតភ្លើងអគ្គិសនី (តភ្ជាប់បណ្តាញពីប្រទេសវៀតណាម រោងចក្រអគ្គិសនីថ្មីៗ ការធ្វើឱ្យប្រសើរឡើងនូវបណ្តាញអគ្គិសនី) ការកើនឡើងយ៉ាងឆាប់រហ័សនៃអ្នកប្រើប្រាស់របស់ក្រុមហ៊ុនទូរសព្ទ និងការធ្វើឱ្យប្រសើរឡើងយ៉ាងឆាប់រហ័សនៃបណ្តាញផ្លូវថ្នល់ នឹងអាចកាត់បន្ថយយ៉ាងពិតប្រាកដនូវតម្លៃខ្ពស់ពីក្នុងចំណោមសេវាទាំងនេះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដែលនឹងអាចពង្រឹងដល់ការប្រកួតប្រជែងយ៉ាងឆាប់រហ័សរបស់រាជធានីភ្នំពេញ។ សន្ទុះសេដ្ឋកិច្ចដែលនៅមានភាពផុយស្រួយនៅឡើយ នឹងត្រូវបានពង្រឹងដោយការរៀបចំអភិវឌ្ឍន៍ទីប្រជុំជនក្រុងមួយឱ្យល្អ និងដោយការធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូនដែលមានស្រាប់។

៤.២.៤- តុល្យភាពរវាងអភិក្រមខាងក្នុងនិងអភិក្រមខាងក្រៅ

ការស្ថាបនាទីក្រុងមួយត្រូវបានរៀបចំដោយអភិក្រមពីរប្រភេទ៖

- អភិក្រមខាងក្នុង គឺរាល់សកម្មភាពអភិវឌ្ឍន៍ដែលឆ្លើយតបដោយផ្ទាល់ដល់សេចក្តីត្រូវការចាំបាច់របស់ប្រជាជនក្នុងស្រុកដូចជាលំនៅឋានប្រពៃណី បណ្តាញផ្លូវ មូលដ្ឋានបរិក្ខារ មូលដ្ឋានទីផ្សារនានា...។
- អភិក្រមខាងក្រៅ គឺជាសកម្មភាពអភិវឌ្ឍន៍ឡើងដោយវិនិយោគិនទាំងឡាយជាអាទិ៍ជនបរទេសដែលបង្កើតឡើងនូវផលិតផលពិសេស រួមមានការអភិវឌ្ឍទីក្រុងរណបនានា (ទីក្រុងកោះពេជ្រ ខាំកូ ប្រ៉ែក្តនភ្នំពេញ ទីក្រុងរណបជ្រោយចង្វា ...។ល។ សណ្ឋាគារខ្នាតអន្តរជាតិនានា លំនៅឋានច្រើនជាន់ និងអគារខ្ពស់ៗសម្រាប់ការិយាល័យ ការកសាងពហុកីឡដ្ឋានជាតិនៅភាគខាងជើង (តំបន់អភិវឌ្ឍក្រុមហ៊ុនLYP) ទីលានវាយកូនគោល បរិក្ខារកម្សាន្ត សួនទឹកកម្សាន្ត តំបន់សកម្មភាពនានា សាលារៀនអន្តរជាតិ និងសង្កាត់លំនៅឋាន បុរីដែលមានការយាមកាម ...។

[៥]អាកាសយានដ្ឋានភ្នំពេញ និងច្រកចូលពីរទៀតតាមកប៉ាល់ជាមួយកំពង់ក្រុងព្រះសីហនុនិងភ្នំពេញ។

អភិក្រមទាំងពីរនេះបំពេញឱ្យគ្នាទៅវិញទៅមក និងជាអ្នកបង្កើតនូវភាពរីកចម្រើនសំបូរសប្បាយ និងការងារសម្រាប់ប្រជាជនទីក្រុង ប៉ុន្តែ អភិក្រមទាំងពីរនេះជួនកាលអាចមានការប្រកួតប្រជែងគ្នានៅលើទីតាំងតែមួយដូចគ្នា។ នៅមានភាពប្រថុយប្រថាននៃការទិញដីធ្លីពីសំណាក់វិនិយោគិន ដើម្បីស្តុកទុកកេងយកចំណេញ ដែលអាចឱ្យមានការលំបាកដល់ការឆ្លើយតបនឹងសេចក្តីត្រូវការចាំបាច់នៅមូលដ្ឋានក្នុងការសាងសង់លំនៅឋាន ជាពិសេសសម្រាប់ប្រជាជនដែលក្រីក្រ។

ដើម្បីផ្សារភ្ជាប់នូវអភិក្រមទាំងពីរនេះចូលគ្នា យើងនឹងបង្កើតទីកន្លែងទទួលការសាងសង់ប្រកបដោយការទាក់ទាញសម្រាប់អគារខ្ពស់ៗ នៅក្នុងតំបន់ដែលមានគុណសម្បត្តិល្អ (ផ្លូវធំៗទេសភាពល្អៗនៅជុំវិញបឹងខាងជើង និងតាមបណ្តោយដងទន្លេមេគង្គ ...)។ យើងក៏នឹងធ្វើឱ្យមានការធ្វើវិនិយោគទុនដែលអាចផ្សារភ្ជាប់ការថែរក្សាបេតិកភណ្ឌប្រវត្តិសាស្ត្រ ពោលគឺការអភិវឌ្ឍត្រូវដើរស្របនឹងការអភិរក្ស។

៤.២.៥- ការពង្រីកផ្ទៃដីទីក្រុងធំ(មេត្រូប៉ូលីតែន)និងការកើនឡើងទ្វេដង នៃចំនួនប្រជាជនឆ្នាំ២០៣៥

ផលិតផលក្នុងស្រុកសរុបរាជធានីភ្នំពេញបច្ចុប្បន្នមានប្រហែល៣០% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា គឺលើសពី១,៣៣ាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ការពង្រីកព្រំដែននៃការគ្រប់គ្រងរដ្ឋបាលរបស់ទីក្រុងភ្នំពេញ នឹងត្រូវរាប់បញ្ចូលនូវផ្ទៃដីដែលកាត់ចេញពីខេត្តកណ្តាលផងនោះ នឹងនាំឱ្យមានការថយចុះកម្រិតនៃផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំរបស់រាជធានីភ្នំពេញ ក៏នឹងធ្វើឱ្យមានគម្លាតមួយតិច ជាមួយនឹងផលិតផលក្នុងស្រុកសរុបនៅកន្លែងដទៃទៀតក្នុងប្រទេសកម្ពុជា (រូបភាពទី៥នៃឯកសារឧបសម្ព័ន្ធ)។

ទោះជាផ្ទៃដីសរុបបច្ចុប្បន្នមានចំនួន៦៧៨ ៤១៦គម² (រូបភាពទី៦នៃឯកសារឧបសម្ព័ន្ធ) ក៏ដោយ ក៏ផ្ទៃដីរាជធានីភ្នំពេញនៅមានលក្ខណៈតូចចង្អៀតនៅឡើយ បើប្រៀបធៀបទៅនឹងផ្ទៃដីនៃទីក្រុងធំៗនៅក្នុងតំបន់ដូចជា៖

- **ទីក្រុងហាណូយ** : មានប្រជាជន២,៧លាននាក់លើផ្ទៃក្រឡា៩១៨គីឡូម៉ែត្រក្រឡាក្នុងនោះមានប្រជាជនចំនួន១ ៨៤៦ ០០០នាក់រស់នៅក្នុងទីក្រុង (ទីប្រជុំជន)នៅឆ្នាំ១៩៩៩ គឺលើសប្រជាជនរស់នៅក្នុងរាជធានីភ្នំពេញប្រហែល១/៣ (១ ០៧៨ ០០០នាក់សម្រាប់ទីប្រជុំជននៅលើរាជធានីភ្នំពេញនិងខេត្តកណ្តាល នៅឆ្នាំ១៩៩៨) ក្នុងស្ថានភាពដែលហាណូយមានកំណើនប្រជាជនយឺតជាងនៅរាជធានីភ្នំពេញ (២,២%នៅទីប្រជុំជនហាណូយ រីឯនៅទីក្រុងភំពេញមាន៤,៤) ផ្ទៃដីហាណូយធំជាងផ្ទៃដីរាជធានីភ្នំពេញ ២ដងកន្លះ។
- **ទីក្រុងហូជីមិញ** : មានប្រជាជន៥,៥លាននាក់ (ការប៉ាន់ប្រមាណនៅឆ្នាំ១៩៩៨)នៅលើផ្ទៃដី២,០៩៣គីឡូម៉ែត្រក្រឡាគឺស្មើនឹងប្រជាជននៅរាជធានីភ្នំពេញចំនួន៣ដង ក៏ប៉ុន្តែក៏មានព្រំដែនរដ្ឋបាលធំជាង៤ដងដែរ។

ដើម្បីឱ្យមានមាត្រដ្ឋានដែនដីមួយដូចនឹងទំហំនៃទីក្រុងធំទាំងពីរខាងលើនៅក្នុងតំបន់នេះ យើងអាចពង្រីកព្រំដែនរាជធានីភ្នំពេញ នៅក្នុងរង្វង់ទំហំ៣០គីឡូម៉ែត្រជុំវិញដោយគិតពីចំណុចកណ្តាលនៃរាជធានីភ្នំពេញ។ នៅពេលនោះ ទីក្រុងភ្នំពេញនឹងត្រូវគ្របដណ្តប់លើផ្ទៃដីខាងជើងស្ទើរតែទាំងអស់នៃខេត្តកណ្តាល។

បច្ចុប្បន្ន មានប្រជាជនច្រើនជាង១៥០ ០០០នាក់នៃទីប្រជុំជនក្រុងភ្នំពេញ ដែលរស់នៅខាងក្រៅព្រំដែនរាជធានី ពោលគឺនៅក្នុងខេត្តកណ្តាល ជាពិសេសនៅតាខ្មៅដែលជាផ្លូវចូលភាគខាងត្បូង និងនៅច្រកចូលផ្សេងទៀតតាមបណ្តោយផ្លូវជាតិលេខ១ លេខ៣ លេខ៤ និងលេខ៥។ ចំនួនប្រជាជនដែលធ្វើបម្លាស់ទីទៅមកប្រចាំថ្ងៃចូលភ្នំពេញគឺប្រហែល២៥០ ០០០នាក់ និងពលករដែលមកបំពេញការងារក្នុងរាជធានីភ្នំពេញ មានប្រមាណ៤០០ ០០០នាក់។ ដូច្នេះ ចំនួន"ប្រជាជនរស់នៅជាប្រចាំ"របស់រាជធានីភ្នំពេញមានប្រមាណច្រើនជាង២ ០០០ ០០០នាក់។ ការបោះទីតាំងនៃសកម្មភាពសេដ្ឋកិច្ចនានា ក៏មិនសុទ្ធតែស្ថិតនៅក្នុងព្រំដែនរដ្ឋបាលនៃរាជធានីភ្នំពេញសព្វថ្ងៃនេះដែរ ពោលគឺស្ថិតនៅក្នុងទីក្រុងតាខ្មៅ និងនៅតាមបណ្តោយផ្លូវជាតិលេខ៣និងលេខ៤។ អមផ្លូវជាតិលេខ៤ សព្វថ្ងៃទទួលរោងចក្រជាង៥០នៅក្នុងរយៈចម្ងាយ២០គីឡូម៉ែត្រដែលរាប់ពីព្រំដែនរដ្ឋបាលនៃរាជធានី។

ព្រំដែនរដ្ឋបាលទាំងនេះបង្កបញ្ហាដល់ការគ្រប់គ្រងក្រុងរួចទៅហើយ ឧទាហរណ៍ដូចជាការគ្រូវផ្គត់ផ្គង់ទឹកស្អាតឬការគ្រប់គ្រងកាកសំណល់នៃទីប្រជុំជនក្រុង ដែលលាតសន្ធឹងរហូតដល់ខេត្តកណ្តាល។

វិទ្យាស្ថានជាតិស្ថិតិប៉ាន់ប្រមាណថា ក្រុងភ្នំពេញ នឹងមានប្រជាជនរស់នៅផ្ទាល់ និងអចិន្ត្រៃយ៍ចំនួនប្រហែល១ ៩៨៣ ០៤០នាក់នៅពេលអនាគតឆ្នាំ២០៣៥ ដែលស្របនឹងឆ្នាំនៃទិសដៅប្លង់គោលនេះ។ សាលារាជធានីភ្នំពេញបានធ្វើចំណោលប៉ាន់ស្មានថានឹងមានប្រជាជនប្រហែល២ ២៦៦ ២៨៩នាក់ នៅក្នុងទីប្រជុំជនក្រុងភ្នំពេញ ដោយរាប់បញ្ចូលទាំងប្រជាជននៃឃុំនានាជាប់នឹងទីក្រុងនៃទីប្រជុំជននៅក្នុងខេត្តកណ្តាលផងដែរ ហើយប៉ាន់ប្រមាណថាមានប្រជាជនចំនួន២ ៥៤៤ ៦៥៩នាក់ ដែលនឹងរស់នៅក្នុងទីក្រុងធំទាំងមូលនោះ។ ដូច្នេះ ប្រជាជនពាក់កណ្តាលនៃខេត្តកណ្តាលនឹងត្រូវផ្សារភ្ជាប់ជាមួយនឹងការងារនៅក្នុងទីប្រជុំជនរាជធានីភ្នំពេញសម្រាប់ឆ្នាំគោលដៅនៃគម្រោងប្លង់គោលនេះ ជាមួយនឹងការរីកឡើងនូវផ្ទៃដីទីក្រុងធំមួយ។

នេះជាបញ្ហាប្រឈមសម្រាប់ការចង់បានប្រសិទ្ធភាពនៃការគ្រប់គ្រងដែនដីមួយធំសម្រាប់ការធ្វើគម្រោងផែនការអភិវឌ្ឍន៍ ក៏ដូចជារបៀបរបបគ្រប់គ្រងដែលសមស្របបំផុតមួយដើម្បីឆ្លើយតបនឹងតម្រូវការនៃការអភិវឌ្ឍជារាជធានីភ្នំពេញមួយធំ(Greater Phnom Penh)។

បណ្តាលទ្ធភាពនានាជាច្រើនដែលអាចយកមកវិភាគពិចារណា៖

១- កិច្ចសម្របសម្រួលឲ្យមានភាពស្របគ្នារវាង កំណើន និងការគ្រប់គ្រងសេវាសាធារណៈនីយកម្មនានារវាងសាលារាជធានីភ្នំពេញនិងខេត្តកណ្តាល ដែលមានរចនាសម្ព័ន្ធគ្រប់គ្រងដឹកនាំដ៏សមស្របមួយ ត្រូវបង្កើតឡើងក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។

២- ការបញ្ចូលគ្នារវាងសាលារាជធានីភ្នំពេញ ជាមួយនឹងផ្នែកខាងជើងនៃខេត្តកណ្តាល (២ ០០០គីឡូម៉ែត្រក្រឡា) ឬជាមួយខេត្តកណ្តាលទាំងមូល(៤ ០០០គីឡូម៉ែត្រក្រឡា)ដើម្បីបង្កើតបានជារាជធានីភ្នំពេញធំមួយជាមួយនឹងលក្ខន្តិកៈពិសេសគឺរាជធានី។ រាជធានីនឹងមានស្វយ័តភាពហិរញ្ញវត្ថុមួយយ៉ាងធំដោយរួមបញ្ចូលទាំងការធ្វើវិនិយោគទុន និងលទ្ធភាពនៃការខ្ចីស្វ័យ័តភាពប្រាក់ផងដែរ។ ដំណោះស្រាយដែលមានភាពរលូនបំផុតនេះនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលកណ្តាលដកខ្លួនចេញពីការធ្វើវិនិយោគសាធារណៈនៅរាជធានីភ្នំពេញ ហើយភ្នំពេញអាចរកបាននូវធនធានស្វយ័ត សម្រាប់ការអភិវឌ្ឍរបស់ខ្លួនជាមួយនឹងសារពើពន្ធមូលដ្ឋានទាំងឡាយដែលរាជធានីនឹងគ្រប់គ្រងដោយផ្ទាល់ ហើយក៏អាចមានលទ្ធភាពក្នុងការខ្ចីប្រាក់ដោយផ្ទាល់ពីម្ចាស់ជំនួយអន្តរជាតិនានា។ រាជធានីភ្នំពេញធំនឹងមានសាមគ្គីភាពជាមួយខេត្តដទៃៗទៀតនៅក្នុងប្រទេស តាមរយៈសារពើពន្ធជាតិដែលករណីនេះបានដំណើរការស្រាប់ទៅហើយ។ នេះជាដំណោះស្រាយដែលត្រូវបានគេប្រើប្រាស់ច្រើនបំផុតសម្រាប់ការគ្រប់គ្រងទីក្រុងធំនានា។

៤.២.៦- កម្រិតទីមួយនៃការរៀបចំអភិវឌ្ឍន៍ការធ្វើសមាហរណកម្មទៅក្នុងតំបន់

រាជធានីភ្នំពេញទទួលបានគុណប្រយោជន៍ពីស្ថានភាពទន្លេប្រកបដោយឯកលក្ខណៈ គឺជាចំណុចប្រសព្វនៃទន្លេមេគង្គ ទន្លេសាបនិងទន្លេបាសាក់(ទន្លេចតុមុខ) និងទទួលគុណប្រយោជន៍ពីភាពប្រសព្វគ្នារបស់អ័ក្សសេដ្ឋកិច្ចប្រកបដោយសក្តានុពលនៅលើដែនដីគោក។

- អ័ក្សប្រទេសថៃ-វៀតណាមគឺជាអ័ក្សកណ្តាលស្ថិតនៅចន្លោះអ័ក្សដែលឆ្លងកាត់ពីខាងជើងនៃបឹងទន្លេសាប មកឆ្មេរសមុទ្រភាគនិរតី។ ទីតាំងនៅលើអ័ក្សបាងកក-ហូជីមិញនេះត្រូវបានជានាទូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នានា (ផ្លូវអាស៊ីPanasiatique) ជាមួយនឹងស្ពានអ្នកលឿងមួយដែលត្រូវសាងសង់នៅចម្ងាយ៦០គីឡូម៉ែត្រ(ផ្នែកអាគ្នេយ៍នៃរាជធានីភ្នំពេញ)។ ការបញ្ជាក់ពីការតភ្ជាប់ផ្លូវដែកនានាដែលជាគម្រោងមូលដ្ឋាននៃការតភ្ជាប់ជាមួយប្រទេសវៀតណាមនិងការគ្រោងធ្វើផ្លូវដែកឆ្លងកាត់ទន្លេមួយខ្សែ ប្រហែល ៤០គីឡូម៉ែត្រខាងជើងរាជធានីភ្នំពេញ(គម្រោងនេះមានតម្លៃថ្លៃពេក)។ គម្រោងប្លង់គោលនគរូបនីយកម្ម ត្រូវតែឈរនៅលើផលប្រយោជន៍ក្នុងការបម្រុងទុកនូវលទ្ធភាពឱ្យខ្សែរថភ្លើងថ្មីឆ្លងកាត់តាមរាជធានីភ្នំពេញជាមួយនឹងចម្ងាយផ្លូវមួយជិតជាងនេះពីរដងដែលត្រូវឆ្ពោះទៅកាន់ទីក្រុងហូជីមិញ បើទោះបីជាមានសង្ឃឹមតិចតួចថានឹងអាចធ្វើបានដោយខ្លួនឯងនៅពេលអនាគតនៃគម្រោងប្លង់គោលឆ្នាំ២០៣៥ក៏ដោយ។
- ច្រកអភិវឌ្ឍន៍ចន្លោះរាជធានីភ្នំពេញ-ក្រុងព្រះសីហនុ ជាច្រកសមុទ្រអន្តរជាតិរបស់ប្រទេសកម្ពុជា គឺជាការអភិវឌ្ឍ ដែលស្ថិតក្នុងការរំពឹងទុកថានឹងនាំមកការលូតលាស់នៃសេដ្ឋកិច្ច ដែលការអភិវឌ្ឍនេះពឹងផ្អែកជាពិសេសលើអ័ក្សពីរ គឺបណ្តាញផ្លូវជាតិលេខ ៣និងផ្លូវជាតិលេខ៤ ជាមួយនឹងផ្លូវដែកនៅចន្លោះផ្លូវជាតិទាំង២ ដូចដែល[illegible] ពាណិជ្ជកម្មគ្រោងទុក គឺច្រករបៀងសេដ្ឋកិច្ច(Gross Economic Corridor) [illegible] ភ្នំពេញ-ព្រះសីហនុ (រូបភាពទី៧នៃឯកសារឧបសម្ព័ន្ធ)។

កត្តាសំខាន់នៃការធ្វើប្លង់យុទ្ធសាស្ត្រសម្រាប់រាជធានីភ្នំពេញ គឺជាការរៀបចំអភិវឌ្ឍន៍ និងការគ្រោងទុកលម្ហនៃអ័ក្សផ្លូវថ្នល់មេធំៗទាំងនេះ (ជាពិសេសផ្លូវខ្សែក្រវាត់ក្រុងនានា) និងផ្លូវដែកនៅក្នុងការឆ្លងកាត់តំបន់ទីក្រុងធំៗ និងទំហំនៃការរៀបចំប្លង់អភិវឌ្ឍន៍ស្ថានីយផ្លាស់ប្ដូរទំនិញនិងអ្នកដំណើរជាមួយនឹងបណ្ដាញដឹកជញ្ជូនក្នុងស្រុកនានា តំបន់ផែស្ងួត តំបន់កំពង់ផែ និងស្ថានីយរថភ្លើងនានា។

៤.៣- ការបម្រុងទុកនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្តមេចាំបាច់

ការដឹកជញ្ជូនធុនធ្ងន់ត្រូវបង្វែរមកធ្វើតាមកប៉ាល់នៅតាមទន្លេមេគង្គ និងទន្លេសាប តាមផ្លូវដែកពីទីក្រុងព្រះសីហនុជាចម្បងឬតាមផ្លូវថ្នល់ តែក្នុងករណីដទៃៗទៀតដែលគ្មានមធ្យោបាយជំនួស។ ទីតាំងប្ដូរ ផ្ទុកទំនិញនានា និងរបៀបរបបគ្រប់គ្រងទំនិញគឺជាលទ្ធផលរំពឹងទុកឲ្យមានការផ្លាស់ទីទៅតំបន់ឬទីតាំងនានានៅខាងក្រៅរាជធានីភ្នំពេញ។ ទីតាំងមួយចំនួនសម្រាប់ការប្ដូរទំនិញនានាដែលមានតួនាទីច្រើនយ៉ាងគឺជាចំណុចសំខាន់ ដែលអាចឱ្យយើងមានលទ្ធភាពធ្វើឱ្យប្រសើរឡើងវិញនូវប្រសិទ្ធភាពនៃការដឹកជញ្ជូនដើម្បីធានាឲ្យចែកចាយផលិតផលដល់ទីក្រុងដែលមិនបង្កការរំខាន។ហេដ្ឋារចនាសម្ព័ន្ធធំៗនៅក្នុងទីក្រុងនឹងត្រូវកម្រិតទំហំទៅតាមការរៀបចំ និងគ្រប់គ្រងការហូរចូលនៃទំនិញដែលត្រូវមានការចាត់ចែងនៅជុំវិញទីតាំងទាំងនោះឲ្យបានល្អ។

ការចែកចាយទំនិញនានានៅក្នុងទីក្រុងធំមួយ ដែលមានប្រជាជនរស់នៅប្រហែល៣លាននាក់តម្រូវឱ្យមានការដាក់ឱ្យប្រើប្រាស់នូវមធ្យោបាយភ័ស្ដុភារនិងសមត្ថភាពនៃហេដ្ឋារចនាសម្ព័ន្ធក្នុងកម្រិតមួយដ៏ធំ ដែលជាគម្រោងអាទិភាពនៃការធ្វើវិនិយោគសាធារណៈនាពេលអនាគតជាមួយការពឹងផ្អែកលើការគាំទ្រពីវិស័យឯកជន។

៤.៣.១- បណ្ដាញផ្លូវជាតិ : ជាផ្លូវខ្សែក្រវាត់ព័ទ្ធជុំវិញទីក្រុងដ៏ធំ

ផ្លូវក្រវាត់ព័ទ្ធជុំវិញរាជធានីភ្នំពេញដ៏ធំនានាត្រូវបានស្នើឡើង ដែលមួយផ្នែកធំគឺជាផ្លូវក្រវាត់ដែលមានស្រាប់នាពេលបច្ចុប្បន្ននេះ។ ជាមួយនឹងស្ពានដែលបានស្ថាបនារួចឆ្លងកាត់ទន្លេបាសាក់នៅតាខ្មៅ និងគម្រោងផ្លូវខ្សែក្រវាត់ក្រុងធំដទៃទៀតដែលគ្រោងដោយក្រសួងសាធារណៈការនិងដឹកជញ្ជូននឹងអនុញ្ញាតឱ្យមានការតភ្ជាប់ទំនាក់ទំនងគ្នានៃបណ្ដាញផ្លូវជាតិទាំងមូលដែលត្រូវមកជួបគ្នានៅរាជធានីភ្នំពេញ។

៤.៣.២- ការបោះទីតាំងនៃកំពង់ផែទាំងឡាយ : ការរក្សាទុកកំពង់ផែនៅក្នុងទីក្រុង

ការធ្វើចរាចរណ៍ទំនិញរបស់កំពង់ផែភ្នំពេញមិនមានការប្រែប្រួលទេគឺ ប្រមាណ៥០០ ០០០តោនក្នុងមួយឆ្នាំ ក្នុងនោះ៤០០ ០០០តោន ជាផលិតផលប្រេងចាប់តាំងពីប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការបង្កើតនូវគ្រឹះស្ថានសាធារណៈនៃកំពង់ផែស្វយ័តភ្នំពេញ អាចឱ្យមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃសកម្មភាពកំពង់ផែក្នុងក្រុង។ យើងត្រូវបំពេញបន្ថែមកំពង់ផែដែលមាន[illegible]

សព្វថ្ងៃនេះនៅលើទន្លេសាប ដោយបង្កើតនូវទីតាំងសម្រាប់ផ្ទេរទំនិញ ដោយសង្ឃឹមឱ្យមានការបោះទីតាំងជាកំពង់ផែនានា និងការបញ្ចូលកំពង់ផែទាំងនោះឱ្យស្ថិតនៅក្នុងភូមិសាស្ត្រទីក្រុង (ជាអាទិ៍ការរក្សាទុកដីស្ថិតនៅក្បែរទន្លេ) ត្រូវគ្រប់គ្រងហានិភ័យបរិស្ថានទាំងឡាយ (ជាអាទិ៍ឃ្លាំងផ្ទុកប្រេងនានានៅគីឡូម៉ែត្រលេខ៤) ដើម្បីឱ្យមានដំណើរការកំពង់ផែល្អ ត្រូវគ្រោងនូវលទ្ធភាពនៃការបង្កើតនូវទីតាំង (សកម្មភាព) សម្រាប់ផ្ទេរផ្ទុកទំនិញដែលអាចមានទំហំខ្នាតអន្តរជាតិនៅខាងចុងផ្នែកខាងជើងនៃផ្លូវដែកដែលមានស្រាប់នៅគីឡូម៉ែត្រលេខ៦[6]។

ការបង្កើតកំពង់ផែថ្មីមួយនៅលើទន្លេមេគង្គខាងត្បូងទីក្រុង (ស្រុកកៀនស្វាយ)មិនត្រឹមតែប្រើប្រាស់សម្រាប់រយៈពេលមធ្យមនោះ ឬសម្រាប់បម្រុងទុកនៃកំណើនឡើងនៃចរាចរណ៍ផ្លូវទឹកសម្រាប់បម្រើឱ្យចរាចរណ៍នៃការដឹកជញ្ជូនកុងតឺន័រជាមួយប្រទេសវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវបានគ្រោងដើម្បីរក្សាទុកនូវលទ្ធភាពក្នុងការធ្វើបម្លាស់ទីនៃឃ្លាំងប្រេងនានាដែលមានទីតាំងនៅលើទន្លេសាបឱ្យទៅកាន់ផ្នែកខាងក្រោមនៃទន្លេមេគង្គ ដោយហេតុផលបរិស្ថាននិងហេតុផលហានិភ័យធំៗដទៃទៀត។ ការធ្វើការរើទីតាំងនេះ នឹងត្រូវផ្សារភ្ជាប់នឹងការបង្កើតឡើងនូវខ្សែផ្លូវដែកមួយ ដែលឆ្លងកាត់តំបន់ជាយក្រុងខាងត្បូងនៃរាជធានីភ្នំពេញទៅកាន់ផ្លូវជាតិលេខ១។

កំពង់ផែក្រុងព្រះសីហនុ ដែលមានទំហំធំជាងកំពង់ផែភ្នំពេញ៣ដងនោះនឹងស្ថិតនៅជាច្រកចូលដ៏សំខាន់បំផុតសម្រាប់ទទួលយកការដឹកជញ្ជូន និងស្តុកទំនិញដែលត្រូវចែកចាយក្នុងប្រទេស។ ការដឹកជញ្ជូនផ្លូវទឹកជាការបំពេញបន្ថែមមួយដែលជាគុណប្រយោជន៍មួយដ៏ធំ ហើយការដឹកជញ្ជូនផ្លូវទឹកនេះមានហេតុផលសេដ្ឋកិច្ចសម្រាប់ការឆ្លងកាត់រាជធានីភ្នំពេញ (រូបភាពទី៨នៃឯកសារឧបសម្ព័ន្ធ)។ វាក៏បង្ហាញផងដែរនូវគុណសម្បត្តិក្នុងការរក្សានូវការប្រកួតប្រជែងដ៏សមស្របជាមួយនឹងប្រភេទនៃការដឹកជញ្ជូនដទៃទៀតចូលមកទីក្រុង។ ការតាំងទីនៅជិតទីផ្សារនៃការដឹកជញ្ជូនគឺជាហេតុផលដ៏សំខាន់មួយ ដែលត្រូវរក្សាទុកនូវទីតាំងដីសម្រាប់ការរៀបចំជាកំពង់ផែនៅក្នុងតំបន់កណ្តាល។ ដោយចម្ងាយផ្លូវជាតិរវាងភ្នំពេញនិងច្រកចុងបំផុតនៃទន្លេមេគង្គមានប្រវែងខ្លី កំពង់ផែថ្មីមួយដែលកសាងនៅឆ្ងាយបន្តិចពីរាជធានីភ្នំពេញនឹងមានការធ្លាក់ចុះនៃការស្តុកនិងដឹកជញ្ជូនទំនិញបន្ថែមទៀត និងដែលនឹងនាំឱ្យការដឹកជញ្ជូនផ្លូវទឹកតាមដងទន្លេចុះខ្សោយប្រៀបធៀបនឹងការដឹកជញ្ជូនតាមផ្លូវគោក។

សកម្មភាពនៃការដឹកជញ្ជូន និងការធ្វើដំណើរទៅមករវាងរាជធានីភ្នំពេញ និងទីរួមខេត្តនានាតាមបឹងទន្លេសាប ត្រូវតែធ្វើការអភិវឌ្ឍបន្ថែមនូវប្រព័ន្ធដឹកជញ្ជូន ក៏ដូចជាការកែលម្អស្ថានភាពដឹកជញ្ជូនរបស់កប៉ាល់ទាំងនេះ គួរតែធ្វើឱ្យបានប្រសើរឡើងជាងពេលបច្ចុប្បន្ន។

៤.៣.៣- បណ្តាញផ្លូវដែក : ការស្តារឡើងវិញនូវបណ្តាញផ្លូវដែកដែលមានស្រាប់និងស្ថានីយរថភ្លើងថ្មីមួយនៅផ្នែកខាងលិចទីក្រុង

ការស្តារឡើងវិញនូវចម្ងាយផ្លូវ៦០០គីឡូម៉ែត្រនៃបណ្តាញផ្លូវដែក (ការតភ្ជាប់ទៅកាន់ទីក្រុងព្រះសីហនុ និងទៅកាន់ព្រំដែនថៃ) គឺចាំបាច់ណាស់ដើម្បីធានានូវសន្តិសុខនៃ...

---

[6]រឿងនេះនឹងអាចឱ្យតភ្ជាប់ទៅនឹងតំបន់កស្តុភារមួយដ៏ធំ ដែលការបង្កើតតំបន់នេះត្រូវបានស្នើឡើងនៅទិសខាងលិច នៃទីប្រជុំជនក្រុង។

និងល្បឿនពាណិជ្ជកម្មមួយឱ្យប្រសើរជាងមុន (រូបភាពទី៩នៃឯកសារឧបសម្ព័ន្ធ)។ ការដឹកជញ្ជូនទំនិញតាមរថភ្លើង ដែលជាការដឹកជញ្ជូនបន្ថែមលើការដឹកជញ្ជូនតាមផ្លូវថ្នល់ នឹងជាការចាំបាច់ណាស់សម្រាប់សេដ្ឋកិច្ចប្រទេសជាតិ ហើយក៏អាចបន្ថយនូវទម្ងន់ដល់បណ្តាញផ្លូវថ្នល់ផងដែរ ដែលត្រូវទ្រុឌទ្រោមខូចខាតជាអចិន្ត្រៃយ៍ ដោយចរាចរណ៍នៃរថយន្តធំៗទាំងឡាយ ដែលផ្ទុកហួសទម្ងន់។

នៅរាជធានីភ្នំពេញ ការបង្កើតឡើងនូវស្ថានីយរថភ្លើងមួយថ្មីនៅចំណុចប្រសព្វនៃបណ្តាញដែលមានស្រាប់នៅច្រកចូលខាងលិចនៃទីប្រជុំជន(ស្ថានីយសំរោង)ត្រូវតែគ្រោងឡើង។ ការថែរក្សានូវមុខងាររបស់ស្ថានីយរថភ្លើងសព្វថ្ងៃ នៅកណ្តាលក្រុងជាមួយនឹងមុខងារជាស្ថានីយចុងបញ្ចប់នៃអ្នកធ្វើដំណើរ នឹងអាចបញ្ជូនទំនិញទាំងឡាយសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុករបស់ក្រុងភ្នំពេញ។ ក្រៅពីមុខងារជាសេវាដឹកជញ្ជូនសម្រាប់ប្រទេស បណ្តាញផ្លូវដែកនៅតំបន់កណ្តាលក្រុងភ្នំពេញ អាចក្លាយជាស្ថានីយខ្នាតតូចសម្រាប់ការដឹកជញ្ជូនសាធារណៈនៅក្នុងក្រុងដោយគ្រាន់តែធ្វើការវិនិយោគជាអប្បបរមាមួយប៉ុណ្ណោះ។

ខ្សែផ្លូវដែកដែលត្រូវភ្ជាប់រវាងរាជធានីភ្នំពេញនិងទីក្រុងហូជីមិញអាចនឹងមានសារៈសំខាន់ដូចជាអ័ក្សអភិវឌ្ឍន៍រវាងទីក្រុងធំទាំងពីរសម្រាប់ការធ្វើចរាចរណ៍របស់អ្នកដំណើរ។ការដឹកជញ្ជូនទំនិញតាមផ្លូវដែកនឹងក្លាយជាតម្រូវការចាំបាច់ដោយសារការកើនឡើងនៃការធ្វើចរាចរនៅលើផ្លូវជាតិលេខ១ដែលនឹងនាំឱ្យមានការទ្រុឌទ្រោមខូចខាតយ៉ាងឆាប់រហ័សដោយយានយន្តធុនធ្ងន់។ ខ្សែផ្លូវដែកដែលគ្រោងធ្វើតាមខេត្តកំពង់ចាមនិងឡុកនិញ (ប្រទេសវៀតណាម) ឬដោយកាត់តាមក្រោលគោ ព្រៃវែង ឆ្លើយតបនឹងអ័ក្សអភិវឌ្ឍន៍ដ៏មានសារៈសំខាន់មួយក្នុងកម្រិតជាតិ ប៉ុន្តែមិនអាចផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ចខ្ពស់សម្រាប់រាជធានីភ្នំពេញនិងខេត្តក្បែរៗនោះទេ។ ផ្លូវវាងកាត់តាមឡុកនិញមុននឹងទៅដល់ទីក្រុងហូជីមិញមានចម្ងាយ ៩៨០គីឡូម៉ែត្រ បើប្រៀបធៀបនឹងចម្ងាយ២៣០គីឡូម៉ែត្រតាមផ្លូវថ្នល់គឺលើសពីរដង នេះនឹងមានការប៉ះពាល់នឹងតម្លៃនៃការដឹកជញ្ជូនទំនិញ និងបញ្ហាទាក់ទងនឹងពេលវេលានៃការដឹកជញ្ជូនអ្នកដំណើរ។ ដូច្នេះ ផ្លូវជាតិលេខ១នឹងនៅតែជាមធ្យោបាយផ្លូវគោកតែមួយគត់ និងប្រកបដោយប្រសិទ្ធភាពសម្រាប់ភ្ជាប់ទីក្រុងទាំងពីរ។

ជាការចាំបាច់បំផុតក្នុងរយៈពេលដ៏ខ្លី ក្នុងការបង្កើតនូវទំនាក់ទំនងផ្លូវគោកថ្មី ហើយមានតែផ្លូវដែកតែមួយគត់ដែលនឹងអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការដ៏សម្បើមនេះនាពេលអនាគត។

៤.៣.៤- អាកាសយានដ្ឋានសព្វថ្ងៃអាចឆ្លើយតបសេចក្តីត្រូវការរហូតដល់ត្រឹមឆ្នាំ២០២០

សេវាកម្មតាមផ្លូវអាកាស គឺជាការតភ្ជាប់ជាមួយនឹងការហោះហើររបស់ពិភពលោកទាំងមូលដែលសេវានេះមានសារៈសំខាន់ណាស់សម្រាប់រាជធានីភ្នំពេញ។ ក៏ប៉ុន្តែទីផ្សារនៃការហោះហើរក្នុងស្រុកដែលនៅមានកម្រិតនៅឡើយ និងអវត្តមាននៃក្រុមហ៊ុនអាកាសចរណ៍ដែលចាប់ផ្តើមវិនិយោគទ្រង់ទ្រាយធំមិនអាចឱ្យអាកាសយានដ្ឋាននេះ មានមុខងារផ្សេងទៀតក្រៅពីជាទីបញ្ចប់ចុងក្រោយបំផុតនៃបណ្តាញហោះហើរអន្តរជាតិ ដែលនឹងត្រូវឆ្លងកាត់តាមអាកាសយានដ្ឋានផ្សេង

សំខាន់ៗ នៅក្នុងតំបន់ដូចអាកាសយានដ្ឋានទីក្រុងបាងកក សិង្ហបុរី ហុងកុង(រូបភាពទី១០ នៃឯកសារឧបសម្ព័ន្ធ)។ល។ ដែលអាកាសយានដ្ឋានទាំងនេះទទួលនូវការហោះហើរ៣០ដង ច្រើនជាងនៅរាជធានីភ្នំពេញ។

បរិក្ខាររបស់អាកាសយានដ្ឋានសព្វថ្ងៃនេះអាចមានលទ្ធភាពទទួលនូវការហោះហើរច្រើនជាងនេះ ជាងការគ្រោងទុកទៅទៀតក្នុងរយៈពេលមធ្យមនិងវែង[៣]។

ដូច្នេះ ការសាងសង់នូវអាកាសយានដ្ឋានថ្មីមួយ ដែលជាការវិនិយោគមួយមានតម្លៃថ្លៃរហូតដល់ជាង៣០០លានដុល្លារអាមេរិកនោះ ហាក់មិនទាន់ស្ថិតនៅក្នុងភាពចាំបាច់ក្នុងទស្សនវិស័យនៃយុទ្ធសាស្ត្រតម្រង់ទិសនេះនៅឡើយទេ។ ជាងនេះទៀត ការស្ថិតនៅជិតទីក្រុង គឺជាគុណសម្បត្តិគួរបានយកចិត្តទុកដាក់របស់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក៏ដូចជាអាកាសយានដ្ឋានដទៃៗទៀតដែរ ដែលអាចទទួលការធ្វើចរាចរណ៍ផ្លូវអាកាសច្រើនជាងនេះទៀត។ ក្នុងនោះយើងអាចធ្វើការប្រៀបធៀបអាកាសយានដ្ឋានអ៊ិកលី (Orly) ដែលមានអ្នកធ្វើដំណើរ ២៥លាននាក់សម្រាប់ទីក្រុងប៉ារីស និងអាកាសយានដ្ឋានលីណាត (Linate) សម្រាប់ទីក្រុងមីឡង់ (Milan) ដែលជាអាកាសយានដ្ឋានរបស់ក្រុងទាំងពីរនេះគួរជាទីពេញចិត្តពីសំណាក់ក្រុមហ៊ុនអាកាសចរណ៍និងអ្នកធ្វើដំណើរ ជាងអាកាសយានដ្ឋានសាលដឺហ្គោល (Charles de Gaulle)និងម៉ាល់ប៉ង់សា (Malpensa) ដែលស្ថិតនៅឆ្ងាយពីទីក្រុងជាងនេះ។ បទពិសោធនៅទីក្រុងកូឡាឡាំពួរ ដែលបានធ្វើអាកាសយានដ្ឋានថ្មីមួយរបស់ខ្លួននៅចម្ងាយ៧៥គីឡូម៉ែត្រពីទីក្រុងនោះ វាហាក់ដូចជាការយល់ច្រឡំផ្នែកសេដ្ឋកិច្ចមួយ(រយៈពេលនិងតម្លៃក្នុងការបម្លាស់ទីកើនខ្ពស់)ដែលគួរឱ្យមានការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធដែលមានតម្លៃដ៏ថ្លៃ(ផ្លូវហាយវេ រថភ្លើងលឿន) សម្រាប់ឱ្យអាកាសយានដ្ឋាននេះមានដំណើរការបាន។ គំរូនេះមិនអាចធ្វើបានទេនៅរាជធានីភ្នំពេញ ដោយយោងទៅតាមធនធានរបស់រដ្ឋនិងអាទិភាពនានារបស់រាជរដ្ឋាភិបាល។

ផ្ទុយទៅវិញ ការពង្រីកបន្តនៃផ្លូវចុះចត សម្រាប់ការធ្វើចរាចរណ៍នៃការហោះហើរដឹកទំនិញ និងអនុញ្ញាតឱ្យយន្តហោះដឹកទំនិញធុនធ្ងន់ហោះហើរបាននោះ(A-៣៨០ឬ ប៊ូអ៊ីងB៧៤៧) គួរតែធ្វើឱ្យបានឆាប់រហ័សបំផុត ដើម្បីបន្ថយនូវតម្លៃដែលទាក់ទងនឹងការធ្វើអស្សាមិករណ៍កម្មសិទ្ធិដីធ្លី។ តម្លៃសរុបបន្ទុករបស់រដ្ឋសម្រាប់ការបន្តពង្រីកផ្លូវចុះចតនេះត្រូវបានប៉ាន់ប្រមាណថាមានប្រហែល៣០លានដុល្លារអាមេរិក។ ការរៀបចំបន្ថែមផ្លូវចុះចតនឹងត្រូវជាបន្ទុករបស់ក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន។ បើគិតពីការទទួលយន្តហោះធុនធំៗ ព្រមទាំងពន្ធរំពឹងទុកដទៃទៀត(ពន្ធអ្នកដំណើរ ពន្ធយន្តហោះ ពន្ធតម្លៃបន្ថែម) ការវិនិយោគទាំងនេះមិនគួរជាបន្ទុករបស់រដ្ឋទេ។/

---

[៣]ការធ្វើចរាចរណ៍នៅអាកាសយានដ្ឋាន គឺមានអ្នកធ្វើដំណើរជិតពី១លាននាក់ក្នុងមួយឆ្នាំ។ ជាមួយនឹងកំណើននៃការធ្វើចរាចរណ៍ពី៥%ទៅ៧% ក្នុង១ឆ្នាំ ការហោះហើរនឹងកើនឡើងទ្វេដងនៅក្នុងរយៈ១៥ទៅ២០ឆ្នាំ។ សមត្ថភាពនៃការតាំងទីលំនៅដែលថ្មីៗបានស្តារឡើងវិញ(វិនិយោគអស់ទឹកប្រាក់៣៥លានដុល្លារអាមេរិក) អាចទទួលអ្នកដំណើរយ៉ាងហោចណាស់៥លាននាក់។ ដូចនេះ គឺវាគ្រប់គ្រាន់ណាស់ទៅហើយ ... សម្រាប់ពេលវែងក៏ដោយ។ ជាងនេះទៅទៀត យើងគិតពិចារណាទៅលើភាពចាំបាច់នៃការបន្តបន្ថែមផ្លូវចុះចតចំនួន៣០០ម៉ែត្រ ដោយសារតែការវិវត្តនៃបច្ចេកវិទ្យា នឹងអាចឱ្យពង្រីកប្រភេទយន្តហោះនានា ដែលនឹងអាចត្រូវទទួល។ ការពង្រីកបន្តនេះ រដ្ឋនឹងប្រើប្រាស់ថវិកា ប្រមាណ៣០លានដុល្លារអាមេរិក (ការដកកម្មសិទ្ធិពីជាង៥០០គ្រួសារ ទីតាំង៥០ហិកតាបម្លាស់ទីផ្លូវថ្នល់នានា។

ទីតាំងអាកាសយានដ្ឋានសព្វថ្ងៃ គឺជាគុណសម្បត្តិដែលអាចប្រកួតប្រជែងបានបើប្រៀបធៀបនឹងអាកាសយានដ្ឋាននៃទីក្រុងធំៗនានាក្នុងតំបន់ លើកលែងតែអាកាសយានដ្ឋាននៅហុងកុងវិញ។ ជាការពិត អាកាសយានដ្ឋាននៅជិតក្រុងបានកាត់បន្ថយនូវរយៈពេលធ្វើដំណើរនិងតម្លៃនៃការធ្វើដំណើរពីព្រលានយន្តហោះ មកកន្លែងដែលមានសកម្មភាពនិងមកកន្លែងដែលមានអំណាចសម្រេចចិត្តទាំងឡាយក្នុងក្រុង។ ក៏ប៉ុន្តែគុណសម្បត្តិដែលអាចផ្គូផ្គងជាមួយគេនោះនឹងអាចថយចុះវិញយ៉ាងឆាប់រហ័ស ប្រសិនបើទំនាក់ទំនងរវាងព្រលានយន្តហោះនិងទីក្រុងត្រូវបានពន្យឺតដោយចរាចរណ៍ដែលមិនសមស្របមួយ។ ដូច្នេះ វាជារឿងអាទិភាពក្នុងការពង្រីកផ្លូវនានាដែលមានស្រាប់រហូតដល់កណ្តាលរាជធានីភ្នំពេញនិងគិតទុកជាមុននូវប្រព័ន្ធប្រទាក់ក្រឡានៃមហាវិថីនានានៅខាងជើងនិងខាងត្បូងនៃអាកាសយានដ្ឋាន ដែលនឹងអាចផ្តល់នូវឱកាសជាច្រើនដល់ការធ្វើដំណើរចូលមកកណ្តាលក្រុង។

នៅក្នុងករណីរាជធានីភ្នំពេញ បើទោះបីជាមានការធានារក្សាទុកអាកាសយានដ្ឋាននៅក្នុងទីតាំងរបស់វាសព្វថ្ងៃ ក៏អាកាសយានដ្ឋាននេះអាចទ្រទ្រង់ប្រតិបត្តិការបានត្រឹមកម្រិតរហូតឆ្នាំ២០៣៥។ ដូច្នេះ បន្ទាប់ពីឆ្នាំ២០៣៥អាជ្ញាធរអាកាសចរណ៍ស៊ីវិលត្រូវតែសិក្សារៀបចំឱ្យមានអាកាសយានដ្ឋានថ្មីធំមួយទៀតដែលអាចឆ្លើយតបតម្រូវការនាពេលអនាគត។

៤.៣.៥- យ៉ាងហោចណាស់ ត្រូវមានទីកន្លែងផែស្ងួតមួយដែលមានអន្តរត្តនាទី

ការបង្កើតឡើងនូវទីផែស្ងួតនានានៅជាយខ្លះរាជធានីភ្នំពេញ[៨] គឺមានភាពចាំបាច់ណាស់សម្រាប់រក្សាបាននូវស្ថានភាពដ៏ល្អប្រសើរមួយក្នុងការទប់ស្កាត់ការហូរចូលនៃទំនិញនានាមកក្នុងទីកណ្តាលក្រុងដោយមធ្យោបាយដឹកជញ្ជូនធំៗដោយផ្ទាល់។ នៅក្នុងបរិការណ៍សេដ្ឋកិច្ចសព្វថ្ងៃ មុខងារភ័ស្តុភារមួយចំនួនមិនមានភាពសមស្របនឹងផលិតផលជាក់ស្តែងរបស់សេដ្ឋកិច្ច ពោលគឺមិនស្របនឹងលំហូរមុខទំនិញដែលឆ្លងកាត់ទីភ័ស្តុភារទាំងនោះ ដែលជាទូទៅទីកន្លែងភ័ស្តុភារមួយនឹងអាចប្រមូលផ្តុំនូវមធ្យោបាយទាំងឡាយ(គយ សន្តិសុខ សេវាកម្មផ្សេងៗ ...) និងអាចផ្តល់នូវសេវាកម្មកម្រិតខ្ពស់មួយនិងមានសមត្ថភាពទទួលឲ្យក្រុមហ៊ុនសហគ្រាសនានានៅរាជធានីភ្នំពេញនិងនៅប្រទេសកម្ពុជាចូលប្រើប្រាស់បាន។ ក្នុងន័យនេះ ទីកន្លែងដ៏គួរឱ្យចាប់អារម្មណ៍បំផុតនោះគឺជាកន្លែងដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងស្ថានីយរថភ្លើងថ្មី ដែលត្រូវបានស្នើកសាងឡើងនៅច្រកចូលខាងលិចនៃរាជធានីភ្នំពេញ (ស្ថានីយសំរោង) តំបន់នេះត្រូវឆ្លងកាត់ដោយផ្លូវក្រវាត់ក្រុង ដែលតភ្ជាប់បណ្តាញផ្លូវជាតិទាំងអស់ ដែលរួមផ្តុំចូលគ្នានៅរាជធានីភ្នំពេញ។ ដូច្នេះ តំបន់នេះអាចមានលក្ខណៈងាយស្រួលដោយមានផ្លូវដែលមានអន្តរត្តនាទីរវាងផ្លូវថ្នល់និងផ្លូវដែក ព្រមទាំងស្ថិតនៅជិតអាកាសយានដ្ឋាន ហើយដែលអាចត្រូវតភ្ជាប់ដោយផ្លូវដែកទៅទីតាំងកំពង់ផែក្រុងព្រះសីហនុទៀតផង។

[៨]ប្រហែលមានទំហំពី៥០ទៅ១០០ហិកតា។

៤.៤- ការរៀបចំការអភិវឌ្ឍនគរូបនីយកម្មក្នុងកម្រិតទីក្រុងធំ

នៅក្នុងចំណុចនេះ យើងនឹងមិនលើកយកបញ្ហាផ្ទៃប្លង់ប្រើប្រាស់ដីធ្លី និងដង់ស៊ីតេមកនិយាយទេ ព្រោះបញ្ហានេះនឹងជាកម្មវត្ថុនៃការសិក្សាឱ្យបានស៊ីជម្រៅជាងនេះទៀតនៅពេលក្រោយ។ ក៏ប៉ុន្តែ មានបញ្ហាធំៗមួយចំនួននឹងអាចលើកយកមកនិយាយជាមុននៅក្នុងការរៀបចំគម្រោងប្លង់គោល ដោយឈរលើដំណោះស្រាយជាគោលការណ៍សមស្របនានា។

៤.៤.១- ភាពបន្ទាន់ក្នុងការកំណត់នូវបណ្តាញលម្ហសាធារណៈ

ការអភិវឌ្ឍនគរូបនីយកម្មរាជធានីភ្នំពេញ ត្រូវបានរៀបចំអនុវត្តរហូតមកដល់ត្រឹមចុងទសវត្សរ៍ឆ្នាំ១៩៦០ នៅក្នុងភូមិសាស្ត្រខណ្ឌកណ្តាលក្រុងទាំង៤ ព្រមជាមួយនឹងមានការពង្រីកតាមបណ្តោយផ្លូវនៃច្រកចូលទីក្រុងនៅភាគខាងជើងនិងខាងត្បូង និងទៅកាន់អាកាសយានដ្ឋាននៅភាគខាងលិច។ ដោយការអភិវឌ្ឍទីក្រុងស្ទើរគ្មានសកម្មភាពអស់រយៈជាងដប់ឆ្នាំ នៅពេលដែលប្រទេសជួបវិបត្តិសង្គ្រាមស៊ីវិលនិងអសន្តិសុខ(ពី១៩៧០-១៩៧៩) រួមទាំងការហ៊ុមព័ទ្ធសេដ្ឋកិច្ចនៅទសវត្សរ៍ឆ្នាំ១៩៨០ ហើយបន្ទាប់មកការវិវឌ្ឍដោយខ្លួនឯងតាមរយៈការវិនិយោគដែលគ្មានផែនការច្បាស់លាស់បានកើនឡើងជាបន្តបន្ទាប់។ ទាំងអស់នេះរាចនឹងនាំឱ្យមាននូវហានិភ័យទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងបញ្ហាការបង្កើតបណ្តាញហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនក្នុងទីក្រុងនាពេលអនាគត។ ដូច្នេះហើយដោយមិនរង់ចាំការអនុម័តនូវគម្រោងប្លង់គោលថ្មីជាផ្លូវការ សាលារាជធានីចាំបាច់ត្រូវតែរកឱ្យឃើញនូវកុងសង់ស៊ុសមួយសម្រាប់រៀបចំបណ្តាញនៃលម្ហសាធារណៈ ដោយត្រូវតែរក្សាទុកដីធ្លីដើម្បីធានាឱ្យបាននូវការរៀបចំអភិវឌ្ឍនគរូបនីយកម្មរាជធានីភ្នំពេញមួយឱ្យស្រស់បំព្រង។ បណ្តាញនេះគឺជាការបញ្ចូលគ្នារវាងបណ្តាញផ្លូវសំខាន់ៗ និងបណ្តាញពណ៌បៃតងនិងពណ៌ខៀវ ជាអាទ៍បឹងនិងប្រឡាយនានាដែលត្រូវថែរក្សាទុក (រូបភាពទី១១នៃឯកសារឧបសម្ព័ន្ធ)។

៤.៤.២- បណ្តាញផ្លូវតាមកម្រិតថ្នាក់

គំនូសបណ្តាញផ្លូវមេមានបួនកម្រិតត្រូវបានស្នើឡើង។ កម្រិតទីមួយ គឺផ្លូវមានទំហំទទឹង៦០ម៉ែត្រ កម្រិតទីពីរមានទទឹង៤៥ម៉ែត្រ កម្រិតទីបី មានទទឹង៣០ម៉ែត្រ និងកម្រិតទីបួន២០ម៉ែត្រ។ បណ្តាញផ្លូវទាំងនេះសម្រាប់បម្រើការតភ្ជាប់ រវាងរាជធានីទៅខេត្តនិងទីក្រុងរណបខ្សែក្រវាត់ក្រុង ដើម្បីបង្វែរចរាចរណ៍មិនឱ្យឆ្លងកាត់ទីកណ្តាលក្រុង និងដើម្បីការភ្ជាប់ទំនាក់ទំនងទៅតំបន់ធំនានា។

៤.៤.៣- បណ្តាញពណ៌បៃតង(សួននិងដើមឈើ)និងពណ៌ខៀវ(ទឹក)

ជាការចាំបាច់ក្នុងការកំណត់នូវបណ្តាញមួយទៀត គឺបណ្តាញផ្ទៃទឹកដែលត្រូវរក្សាទុក ដើម្បីអាចឱ្យមានដំណើរការល្អមួយនៃប្រព័ន្ធធារាសាស្ត្ររាជធានីភ្នំពេញ និងអាចការពារការមានជាអតិបរមានូវហានិភ័យនៃគ្រោះទឹកជំនន់ជាអាទិ៍ អាចធ្វើការស្តុកទុកជាបណ្តោះអាសន្ននូវ...

ទាំងឡាយ។ នេះគឺជាលក្ខខណ្ឌសំខាន់ៗដែលត្រូវតែគោរព ហើយការរៀបចំទំហំនៃផ្ទៃទឹកនេះ ត្រូវបានគណនាដោយហ្មត់ចត់បំផុតតាមដែលអាចធ្វើទៅបាន។ ការកំណត់នូវផ្ទៃបឹង និង បណ្តាញប្រឡាយនានា ដែលត្រូវថែរក្សាទុក និងអាចឱ្យយើងរៀបចំផងដែរនូវក្របខ័ណ្ឌនៃការ រៀបចំអភិវឌ្ឍន៍ប្រកបដោយគុណភាពខ្ពស់ដើម្បីការអភិវឌ្ឍរាជធានីភ្នំពេញ។ ***បណ្តាញពណ៌ខៀវ*** នេះត្រូវអមដោយ ***បណ្តាញពណ៌បៃតង*** (រូបភាពទី១២នៃឯកសារឧបសម្ព័ន្ធ)ដែលមួយផ្នែកជា តំបន់លាតសន្ធឹងរបស់បឹងនានានៅរដូវវស្សា ហើយដែលត្រូវប្រើប្រាស់ជាតំបន់ពណ៌បៃតង សាធារណៈនៅរដូវប្រាំងដែលមានអាកាសធាតុក្តៅ។ តំបន់ភូមិនានាក៏ត្រូវបានស្នើឡើងដែរ ដែលតំបន់ទាំងនេះ ត្រូវបានកំណត់សម្គាល់ដោយចំណែកដីដែលមានលក្ខណៈជាភូមិបុរាណ ចំណែកដីទាំងនេះមានការលំបាកក្នុងការធ្វើការរៀបចំនានា ហើយដោយសារតែមានវត្តមាន នៃដើមឈើយ៉ាងច្រើន។ ចំណែកដីទាំងនេះត្រូវបានចាត់ទុកទៅក្នុងបណ្តាញពណ៌បៃតងផង ដែរ[9]។ គោលការណ៍ដែលត្រូវបានស្នើឡើងនេះនឹងកាត់បន្ថយនូវការរៀបចំនានានៅក្នុងតំបន់ ដែលមានដង់ស៊ីតេទាប (សង្កាត់ភូមិគ្រឹះនានា) ហើយការរក្សាទុកនូវតំបន់ពណ៌បៃតងនឹងធ្វើ ឡើងជាអតិបរមានៅទីនោះ ដូចនេះបណ្តាញពណ៌បៃតង និងពណ៌ខៀវ ធានានូវមុខងារយ៉ាង ច្រើន : សន្តិសុខធារាសាស្ត្រ ការរក្សាទុកនូវភាពបន្តគ្នានៃទីក្រុង និងការរក្សាទុកនូវតំបន់ដែល ជ្រាបទឹក ការកំណត់រចនាសម្ព័ន្ធទេសភាពក្រុង ការទទួលជាកន្លែងលម្ហែកាយ និងចរាចរណ៍ សុវត្ថិភាព ការធ្វើឱ្យប្រសើរឡើងនៃគុណភាពដែនដីក្រុងការលើកតម្កើងតម្លៃដីធ្លី។

៤.៤.៤- ការបម្រុងទុកនូវប៉ូលអភិវឌ្ឍន៍បន្ទាប់នានាក្នុងកម្រិតទីប្រជុំជនក្រុង

សម្រាប់ពេលបច្ចុប្បន្ននេះ សារៈសំខាន់នៃមុខងារកណ្តាលនិងសេវាកម្មនានាក្នុងកម្រិត ទីក្រុងធំគឺប្រមូលផ្តុំនៅក្នុងខណ្ឌកណ្តាលក្រុងទាំងបួន។នៅព្រំប្រទល់ខាងត្បូងរាជធានីភ្នំពេញ និងនៅក្នុងខេត្តកណ្តាល តាខ្មៅគឺជាច្រកចូលផ្នែកខាងត្បូងនៃទីប្រជុំជនក្រុង ហើយក៏ជាប៉ូល ប្រមូលផ្តុំបន្ទាប់មួយរបស់ភ្នំពេញ ដែលយើងត្រូវតែពង្រឹងដើម្បីបម្រើសេវានៅផ្នែកខាងត្បូងនៃ ទីប្រជុំជនក្រុង ។

នៅក្នុងក្របខ័ណ្ឌនៃប្លង់គោល គួរតែបានគ្រោងធ្វើរចនាសម្ព័ន្ធនៃប៉ូលប្រមូលផ្តុំបន្ទាប់ក្នុង កម្រិតទីប្រជុំជនក្រុងយ៉ាងហោចណាស់ចំនួនបួន មួយនៅចន្លោះស្ថានីយរថភ្លើងថ្មីដែលត្រូវបាន ស្នើឱ្យសាងសង់ឡើងនៅផ្នែកច្រកចូលខាងលិចនិងតំបន់អាកាសយានដ្ឋាន ប៉ូលប្រមូលផ្តុំបន្ទាប់ មួយទៀត អាចនឹងត្រូវបានគ្រោងធ្វើឡើងនៅផ្នែកច្រកចូលខាងជើងនៃទីប្រជុំជនក្រុង ដែលនៅ ទីនោះការវិវត្តនគរូបនីយកម្មជាខ្សែបន្ទាត់នៅតាមបណ្តោយទន្លេ នឹងមានកាន់តែច្រើននៅជុំវិញ បឹងខាងជើង។

ការរៀបចំប៉ែកខាងត្បូងនៃតំបន់ចតុមុខ ជាមួយនឹងទំនប់ការពារនៅច្រកចូលទន្លេបាសាក់ ច្បារអំពៅនឹងផ្តល់នូវឱកាសក្នុងការកសាងប៉ូលសេវាកម្មថ្មីមួយទៀតសម្រាប់តំបន់នគរូបនីយកម្ម ធំៗនាពេលអនាគត។

[9]សូមអានរបាយការណ៍បេសកម្មរបស់លោក ប៉ូល ម៉ាតតាំង ទ្រីកូ (P.M Tricaud) ស្ថាបត្យករអ្នករៀបចំទេសភាព

ការរៀបចំទីក្រុងអូឡាំពិកនៅផ្នែកខាងជើង ដែលនឹងមានការស្ថាបនាបន្ថែមនូវពហុកីឡដ្ឋានសម្រាប់ល្បែងកីឡាអាស៊ាននាពេលខាងមុខរួមជាមួយការអភិវឌ្ឍចម្រុះ នឹងបានធ្វើឱ្យកើតចេញជាប៉ូលបន្ទាប់រណបឱ្យរាជធានីភ្នំពេញ។

ជាទីបញ្ចប់ ការអភិវឌ្ឍដែលកំពុងតែមានដំណើរការនៅតំបន់ជាយក្រុងប៉ែកនិរតី បង្ហាញអំពីហេតុផលនៃការអភិវឌ្ឍមជ្ឈមណ្ឌលសេវាកម្មមួយ ដែលនឹងអាចមានការអភិវឌ្ឍនៅតាមបណ្តោយបឹងក្រពើនៅចំណុចប្រសព្វរវាងច្រកចូលថ្មីរបស់ទីក្រុងនៅខាងត្បូងនិងផ្លូវចោមចៅ។

៤.៤.៥- ភាពចាំបាច់នៃប្រព័ន្ធដឹកជញ្ជូនរួម

បញ្ហានៃការកកស្ទះដែលកាន់តែកើនឡើងនៃការធ្វើចរាចរណ៍នៅក្នុងទីប្រជុំជនក្រុង ដែលទំហំចំណតយានយន្តបានកើនឡើងទ្វេដងក្នុងអំឡុងពេលដប់[១០]ឆ្នាំ តម្រូវឱ្យមានការគិតពិចារណាឡើងវិញដល់ដំណោះស្រាយដែលត្រូវលើកឡើងក្នុងវិស័យដឹកជញ្ជូនរួម។

ជម្រើសមួយដែលបានបញ្ជាក់ខាងលើរួចមកហើយ ក្នុងចំណោមជម្រើសដែលបានស្នើឡើងនានា គឺការប្រើប្រាស់នូវផ្លូវដែកដែលមានស្រាប់ទាំងឡាយដើម្បីឱ្យរថភ្លើងក្នុងក្រុងអាចធ្វើចរាចរណ៍បាន។ ប្រព័ន្ធនេះនឹងបង្កើតឱ្យមានចំណតរថភ្លើងសម្រាប់ភាគខាងលិច និងខាងជើងនៃទីប្រជុំជនក្រុង។ ប្រព័ន្ធនេះនឹងត្រូវបំពេញបន្ថែមដោយប្រព័ន្ធដឹកជញ្ជូនរួមមួយទៀត (រថយន្តក្រុងឬរថភ្លើងត្រាំវ៉េ) ដែលនឹងត្រូវកំណត់ពេលក្រោយដែលតភ្ជាប់ទីកណ្តាលក្រុងឆ្ពោះទៅទីក្រុងតាខ្មៅនៅភាគខាងត្បូង។

ការប្រើប្រាស់ទន្លេគឺជាជំហរសម្រាប់សម្រួលការដឹកជញ្ជូនក្នុងក្រុង នឹងត្រូវគ្រោងធ្វើឡើងដើម្បីសម្រាលដល់ផ្លូវថ្នល់ទាំងឡាយ ក៏ប៉ុន្តែសមត្ថភាពរបស់វានឹងនៅមានកម្រិតនៅឡើយ។

៤.៥- បេតិកភណ្ឌតំបន់ពិសេសនានានិងទេសភាពរបស់ទីក្រុង

៤.៥.១- តើត្រូវយកគំរូអភិវឌ្ឍន៍មួយណាសម្រាប់រាជធានីភ្នំពេញ?

នៅពេលដែលទីក្រុងធំៗនៅអាស៊ីបានបាត់បង់អត្តសញ្ញាណ និងក្របខ័ណ្ឌជីវិតរបស់ពួកគេក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដំណើរប្រែប្រួលនៃប្រវត្តិសាស្ត្ររាជធានីភ្នំពេញបានធ្វើឱ្យទីក្រុងនេះក្លាយជាបេតិកភណ្ឌស្ថាបត្យកម្ម ដែលមានគុណភាពទទួលស្គាល់ដោយសម្រស់និងអត្តសញ្ញាណរបស់ខ្លួន រហូតមកដល់បច្ចុប្បន្ននេះ នៅក្នុងទស្សនៈនេះ រាជធានីភ្នំពេញមានគុណភាពនគរូបនីយកម្មដែលមិនចាញ់ទីក្រុងហាណូយឬហូជីមិញទេ។ គុណសម្បត្តិដ៏វិសេសវិសាលរបស់ខ្លួនឯងផ្ទាល់ដែលត្រូវរក្សាជាពិសេសដាច់ដោយឡែករបស់ខ្លួន និងដែលត្រូវពង្រឹងភាពទាក់ទាញរបស់ខ្លួនជាអាទិ៍ ការទាក់ទាញផ្នែកទេសចរណ៍ជាមួយនឹងរូបភាពជាទីក្រុងសួនច្បារ មានចរិតបម្រើឲ្យសេចក្តីត្រូវការរបស់មនុស្សជាតិ ហើយបានសម្រេចនូវការការពារភាពស្រស់ស្រាយនៃជីវិតទីក្រុង។ នៅក្នុងន័យនេះ នយោបាយសមស្របមួយក្នុងការការពារនិង

---

[១០] ចំណតយានយន្តមានទំហំសម្រាប់៦៨០ ០០០ យានយន្តគ្រឿង ស្មើនឹងយានយន្តមួយសម្រាប់ប្រជាជនពីរនាក់ ហើយស្មើនឹង[illegible] នៃចំណត់ប្រទេសកម្ពុជា។ ចំណត់យានយន្តនេះអាចផ្ទុកទោចក្រយានបានចំនួន៤៩០ ០០០រថយន្តក្រុងធុនតូច រថយន្ត[illegible]ចំនួន ១៦០ ០០០ រថយន្តធន់ធ្ងន់ និងរថយន្តក្រុង៣០ ០០០។

លើកតម្កើងបេតិកភណ្ឌស្ថាបត្យកម្មការការពារនិងលើកតម្កើងគុណភាពទេសភាព គួរត្រូវតែបានកំណត់។

ដូច្នេះ សំណួរដែលត្រូវលើកឡើងនៅទីនេះគឺថាតើភ្នំពេញត្រូវជ្រើសយករបៀបអភិវឌ្ឍន៍តាមបែបណា ដើម្បីកុំឱ្យរងនូវភាពអវិជ្ជមានដែលបណ្តាលពីការអភិវឌ្ឍនេះ។ ដោយសំអាងលើវប្បធម៌ ប្រវត្តិសាស្ត្រទីក្រុង គុណសម្បត្តិនិងសក្តានុពលរបស់ខ្លួន តើរាជធានីភ្នំពេញអាចកំណត់នូវរបៀបអភិវឌ្ឍន៍ពិសេសមួយ ដែលចេញពីក្របខ័ណ្ឌអភិរក្សទីក្រុងមួយប្រកបដោយគុណភាពឱ្យទៅជាការទទួលយកទំនើបនីយកម្ម?

៤.៥.២- ការលើកតម្កើងតំបន់ចតុមុខ

តំបន់ចតុមុខគឺជាតំបន់វិសេសវិសាលណាស់ ហើយគុណភាពនៃការអភិវឌ្ឍនានាក្នុងតំបន់នេះគឺជាលទ្ធផលរំពឹងទុកដ៏សំខាន់សម្រាប់រូបភាពរបស់ទីក្រុង។ ចំណុចចុងជ្រោយចង្វាដែលជាតំបន់ឯកសិទ្ធិបំផុតនៅទល់មុខនឹងព្រះបរមរាជវាំង នឹងត្រូវតែរៀបចំការអភិវឌ្ឍដែលស្របនឹងការអភិរក្ស ពោលគឺជាគម្រោងពិសេសដែលមានភាពសុខដុមរមនាជាមួយរមណីយដ្ឋានវត្តភ្នំនិងព្រះរាជវាំង។

ច្រកចូលនៃទន្លេបាសាក់គឺជាតំបន់មានហានិភ័យធំៗ ដែលទាមទារឱ្យមានការរៀបចំសំខាន់ៗ និងមានតម្លៃខ្ពស់សម្រាប់ធ្វើឱ្យមានស្ថិរភាពនៅតំបន់នេះ។ ការចាក់ដីលុបដែលបានធ្វើឡើងនៅដើមទសវត្សរ៍ឆ្នាំ១៩៦០នៅទីកន្លែងសណ្ឋាគារកាំបូឌីយ៉ាណាសព្វថ្ងៃ បានជំរុញចលនាច្រាំងទន្លេជាង១គីឡូម៉ែត្រឆ្ពោះទៅទិសខាងកើតក្នុងរយៈពេល៤០ឆ្នាំ។ ការវិវត្តថ្មីៗនៃច្រាំងខាងកើតរបស់ច្រកចូលទន្លេបាសាក់ គឺជាការពង្រីកដីទំហំជាង១០០ម៉ែត្រឆ្ពោះទៅទិសខាងកើតនៅចន្លោះឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០១ បន្តពីកន្លែងដែលមានការសាងសង់ទំនប់ សួនច្បារសម្តេចហ៊ុនសែន ដែលបណ្តាលឱ្យមានបាក់ដីយ៉ាងខ្លាំង ហើយបាននាំយកទៅបាត់នូវផ្ទះសម្បែងនានានិងវត្តមួយផងនៅត្រើយខាងកើតទន្លេបាសាក់ (រូបភាពទី១៣នៃឯកសារឧបសម្ព័ន្ធ)។ ការវិវត្តរបៀបនេះនឹងនាំឱ្យមានការបិទច្រកទន្លេបាសាក់បន្តិចម្តងៗ ដែលនាំឱ្យខូចប្រយោជន៍ដល់កសិកម្មខាងក្រោមនៃទន្លេ។ ដូច្នេះ ទាមទារជាចាំបាច់នូវការស្ថាបនាច្រាំងទន្លេរឹងមាំនិងការស្តារជាប្រចាំនូវកំណាកដីបាតទន្លេ ពិសេសតំបន់ចតុមុខ។

តាមកម្រិតនិងចម្ងាយឆ្ងាយល្មមពីមជ្ឈមណ្ឌលប្រវត្តិសាស្ត្រចំណុចចុងនៃច្បារអំពៅអាចទទួលក្នុងរយៈពេលមធ្យមនូវការធ្វើការរៀបចំជានិមិត្តរូប សម្រាប់ប្រទេសកម្ពុជានាពេលអនាគត។ មហិច្ឆតានិងកម្រិតនៃកិច្ចប្រតិបត្តិការនេះ នឹងអាចទទួលបន្ទុកនូវបញ្ហាបច្ចេកទេសសំខាន់ៗនានាដែលមាននៅក្នុងការរៀបចំតំបន់នេះ ដែលជាតំបន់ប្រឈមមុខនឹងអានុភាពរបស់ទន្លេ។ តំបន់នេះនឹងធានាអភិវឌ្ឍន៍ប្រកបដោយគុណភាពខ្ពស់សម្រាប់ទទួលនូវអគារខ្ពស់ៗនានា។

នៅខាងកើតទល់មុខនឹងតំបន់នេះ គឺតំបន់អរិយក្សត្រនឹងត្រូវរក្សាទុកនៅក្នុងរយៈពេល ១០ឆ្នាំទៅមុខទៀត ជាលក្ខណៈភូមិនិងទេសភាពដូចនឹងការបម្រុងទុកនៃនគរូបនីយកម្មសម្រាប់កំណត់នៅពេលក្រោយ នៅក្នុងគម្រោងប្លង់គោលបន្ទាប់មកទៀត។ ក៏ប៉ុន្តែក្នុងពេលនេះ...

និមិត្តរូបសំខាន់ៗដូចជាវត្តអារាម ឬបូជនីយដ្ឋានដែលអាចមើលឃើញពីអ័ក្សសួនច្បារសម្ដេចហ៊ុនសែន នឹងអាចរក្សាបាននូវគុណភាពទេសភាព ហើយនិងអាចគ្រោងសម្រាប់ការពង្រីកទីក្រុងនាពេលអនាគត។ ជាទូទៅ ការលើកតម្កើងតម្លៃតំបន់ចតុមុខគួរតែបង្កើតឱ្យមានការប្រឡងប្រជែងនគរូបនីយកម្មជាលក្ខណៈអន្តរជាតិ ដើម្បីទាក់ទាញរកអ្នករៀបចំក្រុងដ៏ល្បីៗបំផុតនៅលើពិភពលោកឱ្យមកចូលរួមប្រកួតប្រជែងចូលរួមសិក្សា។

៤.៥.៣- ការលើកតម្កើងការអភិវឌ្ឍតំបន់បឹងកក់

ទីតាំងសាធារណៈថ្មីៗ អគារការិយាល័យ និងពាណិជ្ជកម្មទំនើបៗនឹងអាចលើកតម្កើងតំបន់នេះ ដោយអាចបើកចំហដល់សាធារណជនអាចបង្កើតតំបន់កណ្ដាលក្រុងថ្មី និងបង្កើតកាលានុវត្តភាពនៃការធ្វើវិនិយោគទុនថ្មីៗដែលមានលម្ហបើកទូលាយច្រើន។

គម្រោងរបស់សាលារាជធានីក្នុងការរៀបចំបឹងកក់ តម្រូវឱ្យមានការថែរក្សានៃទីតាំងស្ថានីយរថភ្លើងចាស់ ដែលជាសំណង់បេតិកភណ្ឌ និងតម្រូវឱ្យមានការតភ្ជាប់ឡើងវិញនូវបណ្ដាញផ្លូវដែលតភ្ជាប់តំបន់ខាងលិច និងខាងជើងមកតំបន់ទីក្រុងចាស់ផ្នែកខាងត្បូង និងខាងកើតនៃបឹងកក់នេះ ផ្លូវថ្មីៗ និងទីតាំងសាធារណៈនានាដែលបន្តពីទីលាននៅមុខស្ថានីយរថភ្លើងឆ្ពោះទៅខាងលិចនៅទល់មុខទីស្ដីការគណៈរដ្ឋមន្ត្រីសព្វថ្ងៃ។ ការបន្តពីផ្ទៃពណ៌បៃតង ដែលមានទំនាក់ទំនងរវាងពហុកីឡាដ្ឋានអូឡាំពិក និងបឹងកក់ គឺជាទីកន្លែងថ្មីៗផងដែរដែល បន្តប្លង់អភិវឌ្ឍន៍ជាប្រវត្តិសាស្ត្ររបស់រាជធានី ហើយផ្លូវទាំងនេះនឹងរៀបសម្រាប់ទទួលនូវសកម្មភាពកម្សាន្តទាំងឡាយ (មជ្ឈមណ្ឌលវប្បធម៌ និងតាំងពិព័រណ៌ រោងភាពយន្ត សាល មហោស្រពបណ្ណាល័យសោតទស្សន៍) ទទួលនូវសកម្មភាពប្រើប្រាស់ទាំងឡាយ (មជ្ឈមណ្ឌលពាណិជ្ជកម្មភោជនីយដ្ឋាន សណ្ឋាគារ) និងទទួលសេវាកម្មនានា (ការិយាល័យរដ្ឋបាលនានា)។

៤.៥.៤- ការលើកតម្កើងបឹងនានានៅភាគខាងជើង

បឹងនៅភាគខាងជើង (បឹងតាមោគនិងបណ្ដាញរបស់វា) នៃរាជធានីភ្នំពេញគឺជាសេចក្ដីប្រាថ្នានៃការរៀបចំនគរូបនីយកម្ម បឹងទាំងនេះបង្ហាញនូវឱកាសតែមួយគត់សម្រាប់បង្កើតនូវទីតាំងនគរូបនីយកម្មថ្មីមួយដើម្បីធ្វើការពង្រីកទីក្រុងប្រកបដោយគុណភាពខ្ពស់ ដែលរាជធានីត្រូវតែមាន ដើម្បីទទួលនូវស្ដង់ដាលំនៅឋាន និងតំបន់កណ្ដាលក្រុងថ្មីៗ។

ការថែរក្សាទុកនូវបឹងទាំងអស់នេះ គឺមានសារៈសំខាន់ណាស់សម្រាប់ការបង្ហូរទឹកពីទីតាំងនគរូបនីយកម្មដែលបានគ្រោងទុកនៅខាងជើងទំនប់កប់ស្រូវនិងទន្លេសាប។ ការធ្វើឱ្យថយសមត្ថភាពជ្រាបទឹកនូវផ្ទៃដីទាំងឡាយបន្តិចម្ដងៗ នឹងនាំឱ្យមានការលំបាកកាន់តែខ្លាំងក្នុងការគ្រប់គ្រងជំនន់ដោយទឹកភ្លៀងធំៗ។

ការការពារនិងការលើកតម្កើងបឹងនានា ដែលតភ្ជាប់ទៅនឹងប្រឡាយដ៏ធំនានាក្នុងខណ្ឌឫស្សីកែវនិងខណ្ឌសែនសុខ នឹងក្លាយទៅជាជន្ទល់ដ៏មានសារៈសំខាន់សម្រាប់ទាក់ទាញការអភិវឌ្ឍប្រកបដោយគុណភាព ដោយរាប់បញ្ចូលផងដែរនូវគម្រោងដែលអាចមានគុណខ្ពស់ៗជុំវិញនៃមាត់បឹង។

ការអភិវឌ្ឍទាំងឡាយនេះ តម្រូវឱ្យមានការបង្កើតឡើងនូវអាងទទួលទឹកដែលប្រើប្រាស់រួចហើយដែលនឹងត្រូវបង្ហូរទឹកកខ្វក់ទាំងនេះចេញពីតំបន់ជាយក្រុងខាងជើងទៅកាន់អាងចម្រោះទឹកកខ្វក់បឹងជើងឯកនៃតំបន់ជាយក្រុងខាងត្បូង ដើម្បីចៀសវាងការបំពុលបរិស្ថានទន្លេសាបដែលជាទីតាំងបរិស្ថាននិងសេដ្ឋកិច្ច(ទេសចរណ៍ការនេសាទ) ដ៏សំខាន់មួយរបស់ប្រទេសកម្ពុជា។

៤.៥.៥- ការរៀបចំផ្ទៃអាងចម្រោះទឹកកខ្វក់ខាងត្បូងក្រុង(បឹងជើងឯក)

ការសម្អាតទឹកកខ្វក់របស់រាជធានីភ្នំពេញនៅក្នុងបឹងនៃតំបន់ជាយក្រុងខាងត្បូង(ជើងឯក) គឺសម្រាប់បន្សុទ្ធទឹកកខ្វក់របស់ទីក្រុងតាមរយៈការធ្វើអាងសម្អាតជាបន្តបន្ទាប់ និងខុសៗគ្នា (ការច្រោះទឹក-អាងទឹក សម្រាប់ដំណាំមិនត្រូវការខ្យល់-អាងទឹកសម្រាប់ដំណាំធំៗ ការដាំដំណាំនានា និងការចិញ្ចឹមត្រី)មុននឹងបញ្ចេញទៅក្នុងមជ្ឈដ្ឋានធម្មជាតិ។ ការបន្សុទ្ធនេះតម្រូវឱ្យមានការរៀបចំទុកផ្ទៃបឹងទំហំ៥២០ហិកតា (ប្រហាក់ប្រហែលនឹង២ម៉ែត្រក្រឡាសម្រាប់ប្រជាជនម្នាក់ និងតំបន់ការពារនៅជុំវិញបឹង)។

៤.៥.៦- ការរៀបចំទីតាំងទីលានចាក់សំរាម

ការកើនឡើងនូវសំរាមជារៀងរាល់ឆ្នាំ បរិមាណសំរាមអាចនឹងមានចំនួន២០០០តោនក្នុងមួយថ្ងៃត្រឹមឆ្នាំ២០១៥។ ជាមួយគ្នានេះ គេអាចប៉ាន់ប្រមាណថា សមត្ថភាពទីលានចាក់សំរាមដង្កោមានសមត្ថភាពត្រឹមឆ្នាំ២០១៧។ ចាប់ពីក្រោយឆ្នាំ២០១៧យ៉ាងយូរ ទាមទារឲ្យមានការរកទីលានចាក់សំរាមថ្មី បើអាចឆ្ងាយពីទីប្រជុំជនកាន់តែប្រសើរ ដើម្បីអាចបន្ថយនូវការបំពុលឬត្រូវជំរុញឲ្យមានការអភិវឌ្ឍរោងចក្រផលិតអគ្គិសនីពីឋាមពលសំរាម ឬដោយមធ្យោបាយទាំងពីរយ៉ាង ទាំងការសាងសង់រោងចក្រ និងការសាងសង់រោងចក្រផលិតអគ្គិសនី។ ថែមលើនេះទៀត ដើម្បីលើកកម្ពស់បរិស្ថាន ភាពអនុគ្រោះលើការទិញអគ្គិសនីពីរោងចក្រដែលដើរដោយឋាមពលសំរាម គួរបានពិចារណាជាអាទិភាព។

៤.៥.៧- ការបង្កើតលក្ខខណ្ឌចាំបាច់សម្រាប់ទទួលអគារខ្ពស់ៗ

ការសាងសង់អគារខ្ពស់ៗនៅរាជធានីភ្នំពេញ គឺជាប្រធានបទដ៏រសើបមួយ តាមពិតទៅទីក្រុង មានកម្ពស់កើនឡើងតាំងពីច្រើនឆ្នាំមកហើយ យោងទៅតាមការវិវត្តនៃដង់ស៊ីតេ។ កំណើនសេដ្ឋកិច្ចរបស់រាជធានីភ្នំពេញ ដែលក្នុងនោះមានអ្នកធ្វើវិនិយោគទុនបានចូលរួមផងដែរនឹងត្រូវបង្ខំឱ្យមាន ទោះយូរឬឆាប់នូវការសាងសង់អគារខ្ពស់ៗនានា។ បញ្ហាមិនមែនបដិសេធការសាងសង់អគារខ្ពស់ៗនោះទេ ក៏ប៉ុន្តែគឺធ្វើយ៉ាងណារៀបចំទីតាំងរបស់វាឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកធ្វើវិនិយោគទុន តែជំរុញនូវគុណសម្បត្តិនៃទេសភាពនគរូបនីយកម្មក្រុងមិនត្រូវឱ្យការសាងសង់អគារខ្ពស់ៗ ដែលធ្វើឱ្យធ្លាក់តម្លៃទីកណ្តាលក្រុង ធ្វើឱ្យបាត់បង់ភាពស្អាតរបស់ទេសភាពទីក្រុង ឬស្ថានភាពនៃការធ្វើចរាចរណ៍នានានោះទេ។ តំបន់កណ្តាលក្រុងជាតំបន់ប្រវត្តិសាស្ត្រតាំងពីមុនមកមិនបានរៀបចំនូវរចនាសម្ព័ន្ធសម្រាប់ទទួលអគារខ្ពស់ៗ ដែលជាទូទៅ

បានរៀបចំឱ្យមានផ្លូវចង្អៀត ទំហំដីឡូត៍តូចៗ ការលំបាកទាំងឡាយដែលជួបប្រទះរបស់ទីក្រុងនានានៅក្នុងតំបន់ក្នុងការគ្រប់គ្រងការធ្វើចរាចរណ៍ជាអាទិ៍ដោយសារតែការសាងសង់នៃអគារខ្ពស់ៗនៅក្នុងតំបន់កណ្តាលក្រុងជាប្រវត្តិសាស្ត្រដែលគួរជំរុញឱ្យមានការបង្វែរ ឬស្នើឡើងនូវទីតាំងផ្សេងទៀត ដែលសមរម្យជាងនេះ។

ការបង្កើនសេដ្ឋកិច្ចរាជធានីភ្នំពេញទាំងលើផែនការទេសចរណ៍ និងការបោះទីតាំងរបស់ក្រុមហ៊ុនសហគ្រាសនានាចាំបាច់ត្រូវតែរក្សានូវគុណភាពទេសភាព នៃតំបន់កណ្តាលក្រុងជាប្រវត្តិសាស្ត្រជាអាទិ៍ នៅជុំវិញផ្សារធំថ្មី ជុំវិញវត្តភ្នំ និងព្រះបរមរាជវាំង។

ដូចគ្នានេះដែរនៅក្នុងករណី ដែលអគារខ្ពស់ៗនានាមិនធ្វើឱ្យអន្តរាយដល់ទេសភាពទីក្រុងការសាងសង់អគារខ្ពស់ៗនានា នឹងអាចត្រូវបានគ្រោងធ្វើឡើងនៅក្នុងផ្នែកមួយចំនួននៃទីប្រជុំជនក្រុងហើយថែមទាំងអាចជាសេវាសម្រាប់សមាសភាព នគរូបនីយកម្ម ការកំណត់ផ្លូវចូលទីក្រុងនៅខាងជើងទួលគោក ឬនៅខាងប៉ែកនិរតី (បឹងក្រពើ)ការរក្សាទុកនូវស្ថាបត្យកម្មដាច់ៗគ្នាដែលអាចឱ្យមានផ្លូវចូលសាធារណៈទៅកាន់ច្រាំងទន្លេ (ច្បារអំពៅ) ឬបឹង (បឹងពោងពាយ បឹងកក់...)។

៤.៥.៨- នយោបាយលំនៅឋានដីធ្លីនិងអចលនវត្ថុ

កំណើនប្រជាជនរាជធានីភ្នំពេញមានប្រហែល ៤០ ០០០នាក់ ក្នុងមួយឆ្នាំ ជាល្បឿនកំណើនមួយប្រហែលគ្នានឹងល្បឿននៃកំណើនមុនសង្គ្រាមដែរ។ គោលនយោបាយកសិកម្មមួយមុខមិនអាចកាត់បន្ថយបាននូវការធ្វើចំណាកស្រុកពីទីជនបទមកទីក្រុងបានទេ(កំណើនប្រជាជននៅប្រទេសកម្ពុជាគឺ ១,៥%ក្នុងមួយឆ្នាំ ហើយកំណើនផ្ទៃដីកសិកម្មគឺស្មើ ០,៥ក្នុង១ឆ្នាំ) ហើយទីក្រុងបន្ទាប់នានាស្រូបយក ១/៣នៃប្រជាជនធ្វើបម្លាស់ទីអន្តរតំបន់ ហើយក្នុងនោះមាន២០% មករាជធានីភ្នំពេញ។ គោលនយោបាយជាតិស្តីពីលំនៅឋាន នឹងរួមចំណែកដល់ការដោះស្រាយសំណង់បណ្តោះអាសន្ននានាដោយសុច្ឆន្ទៈ ក្នុងការលើកតម្កើងឡើងវិញនូវតំបន់កណ្តាលក្រុងនៃរាជធានីផង និងដើម្បីផ្តល់នូវលក្ខខណ្ឌជីវិត ដ៏ប្រសើរដល់ប្រជាជនក្រីក្រទាំងឡាយផង។ សកម្មភាពនៃការផ្តល់ទីតាំងថ្មី ដល់អ្នករស់នៅក្នុងសំណង់អនាធិបតេយ្យទាំងឡាយ (១៩៩៨-២០០២)បានធ្វើបម្លាស់ទីប្រជាជនជាង១០ ០០០គ្រួសារពីកណ្តាលក្រុងទៅកាន់ជាយក្រុងជាមួយនឹងបទពិសោធ ដែលទោះជាបានរៀបចំនិងព្រមព្រៀងគ្នាយ៉ាងល្អក៏ដោយ ក៏ការធ្វើបម្លាស់ទីប្រជាជនខ្លះបានជួបប្រទះនូវការលំបាកមួយចំនួន ដោយសារវាបានបង្កើតឱ្យមាននូវចលនាវិលទៅរកតំបន់អនាធិបតេយ្យនៅកណ្តាលក្រុងរបស់ខ្លួនវិញ ក្រោមកិច្ចលូកដៃរបស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន។ ដូច្នេះ វាបានបំផ្លាញចោលមួយផ្នែកនូវកិច្ចខិតខំប្រឹងប្រែងនានាដែលបានធ្វើក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាអាទិ៍ទាក់ទងនឹងការកសាងនីតិរដ្ឋ ដោយ[illegible] ហើយការកាន់កាប់ទីកន្លែងដោយភាពមិនស្របច្បាប់ ហាក់បីដូចជាបានក្លាយទៅ[illegible] មួយសម្រាប់ទាក់ទាញឲ្យមានការចូលក្នុងក្រុងដោយប្រជាជនក្រីក្រ។ បច្ចុប្បន្ន [illegible] នយោបាយអភិវឌ្ឍសហគមន៍បណ្តោះអាសន្នចំនួន១០០ក្នុងមួយឆ្នាំ និងសា[illegible]

ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន។ នេះជាគោលបំណងដ៏មានមហិច្ឆតាធំណាស់។ ក៏ប៉ុន្តែគោលនយោបាយនេះតែមួយមុខ មិនអាចទប់ស្កាត់នឹងកំណើនលឿនរបស់ប្រជាជនចំណូលថ្មីដែលជាបញ្ហាស្រួចស្រាល់ជាងគេបំផុតទេ។ គោលនយោបាយដែលផ្តោតសំខាន់តែទៅលើសហគមន៍បណ្តោះអាសន្នដែលមានស្រាប់នេះ គឺមិនមានអនាគតល្អទេដោយវាមិនបានដោះស្រាយនូវបញ្ហាចំណូលថ្មីបន្ថែមនៃប្រជាជនក្រីក្រមានចំនួន ២៥ ០០០ នាក់ក្នុងមួយឆ្នាំ(ជាង ៥ ០០០ គ្រួសារ/ឆ្នាំ) ដែលពួកគេជាប្រជាជនដែលគ្មានផ្ទះសម្បែងឬដីធ្លីនោះឡើយ។

តាមពិតទៅ ការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មនគរូបនីយកម្មនិងហេដ្ឋារចនាសម្ព័ន្ធបានចូលរួមយ៉ាងទូលំទូលាយ ដល់ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅរបស់ប្រជាជនទាំងមូលដូចគ្នានេះដែរ ការធ្វើឱ្យមានភាពរឹងមាំនៃទីផ្សារដីធ្លី និងអចលនទ្រព្យដែលយើងបានឃើញតាំងពីប៉ុន្មានឆ្នាំមកហើយនោះ កាន់តែបានឆ្លើយតបជាបណ្តើរៗដល់សេចក្តីត្រូវការផ្នែកលំនៅឋានដែលនាំឱ្យមានការកាត់បន្ថយសម្ពាធនៃការបង្កើតសហគមន៍បណ្តោះអាសន្ន។ ក៏ប៉ុន្តែប្រជាជនមួយចំនួនមិនបានទទួលសេវាកម្មទីផ្សារលំនៅឋានជាក់លាក់ទេ។ ការដែលគ្មានការផ្គត់ផ្គង់នូវលំនៅឋានដែលមានតម្លៃថោកនៅលើទីផ្សារលំនៅឋានដែលមានបរិក្ខារគ្រប់គ្រាន់និងជាក់លាក់ ឬការខ្វះការផ្គត់ផ្គង់នូវដីធ្លីសាងសង់សម្រាប់ប្រជាជនក្រីក្រ គឺជាបញ្ហាដ៏លំបាកដោះស្រាយបំផុត។ ការផ្តោតសំខាន់នៃជំនួយអន្តរជាតិទៅលើសហគមន៍បណ្តោះអាសន្នដែលមានស្រាប់នានា គ្រាន់តែអាចដោះស្រាយបញ្ហាក្នុងរយៈពេលខ្លីប៉ុណ្ណោះ ប្រហែលជាត្រូវជំរុញនូវគំនិតដែលថាមធ្យោបាយតែមួយគត់ដើម្បីចូលទីក្រុងសម្រាប់ប្រជាជនក្រីក្រ គឺភូមិអ្នកក្រនិងក្រុងអនាធិបតេយ្យទៅវិញទេ។ ដូច្នេះ ការបង្កើតភូមិអ្នកក្រនៅតែបន្តកើតមានរហូត ហើយថែមទាំងរីកច្រើនថែមទៀតផង ពីព្រោះថាគ្មានដំណោះស្រាយជាចីរភាពណាមួយត្រូវបានធ្វើឡើងដោយនយោបាយកាត់បន្ថយភាពក្រីក្រទេ។

ការតម្រង់ទិសប្រាំចំណុចគួរត្រូវបានយកចិត្តទុកដាក់ដើម្បីដោះស្រាយបញ្ហាលំនៅឋានៈ

១- ធ្វើឱ្យទីផ្សារដីធ្លីនិងអចលនទ្រព្យមានលំហូរ ដើម្បីធ្វើការអភិវឌ្ឍការផ្គត់ផ្គង់លំនៅឋាននៃក្រុមហ៊ុនឯកជនសម្រាប់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ ភ្នាក់ងារសង្កេតទីផ្សារដីនិងអចលនវត្ថុមួយជាមួយនឹងការប្រជុំជារៀងរាល់ឆមាសដែលប្រមូលផ្តុំគ្រប់មហាជន និងដៃគូអភិវឌ្ឍពាក់ព័ន្ធត្រូវរៀបចំឡើងដោយសាលារាជធានីភ្នំពេញ ដើម្បីចែកចាយព័ត៌មាននិងសម្រួលដល់សកម្មភាពរបស់វិនិយោគិនទាំងឡាយ។ ភ្នាក់ងារសង្កេតដីធ្លីនេះនឹងត្រូវបំពេញបន្ថែម ដោយការអភិវឌ្ឍប្រព័ន្ធឥណទានជាមួយនឹងការប្រាក់ដែលមានភាពទាក់ទាញបំផុត សម្រាប់ឱ្យចំនួនប្រជាជនដ៏ច្រើនបំផុតអាចបង្វិលទឹកប្រាក់សងវិញបាន។

២- ធ្វើការអភិវឌ្ឍលើការផ្គត់ផ្គង់ផ្នែកដីធ្លីដោយផ្តល់អាទិភាព ដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានទាំងឡាយ (ផ្លូវថ្នល់ ទឹកស្អាត ភ្លើងអគ្គិសនី ការបង្ហូរទឹក) នៅតាម[illegible] ជាយក្រុង នានាដែលនឹងអាចទទួលស្រូបយកកំណើនថ្មីនៃប្រជាជនក្រុងចំនួន [illegible]% ពីពេលនេះរហូតដល់ឆ្នាំ២០៣៥។

៣- ធ្វើការអភិវឌ្ឍដីធ្លីដែលបម្រុងទុកសម្រាប់ប្រជាជនក្រីក្រទាំងឡាយ នៅលើដីឯកជនរបស់រដ្ឋ (សម្បទានដីសង្គមកិច្ច ដីទិញដោយទីភ្នាក់ងារអចលនវត្ថុឯកជននានា) នៅតំបន់ជាយក្រុង ដោយត្រូវបានរៀបចំជាចំណែកដីឡូត៍តូចៗតម្លៃថោកប្រកបដោយសម្ភារៈបរិក្ខារគ្រប់គ្រាន់។

៤- ធ្វើការអភិវឌ្ឍទីផ្សារជួលដែលមានលក្ខណៈសង្គមកិច្ច ជាឯកជននៅតំបន់កណ្តាលក្រុងដោយអ្នកអភិវឌ្ឍឯកជន ដោយមានការគ្រប់គ្រងដង់ស៊ីតេនៃអគារលំនៅឋានបានល្អនៅក្នុងក្រុង ជាគោលនយោបាយមួយដើម្បីជំរុញការថែរក្សា និងស្តារឡើងវិញនូវអគារលំនៅឋានរួមចាស់ៗនានានៃតំបន់កណ្តាលក្រុងប្រវត្តិសាស្ត្រ(ខណ្ឌដូនពេញ) និងដោយសារមានវិធានការក្នុងការជំរុញវិស័យនេះ (មិនមានពន្ធ១០%លើការជួលជាលក្ខណៈសង្គមកិច្ចនានា ការជួលរយៈពេលវែងជាមួយនឹងអត្រាប្រាក់ឈ្នួលថោក និងការកាត់បន្ថយនូវតម្លៃជួល..)។

៥- កាត់បន្ថយនូវការបំផ្លាញចោលអគារលំនៅឋានសហកម្មសិទ្ធិ ដែលមានស្រាប់ហើយបង្កើតគោលនយោបាយឧបត្ថម្ភមួយសម្រាប់ការស្តារឡើងវិញនូវអគារចាស់ៗ ដើម្បីធ្វើការអភិវឌ្ឍទីផ្សារកណ្តាលមួយ(តម្លៃថោកសមរម្យ) រវាងទីផ្សារនៃលំនៅឋានថ្មី និងទីផ្សារនៃលំនៅឋាននៅភូមិអ្នកក្រ។

៦- អនុវត្តតាមសារាចរលេខ០៣ស.រ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅតាមរាជធានី ទីក្រុង និងទីប្រជុំជន ដោយធ្វើសមាហរណកម្មទៅនឹងទីក្រុងនូវទីតាំងសហគមន៍បណ្តោះអាសន្ន នៅលើដីសាធារណៈរបស់រដ្ឋទាំងឡាយណាដែលអាចអភិវឌ្ឍនៅនឹងកន្លែង ដោយមានលក្ខខណ្ឌមិនអាចក្លាយជាដីឯកជនបានក្នុងករណីណាក៏ដោយ ដូចមានចែងក្នុងសារាចរ (ផ្លូវដែក បឹង ផ្លូវនានា កំពង់ផែ ស្ថានីយរថភ្លើង សួនច្បារសាធារណៈ ច្រាំងទន្លេ ប្រឡាយនានា...)។

ជម្រើសគោលនយោបាយក្នុងការតម្រង់ទិសការអភិវឌ្ឍ ឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ (រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣) និងការបង្កើនល្បឿននៃការសម្រេចនូវកម្មសិទ្ធិដីដែលផ្តើមនៅក្នុងក្របខ័ណ្ឌនៃគម្រោងរដ្ឋបាលដីធ្លី LMAP របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តម្រូវឱ្យយើងយកចិត្តទុកដាក់ជាអាទិភាពដល់ការកំណត់នូវដីបម្រុងសាធារណៈរបស់រដ្ឋ ដើម្បីបម្រុងទុកនូវទីតាំងចាំបាច់នានាសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធធំៗ ដែលជាលក្ខខណ្ឌកំណត់នូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចលើសពីគម្រោងប្លង់គោលនគរូបនីយកម្មសម្រាប់ឆ្នាំ២០៣៥ទៀតផង។ ដូច្នេះ យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍នេះត្រូវបានធ្វើឡើងសម្រាប់រយៈពេលពីឆ្នាំ២០១៥ ដល់ឆ្នាំ២០៣៥។ ប៉ុន្តែយុទ្ធសាស្ត្រនេះបានបញ្ចូលតែការពិចារណាទាំងឡាយនៃក្របខ័ណ្ឌក្នុងកម្រិត មីក្រូតំបន់ និងស្ថិតក្នុងភាពបណ្តោះអាសន្នតែប៉ុណ្ណោះ។ ដូចនេះសាលារាជធានីត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួនដើម្បីអភិវឌ្ឍឱ្យបានជោគជ័យតាមបំណងប្រាថ្នារបស់ខ្លួន។

៥- ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិរៀបចំដែនដីនិងយុទ្ធសាស្ត្រតម្រង់ទិសនេះ សាលារាជធានីភ្នំពេញត្រូវរៀបចំគម្រោងសំខាន់ៗ ចាំបាច់ដូចតទៅ៖

៥.១- ការផ្សព្វផ្សាយ

- រៀបចំការប្រជុំផ្សព្វផ្សាយយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍នេះដល់ក្រុមជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ ផ្សព្វផ្សាយយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍នេះតាមគេហទំព័រអេឡិច-ត្រូនិករបស់សាលារាជធានី។

៥.២- គម្រោងសំខាន់ៗ ដែលត្រូវការចាំបាច់នូវការអនុម័តបន្ទាន់

- ការអនុម័តបទប្បញ្ញត្តិ និងប្លង់នៃការបម្រុងទុកធំៗនៃវិស័យសាធារណៈ ផ្លូវធំៗ ផ្លូវដែក និងការបង្ហូរទឹកនៅតំបន់ជាយក្រុងនានា
- ការអនុម័តកំណត់ទីតាំងស្ថានីយរថភ្លើងសម្រាប់ទំនិញ និងទីតាំងផែស្ងួតធំនៅសំរោង ខណ្ឌពោធិ៍សែនជ័យ
- ការអនុម័តជាគោលការណ៍នូវគម្រោងផ្លូវដែក ដែលតភ្ជាប់ដោយផ្ទាល់ទៅកាន់ទីក្រុងហូជីមិញ ដែលតម្រូវឱ្យមានស្ពានមួយឆ្លងទន្លេមេគង្គនៅភ្នំពេញ និងផ្លូវដែកដែលតភ្ជាប់ពីស្ថានីយសំរោងទៅតំបន់ជាយក្រុងខាងត្បូងឆ្លងកាត់ទន្លេបាសាក់
- ការស្ដាបនាពង្រីកបន្តនូវផ្លូវចុះចតរបស់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- ការស្ដាបនានូវទំនប់មួយ និងការធ្វើច្រាំងបេតុងជាច្រកចូលរបស់ទន្លេបាសាក់
- ការកំណត់ស្តង់ដាដែលមានអគារខ្ពស់ៗ នៅច្បារអំពៅ នៅបឹងក្រពើ បឹងពោងពាយ ទល់មុខទន្លេបាសាក់ បឹងកក់
- ការកំណត់ទីតាំងទីលានចាក់សំរាមថ្មី ការកែលម្អទីតាំងចាក់សំរាមដង្កោក្រោមរូបភាពនៃការវិនិយោគជារោងចក្រកែច្នៃសំរាម និងការរៀបចំសួនឧទ្យាននៅទីលានចាក់សំរាមមានជ័យ
- ការកំណត់តំបន់អេកូឡូស៊ីព្រែកព្នៅ
- ការអនុវត្តការថែរក្សានិងលើកតម្កើងមជ្ឈមណ្ឌលប្រវត្តិសាស្ត្រ។

៥.៣- បទប្បញ្ញត្តិនគរូបនីយកម្ម

តាមគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី បទប្បញ្ញត្តិនគរូបនីយ-កម្មដែលត្រូវធ្វើមានៈ

- ផែនទីនៃប្លង់បែងចែក និងប្រើប្រាស់ដីធ្លីនៃរាជធានីភ្នំពេញ (Zoning) (រូបភាពទី១៤នៃឯកសារឧបសម្ព័ន្ធ)
- ប្លង់អភិវឌ្ឍន៍ទិសខាងជើងនិងខាងលិច
- ប្លង់អភិវឌ្ឍន៍ទិសខាងត្បូងនិងគម្រោងរៀបចំអាងចម្រោះទឹកបឹងជើងឯក
- ផែនទីនៃប្លង់លម្ហសាធារណៈ(បឹង ប្រឡាយ ផ្លូវថ្នល់ ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ ទីលានពណ៌បៃតង)
- ផែនទីនៃកំណត់តំបន់អភិវឌ្ឍន៍ជាអាទិភាព

- ផែនទីនៃការកំណត់កម្ពស់អគារ និងសេវកិច្ចនៃកម្ពស់ការហោះហើររបស់យន្តហោះ
- ផែនទីសំណង់អគារបេតិកភណ្ឌនៃរាជធានីភ្នំពេញ
- ផែនទី និងបទប្បញ្ញត្តិប្លង់មេទេសភាពដ៏ធំមួយ ការថែរក្សាទេសភាពដើមឈើនានា និងការរៀបចំទេសភាព និងបរិក្ខារសាធារណៈជាតិនៅក្នុងស្តង់ដាចុងជ្រោយចង្វារ។

៥.៤- សកម្មភាពអភិវឌ្ឍន៍បន្តនិងវិនិយោគសាធារណៈ

- ការកសាងនិងអភិវឌ្ឍន៍បន្តទីក្រុងរណបនានាដូចជាកោះពេជ្រ ជ្រោយចង្វារ ខាំកូ
- ការកសាងនិងបន្តអភិវឌ្ឍន៍ទីក្រុងរណបអូឡាំពិកនៅផ្នែកខាងជើងភ្នំពេញ
- ការកសាងបន្តផ្លូវឆ្លងកាត់បឹងកក់ និងបន្តអភិវឌ្ឍន៍តំបន់បឹងកក់
- ការអភិវឌ្ឍនិងកសាងផែស្ងួត និងស្ថានីយអាស៊ាននៅតំបន់សំរោង ខណ្ឌពោធិ៍សែនជ័យ
- ការកសាងបន្តភ្ជាប់ផ្លូវក្រវាត់ក្រុងធំភ្ជាប់ពីខណ្ឌមួយទៅខណ្ឌមួយ(ឫស្សីកែវ-សែនសុខ-ពោធិ៍សែនជ័យ)
- ការស្ថាបនាផ្លូវបន្ទាប់ទាំងឡាយស្របផ្លូវមេ (ផ្លូវជាតិលេខ១,២,៣,៤,៥)ដើម្បីកាត់បន្ថយចរាចរណ៍ចេញនិងចូលក្រុង
- ការស្ថាបនាស្ពានអាកាសតាមរង្វង់មូលធំទាំងឡាយ(ជំនួបរវាងផ្លូវក្រវាត់ក្រុងនិងផ្លូវចេញក្រៅក្រុងទៅខេត្តនានា)
- ការកសាង និងពង្រីកផ្លូវនៅតំបន់ជាយក្រុង ដើម្បីអភិវឌ្ឍមួយមានសមភាព និងតុល្យភាពជាមួយតំបន់កណ្តាលក្រុង និងដើម្បីជួយស្រូបកំណើនប្រជាជនពីទីក្រុង
- ការស្ថាបនាអាងច្រោះទឹកស្អុយនៅបឹងជើងឯក និងការរៀបចំប្រព័ន្ធលូទឹកស្អុយរាជធានីភ្នំពេញ
- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់និងទន់ភ្លន់សារាចរលេខ០៣សរ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជន
- ជំរុញនិងពង្រឹងសមត្ថភាពសេដ្ឋកិច្ចនៅក្នុងវិស័យសំណង់ វិស័យវាយនភណ្ឌ ការចិញ្ចឹមត្រី ការដាំដំណាំបន្លែបង្ការ ការដឹកជញ្ជូនទេសចរណ៍ កសិចំណីអាហារ សេវាកម្មសម្រាប់ក្រុមហ៊ុនសហគ្រាសនានា វិស័យអេឡិចត្រូនិច ការវេចខ្ចប់ ការដំឡើងមេកានិក និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

៦- សេចក្តីសន្និដ្ឋាន

ទោះបីជាកន្លងមក ប្រទេសកម្ពុជាបានជួបវិបត្តិធំនៃសេដ្ឋកិច្ចសកលនិងវិបត្តិព្រំដែនខ្លះជាមួយប្រទេសថៃក៏ដោយ កម្ពុជាបច្ចុប្បន្នមានសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពសណ្តាប់ធ្នាប់សង្គមល្អប្រសើរប្រកបដោយវឌ្ឍនភាពសង្គមកិច្ច និងកំណើនសេដ្ឋកិច្ចដ៏ខ្ពស់

នេះ កម្ពុជាបានធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងតំបន់និងពិភពលោក ហើយថែមទាំងជាសមាជិកដែលស្មើសិទ្ធិជាមួយបណ្តាប្រទេសលើសកលលោកទៀតផង។ គុណសម្បត្តិទាំងនេះបានទាក់ទាញការវិនិយោគក្នុងនិងក្រៅប្រទេសបន្ថែមទៀតលើគ្រប់វិស័យពិសេសវិស័យនគរូបនីយកម្មនិងសំណង់ចាប់ពីពេលនេះរហូតដល់ឆ្នាំ២០៣៥ ដើម្បីឆ្លើយតបនឹងតម្រូវការនៃកំណើនប្រជាជនជិត៣លាននាក់នៅភ្នំពេញ។ ដូច្នេះ គោលការណ៍ធំៗនៃយុទ្ធសាស្ត្រតម្រង់ទិសការអភិវឌ្ឍផ្នែកនគរូបនីយកម្មរាជធានីភ្នំពេញ នឹងត្រូវអនុវត្តដោយទូលំទូលាយក្រោមបរិបទលទ្ធិប្រជាធិបតេយ្យនិងមានតម្លាភាព ដើម្បីសម្រេចបាននូវបំណងប្រាថ្នាធំៗរបស់រដ្ឋ ក៏ដូចជាស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ ឈានទៅកាត់បន្ថយភាពក្រីក្រនិងឆ្ពោះទៅរកវឌ្ឍនភាព។ ក្នុងបរិយាកាសនេះ រាជធានីភ្នំពេញនឹងក្លាយជាទីក្រុងចតុមុខដ៏ទំនើបមួយ ជាប៉ូលអភិវឌ្ឍន៍ស្នូលនៃសេដ្ឋកិច្ចនិងសង្គមកិច្ចដែលមិនអាចខ្វះបានដោយរក្សាបានអត្តសញ្ញាណជាតិរបស់ខ្លួន គុណភាពបរិស្ថាន និងទេសភាពគុណភាព(ស្តង់ដា)អន្តរជាតិ សក្តិសមជាទីក្រុងគជ់មួយនៅអាស៊ីអាគ្នេយ៍។/

ដង់ស៊ីតេប្រជាជនតាមភូមិនៅទីក្រុងភ្នំពេញឆ្នាំ១៩៩៨

Densité de la Population par phum PHNOM PENH 1998



រូបភាពទី១: ដង់ស៊ីតេប្រជាជននៅទីក្រុងភ្នំពេញ (ចំនួនប្រជាជនក្នុង១គីឡូម៉ែត្រក្រឡា)

Densité de la population à Phnom Penh (Nombre d'habitants par Km²)

■	៤០.០០០ -៣១៦.៧០០	40,000 -316,700
■	១៥.០០០ - ៤០.០០០	15,000 - 40,000
■	៣.០០០ - ១៥.០០០	3,000 - 15,000
■	៧.០០ - ៣.០០០	7,00 - 3,000
□	០ - ៧.០០	0 - 7,00

ប្រភព : ជំរឿនជាតិកម្ពុជាឆ្នាំ ១៩៩៨

Source : Recensement National du Cambodge 1998



រូបភាពទី២: ផែនសេវាកម្មនៃរាជធានីភ្នំពេញ



រូបភាពទី៣៖ ដង់ស៊ីតេប្រជាជន (ចំនួនប្រជាជនក្នុង១ គីឡូម៉ែត្រក្រឡា)

Densité de population (Nombre de personnes par Km2)

■	២៣០០០ - ៥៣៤៤០ (ខណ្ឌកណ្តាលក្រុងទាំង៤)	23000 - 53440 (4 khan centraux)
■	៥០០ -៥០០០	500 - 5000
■	៣០០ - ៥០០	300 - 500
■	២០០ - ៣០០	200 - 300
■	១០០ - ២០០	100 - 200
■	៥០ - ១០០	50 - 100
■	១០ - ៥០	10 - 50
□	០ - ១០	0 - 10
□	គ្មានទិន្នន័យ	Sans données

ប្រភព ៖ ជំរឿនជាតិកម្ពុជាឆ្នាំ ១៩៩៨
Source : Recensement National du Cambodge 1998



រូបភាពទី៤: គំនូសបំប្រួញនៃបណ្តាញទំនាក់ទំនងដីគោកនៅឥណ្ឌូចិន
បង្ហាញពីផលិតផលសរុបមហាតំបន់ ឆ្នាំ១៩៩៨
១០ពាន់លានដុល្លារអាមេរិក "រង្វង់ធំ"
១ពាន់លានដុល្លារអាមេរិក "រង្វង់តូច"



រូបភាពទី៥:ក្រាហ្វិកបរិយាយពីសកម្មភាពសេដ្ឋកិច្ចតាមវិស័យនៃប្រទេសកម្ពុជា: កសិកម្ម ការចិញ្ចឹមសត្វ ការនេសាទនិងឈើព្រៃ ឧស្សាហកម្មវាយនភ័ណ្ឌ និងស្បែកជើង ឧស្សាហកម្ម ពាណិជ្ជកម្ម ការដឹកជញ្ជូន សេវាកម្មផ្សេងៗ និងទំនាក់ទំនងផ្សេងទៀត



រូបភាពទី៦: ព្រំប្រទល់នៃការពង្រីកផ្ទៃដីរាជធានីភ្នំពេញជាបន្តបន្ទាប់



រូបភាពទី៧: ផែនទីនៃអ័ក្សអភិវឌ្ឍន៍នៃប្រទេសកម្ពុជា



រូបភាពទី៨: ក្រាហ្វិកនៃទិន្នន័យដឹកជញ្ជូននៅកម្ពុជា



រូបភាពទី៩: ផែនទីនៃប្រព័ន្ធផ្លូវដែកកម្ពុជា

រូបភាពទី១០: ផែនទីចំនួនអ្នកដំណើរនៃព្រលានយន្តហោះធំៗនៅតំបន់អាស៊ីប៉ាស៊ីហ្វិក



រូបភាពទី១១ៈ ផែនទីប្រព័ន្ធផ្លូវថ្នល់នៃរាជធានីភ្នំពេញ



រូបភាពទី១៣: ផែនទីការវិវត្តនៃទន្លេចតុមុខ នៅរាជធានីភ្នំពេញ



រូបភាពទី១២: ផែនទីបណ្ដាញពណ៌និងពណ៌ខៀវនៃរាជធានីភ្នំពេញ

រូបភាពទី១៥: ផែនទីផែនប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៥៩៧,៣១ ហិកតា នៅស្រុកសំបូរ ខេត្តក្រចេះ ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចព្នង ០១ សហគមន៍ និងការផ្តល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បកចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ២២០ ល.ក្រច ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៥ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១: ត្រូវបានកាត់ដីទំហំ **៥៩៧,៣១ ហិកតា** ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិសមូហភាព ជូនសហគមន៍ជនជាតិដើមភាគតិចព្នង ០១សហគមន៍ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង **នៅភូមិពន្ធជា ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងឧបសម្ព័ន្ធ (១) និង (២) នៃអនុក្រឹត្យនេះ ។

មាត្រា ២: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនសហគមន៍ជនជាតិដើមភាគតិចព្នង ចំនួន ១៣២ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិពន្ធជា ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ។

មាត្រា ៣: ផ្តល់សិទ្ធិជាកម្មសិទ្ធិសមូហភាព ជូនសហគមន៍ជនជាតិដើមភាគតិចព្នង ចំនួន ១៣២ គ្រួសារ លើ ៣៥ ក្បាលដី ដែលរួមមាន ដីលំនៅដ្ឋាន ១៤ក្បាលដី ដីកសិកម្មប្រពៃណី ១៤ក្បាលដី ដីកបសព ០១ក្បាលដី និងដីចំការវិលជុំ ០៦ក្បាលដី នៅភូមិពន្ធជា ឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ ។

មាត្រា ៤: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៥: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៩ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*


1441000
1440000
1439000
1438000
1437000
1436000
615000
616000
617000
618000
619000
620000
621000
622000
623000
Projection : UTM
Horizontal Datum : WGS 1984
GPS Model : Leica VIVa
Leica VIVa GS10 CS15

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

សម្រេច

មាត្រា ១.- បំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងផែនការ ចំនួន៨៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិលើវិស័យផែនការកន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសុវត្ថារាថ្នាក់ ធិបឌិន្ទ

១-	លោកស្រី **អន នារី**	អគ្គលេខាធិការរង
២-	លោក **លន់ គឹមលាង**	អគ្គនាយករង
៣-	លោក **មិន ធី**	អនុប្រធាននាយកដ្ឋាន
៤-	លោក **កែម វិបុល**	ប្រធានការិយាល័យ
៥-	លោក **ប៉ុន សុផល**	អនុប្រធាននាយកដ្ឋាន
៦-	លោកស្រី **ស៊ិន ធារី**	អនុប្រធាននាយកដ្ឋាន
៧-	លោក **ប៊ិ ប៊ុន្នា**	ប្រធានមន្ទីរផែនការខេត្តកំពង់ចាម
៨-	លោក **យ៉េម ឆន**	ប្រធានមន្ទីរផែនការខេត្តកំពង់ស្ពឺ
៩-	លោក **ណុប អូ**	អនុប្រធានមន្ទីរផែនការខេត្តព្រះសីហនុ
១០-	លោក **ផុក ទូច**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រះសីហនុ
១១-	លោក **កៅ តា**	អនុប្រធានមន្ទីរផែនការខេត្តកំពត
១២-	លោក **គឹម ច័ន្ទឌីណា**	ប្រធានមន្ទីរផែនការរាជធានីភ្នំពេញ

១៣- លោកស្រី **សោម ចាន់ណា** អនុប្រធានមន្ទីរផែនការខេត្តស្វាយរៀង
១៤- លោក **ខេង ឧត្តី** ប្រធានមន្ទីរផែនការខេត្តរតនគិរី
១៥- លោកស្រី **លឹម សាត** អនុប្រធានមន្ទីរផែនការខេត្តព្រះវិហារ
១៦- លោក **ឡុង ផុន** ប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រះវិហារ

ខ- មេដាយសុវត្ថារា ថ្នាក់ សេនា

១- លោក **ផាច ចេស្តា** អនុប្រធាននាយកដ្ឋាន
២- លោក **នេ ស៊ុន្ថា រិទ្ធី** អនុប្រធាននាយកដ្ឋាន
៣- លោក **ប៉ែន សុជាតិ** អនុប្រធាននាយកដ្ឋាន
៤- លោក **ឃួន ម៉ិនណា** អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រះសីហនុ
៥- លោក **ទូច ឧស្សាហ៍** អនុប្រធានមន្ទីរផែនការខេត្តពោធិ៍សាត់
៦- លោក **ឌុំ រឿន** អនុប្រធានមន្ទីរផែនការខេត្តកំពត
៧- លោក **ស សារឿន** អនុប្រធានមន្ទីរផែនការខេត្តកំពត
៨- លោក **កៅ ម៉ិណ្ណា** អនុប្រធានមន្ទីរផែនការខេត្តកំពត
៩- លោក **ខឹម សុផុន** ប្រធានការិយាល័យ មន្ទីរផែនការខេត្តកំពត
១០- លោកស្រី **ឈឹម ណារិន** ប្រធានការិយាល័យ មន្ទីរផែនការខេត្តកំពត
១១- លោក **លួន សេរី** ប្រធានការិយាល័យ មន្ទីរផែនការខេត្តប៉ៃលិន
១២- លោកស្រី **ស្រី សុគុណា** អនុប្រធានមន្ទីរផែនការខេត្តសៀមរាប
១៣- លោក **គង់ ចាន់ថន** អនុប្រធានមន្ទីរផែនការខេត្តស្វាយរៀង
១៤- លោក **និត នៃ** ប្រធានការិយាល័យ មន្ទីរផែនការខេត្តស្វាយរៀង
១៥- លោក **ម៉ិត ហ៊ិន** អនុប្រធានមន្ទីរផែនការខេត្តកោះកុង
១៦- លោក **អ៊ិត សុឌីឡា** អនុប្រធានមន្ទីរផែនការខេត្តកោះកុង
១៧- លោកស្រី **ស៊ាន សុគីន** ប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រះវិហារ
១៨- លោក **ជា ចន្ថុនា** ប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រះវិហារ

គ-មេដាយសុវត្ថារាថ្នាក់ អស្សឫទ្ធិ

១- លោក **ហ៊ីង សុផល** ប្រធានការិយាល័យ
២- លោក **ហាំ ម៉ូរ៉ា** អនុប្រធានការិយាល័យ
៣- លោក **ឈឹម សុផុន** អនុប្រធានការិយាល័យ
៤- លោក **លឹម ឧត្តរា** ប្រធានការិយាល័យ
៥- លោក **ទ្រី ម៉េងស៊ាង** អនុប្រធាននាយកដ្ឋាន
៦- លោក **ឃួន ស៊ីថាណា** អនុប្រធាននាយកដ្ឋាន
៧- លោក **ជា អេង** អនុប្រធាននាយកដ្ឋាន
៨- លោក **ហង្ស វាសនា** អនុប្រធាននាយកដ្ឋាន
៩- លោក **ឡុង ឡុក** អនុប្រធាននាយកដ្ឋាន
១០- លោក **សេង ចិន្តា** អនុប្រធាននាយកដ្ឋាន
១១- លោកស្រី **សុខ ធាវី** អនុប្រធាននាយកដ្ឋាន

១២-	លោក **សំ កុសល**	អនុប្រធាននាយកដ្ឋាន
១៣-	លោក **អ៊ុន សាវិន**	ប្រធានការិយាល័យ
១៤-	លោក **ជា ទាសនា**	អនុប្រធានការិយាល័យ
១៥-	លោកស្រី **ខុន ច័ន្ទវត្តី**	អនុប្រធានការិយាល័យ
១៦-	លោកស្រី **ម៉ា ស្រីភា**	ប្រធានការិយាល័យ
១៧-	លោក **អ៊ុក ហរិតាល**	អនុប្រធានមន្ទីរផែនការខេត្តពោធិ៍សាត់
១៨-	លោក **ជួន ដារា**	អនុប្រធានមន្ទីរផែនការខេត្តពោធិ៍សាត់
១៩-	លោក **ផន ប៉ុក**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តពោធិ៍សាត់
២០-	លោកស្រី **អ៊ុក បូរីណា**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តពោធិ៍សាត់
២១-	លោកស្រី **សៅ គីមហ៊ី**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តពោធិ៍សាត់
២២-	លោក **កែវ បូរ៉ា**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តពោធិ៍សាត់
២៣-	លោក **ម៉ម សុទ្ធី**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តកំពត
២៤-	លោក **ស្វាយ សំណាង**	អនុប្រធានមន្ទីរផែនការខេត្តកំពង់ឆ្នាំង
២៥-	លោក **ខេន ផល្លី**	អនុប្រធានមន្ទីរផែនការខេត្តកំពង់ឆ្នាំង
២៦-	លោក **ឌិន ឌីឡា**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តកំពង់ឆ្នាំង
២៧-	លោក **សំ សុភាព**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តកំពង់ឆ្នាំង
២៨-	លោក **សយ សារុន**	ប្រធានការិយាល័យ ផែនការស្រុកសាលាក្រៅ
២៩-	លោក **គួ វីណៃ**	អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តប៉ៃលិន
៣០-	លោកស្រី **ឡុច ខ៊ាន់ឌី**	អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តប៉ៃលិន
៣១-	លោកស្រី **វ៉ាច បូថាវី**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តក្រចេះ
៣២-	លោក **ហ៊ឹម គឹមឡេង**	ប្រធានការិយាល័យផែនការក្រុងក្រចេះ
៣៣-	លោក **ប្រាក់ សុខឃី**	អនុប្រធានមន្ទីរផែនការខេត្តសៀមរាប
៣៤-	លោក **ជួប គឹមសាល**	អនុប្រធានមន្ទីរផែនការខេត្តសៀមរាប
៣៥-	លោក **ឯម ស៊ាន**	អនុប្រធានមន្ទីរផែនការខេត្តសៀមរាប
៣៦-	លោក **លី សារឿម**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តសៀមរាប
៣៧-	លោក **ឌិត្យ សារ៉ាត**	អនុប្រធានមន្ទីរផែនការរាជធានីភ្នំពេញ
៣៨-	លោក **រស់ សារី**	អនុប្រធានមន្ទីរផែនការរាជធានីភ្នំពេញ
៣៩-	លោកស្រី **សោម សារឿម**	អនុប្រធានមន្ទីរផែនការខេត្តស្វាយរៀង
៤០-	លោកស្រី **ឈឹម ម៉ុនឆាត**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តស្វាយរៀង
៤១-	លោក **គង់ សាលី**	ប្រធានការិយាល័យផែនការស្រុកចន្ទ្រា
៤២-	លោក **ជា សាផុន**	ប្រធានការិយាល័យ ផែនការស្រុករំដួល
៤៣-	លោក **ម៉ុក សុវណ្ណា**	ប្រធានការិយាល័យផែនការក្រុងស្វាយរៀង
៤៤-	លោក **មាស សារឹម**	ប្រធានការិយាល័យ ផែនការក្រុងបាវិត
៤៥-	លោក **មាស ម៉ិនថាន**	អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តស្វាយរៀង
៤៦-	លោក **ជា ស៊ីវត្រា**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តកោះកុង

៤៧-	លោក **ឡុង ពុទ្ធី**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តកោះកុង
៤៨-	លោក **ឡុង សុខហេង**	ប្រធានការិយាល័យ ផែនការក្រុង
៤៩-	លោកស្រី **ហួន ផាសុភា**	អនុប្រធានមន្ទីរផែនការខេត្តរតនគិរី
៥០-	លោក **ភាន់ ថិទ្ធ**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តរតនគិរី
៥១-	លោក **ខេង សារ៉ាត**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តរតនគិរី
៥២-	លោក **សុខ ហៃ**	ប្រធានការិយាល័យ មន្ទីរផែនការខេត្តរតនគិរី
៥៣-	លោកស្រី **កែវ គន្ធារូន**	អនុប្រធានការិយាល័យ មន្ទីរផែនការខេត្តព្រះវិហារ

មាត្រា២._រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងផែនការ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

មាត្រា ១.- បំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ចំនួន ១០គ្រឿង ប្រគេនព្រះសង្ឃ និងសប្បុរសជនចំនួន ១០រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា នៅវត្តច័ន្ទរស្មី ហៅវត្តច័ន្ទនិមិត្ត ស្ថិតនៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមាសស្ថាបនាជាតិ

- លោកយាយ **ប៉ូច ឆាង** សប្បុរសជន

ខ-មេដាយប្រាក់ស្ថាបនាជាតិ

១- លោក **ហ៊ីង ស៊ុនហេង** សប្បុរសជន

២- លោក **វ៉ង់ វណ្ណា** សប្បុរសជន

៣- លោក **លី យ៉េង** សប្បុរសជន

គ-មេដាយសំរឹទ្ធស្ថាបនាជាតិ

១- លោក **គីម ណារ៉ា** អនុប្រធានភូមិច័ន្ទនិមិត្ត

២- ព្រះតេជគុណ **អេង រដ្ឋា** ចៅអធិការវត្ត

៣- លោក **ជា សុវណ្ណា** បុគ្គលិកក្រុមហ៊ុនចំការកៅស៊ូតាប៉ាវ

៤- លោក **សាន់ សៀម** បុគ្គលិកក្រុមហ៊ុនចំការកៅស៊ូតាប៉ាវ

៥- លោក **ស្នួស ខុន** ប្រធានគណៈកម្មការវត្តច័ន្ទនិមិត្ត

៦- លោក **ហុក យិនណា** អតីតប្រធានគណៈកម្មការវត្តច័ន្ទនិមិត្ត

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីអភិវឌ្ឍន៍ជនបទ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ខែ ធ្នូ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា   ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៤៥៦ អនក្រ.បត

អនុក្រឹត្យ
ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សម្រេច

មាត្រា១._បំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការជានារី នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចំនួន០៨រូប ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចជូនក្រសួង កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

១-លោកស្រី សៀង ទៀង — នាយិកា នៃសាលាមធ្យមវិចិត្រសិល្បៈ

២-លោកស្រី ហ៊ីម ណារ៉ាឡា — ព្រឹទ្ធបុរសរងមហាវិទ្យាល័យសិល្បៈនាដសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១-លោកស្រី ឈុន មុន្នី — ប្រធានការិយាល័យ នៃនាយកដ្ឋានសៀវភៅ និងការអាន

២-លោកស្រី សាន សាវត្ថី — ប្រធានការិយាល័យ នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌

៣-លោកស្រី យ៉ាង ចន — អនុប្រធានការិយាល័យ នៃនាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌

៤-លោកស្រី យឹម ស៊ីណាត — មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

៥-លោកស្រី និត ដាំណែត — មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

៦-លោកស្រី ថោង គឹមចេង — គ្រូបង្ហាត់តូរ្យតន្ត្រី នៃសាលាមធ្យមវិចិត្រសិល្បៈ

មាត្រា២._រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយការងារ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សម្រេច

មាត្រា១. បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការជានារី ចំនួន៧៦រូប នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលមានស្នាដៃល្អនិងស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញភារកិច្ចជូនក្រសួង កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១-លោកស្រី ឈើ្យ យ៉ានី	ប្រធានការិយាល័យនៃអធិការដ្ឋាន
២-លោកស្រី ប៊ូ ឆាព	អនុប្រធានការិយាល័យនៃសាលាបណ្តុះបណ្តាលក្របខ័ណ្ឌវប្បធម៌
៣-លោកស្រី ឡេង សុភា	អនុប្រធានការិយាល័យនៃនាយកដ្ឋានសម្ភារ និងបរិក្ខារ
៤-លោកស្រី សឿង មាន	អនុប្រធានការិយាល័យ នៃនាយកដ្ឋានសៀវភៅនិងការអាន
៥-លោកស្រី ឌិត សារ៉ាវី	អនុប្រធានការិយាល័យនៃនាយកដ្ឋានសារមន្ទីរ
៦-លោកស្រី សំ សត្យា	អនុប្រធានសាលារបាំ នៃសាលាមធ្យមវិចិត្រសិល្បៈ
៧-លោកស្រី អែម សុគន្ធា	អនុប្រធានការិយាល័យសិក្សានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
៨-លោកស្រី សិត សុភី	មន្ត្រីនៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៩-លោកស្រី ជា វណ្ណៈ	មន្ត្រីនៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១០-លោកស្រី អ៊ុក សុខា	មន្ត្រីនៃនាយកដ្ឋានសិល្បៈទស្សនីយភាព
១១-លោកស្រី សុខ លី	គ្រូបង្ហាត់ល្ខោនយីកេ នៃសាលាមធ្យមវិចិត្រសិល្បៈ
១២-លោកស្រី ធុន ស៊ីណា	គ្រូបង្ហាត់ល្ខោននិយាយ នៃសាលាមធ្យមវិចិត្រសិល្បៈ
១៣-លោកស្រី វ៉ា ស៊ីវន	មន្ត្រីនៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១៤-លោកស្រី ដួង សារ៉ន មន្ត្រីមហាវិទ្យាល័យសិល្បៈសូនរូប នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

១៥-លោកស្រី ស្រី ណារិទ្ធ មន្ត្រីមហាវិទ្យាល័យស្ថាបត្យកម្ម នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

ខ-មេដាយប្រាក់ការងារ

១-លោកស្រី ឃុន សាថាល់ ប្រធានការិយាល័យ នៃនាយកដ្ឋានសារមន្ទីរ

២-លោកស្រី ឡឿង និមល អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក

៣-លោកស្រី ចាន់ កល្យាណ អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាលទូទៅ

៤-លោកស្រី គង់ គន្ធារី អនុប្រធានការិយាល័យ នៃនាយកដ្ឋានសារមន្ទីរ

៥-លោកស្រី អៀង សុធារី មន្ត្រី នៃនាយកដ្ឋានសារមន្ទីរ

៦-លោកស្រី មាស សុវណ្ណារ៉ា មន្ត្រី នៃនាយកដ្ឋានសិល្បៈសូនរូប និងសិប្បកម្ម

៧-លោកស្រី រស់ ដាដាណេ មន្ត្រី នៃនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌

៨-លោកស្រី ម៉ូ រីដា មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

៩-លោកស្រី ឈូក ច័ន្ទដារ៉ា មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១០-លោកស្រី យឹម នីម៉ូលីកា មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១១-លោកស្រី ភាអម មាសរក្សអន្តារ៉ា មន្ត្រី នៃនាយកដ្ឋាន សិល្បៈទស្សនីយភាព

១២-លោកស្រី ឈន នីរតនៈ មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១៣-លោកស្រី ស៊ឹម រ៉ារី មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១៤-លោកស្រី អ៊ុង វិស័យនា មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១៥-លោកស្រី ប៊ុក ខាន់ថារី មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១៦-លោកស្រី យិន សេរីភាព មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១៧-លោកស្រី រស់ ណារី មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១៨-លោកស្រី ឡឹក វណ្ណានី មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

១៩-លោកស្រី យិន លៀង មន្ត្រី នៃនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ

២០-លោកស្រី ចាន់ ផល្លា មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព

២១-លោកស្រី ថោង សោភ័ណភាព គ្រូសាលាសិល្បៈសូនរូប នៃសាលាមធ្យមវិចិត្រសិល្បៈ

២២-លោកស្រី ហាក្យ ត្បូងម៉ាឡា គ្រូបង្ហាត់សៀក នៃសាលាមធ្យមវិចិត្រសិល្បៈ

២៣-លោកស្រី ស៊ុំ ស៊ីថា មន្ត្រីមហាវិទ្យាល័យតូរ្យតន្ត្រី នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

គ-មេដាយសំរឹទ្ធការងារ

១-លោកស្រី តូច ស្រីពៅវាសនា ប្រធានការិយាល័យ នៃនាយកដ្ឋាននីតិកម្ម

២-លោកស្រី ស្រី វិចិន្តា អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាលទូទៅ

៣-លោកស្រី ទ្រាំ ច័ន្ទបូផល មន្ត្រី នៃនាយកដ្ឋានបុរាណវិទ្យានិងបុរេប្រវត្តិវិទ្យា

៤-លោកស្រី នុត វណ្ណៈ អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុរាណវត្ថុ

៥-លោកស្រី ទួន សោភា អនុប្រធានការិយាល័យ នៃនាយកដ្ឋានគាំពារ អភិរក្សសំណង់បុរាណ

៦-លោកស្រី ហ៊ឹម សុគន្ធា អនុប្រធានការិយាល័យ នៃនាយកដ្ឋានសារមន្ទីរ

៧-លោកស្រី សំ ពិសី អនុប្រធានសាលារបាំ នៃសាលាមធ្យមវិចិត្រសិល្បៈ

៨-លោកស្រី ម៉ុច សម្បត្តិ គ្រូបង្ហាត់តូរ្យតន្ត្រី នៃសាលាមធ្យមវិចិត្រសិល្បៈ

៩-លោកស្រី អ៊ុយ ថាច គ្រូបង្ហាត់តូរ្យតន្ត្រី នៃសាលាមធ្យមវិចិត្រសិល្បៈ

១០-លោកស្រី ខៀវ សុធាវី	គ្រូបង្ហាត់របាំបុរាណ នៃសាលាមធ្យមវិចិត្រសិល្បៈ
១១-លោកស្រី ហេង្ស សុភាព	គ្រូបង្ហាត់របាំបុរាណ នៃសាលាមធ្យមវិចិត្រសិល្បៈ
១២-លោកស្រី សំ លីមសុធា	គ្រូបង្ហាត់របាំបុរាណ នៃសាលាមធ្យមវិចិត្រសិល្បៈ
១៣-លោកស្រី ទុន សុខា	គ្រូបង្ហាត់សៀក នៃសាលាមធ្យមវិចិត្រសិល្បៈ
១៤-លោកស្រី ពេជ្រ ញឹមជា	មន្ត្រី នៃនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
១៥-លោកស្រី គង់ សេដ្ឋា	មន្ត្រី នៃនាយកដ្ឋានសម្ភារ និងបរិក្ខារ
១៦-លោកស្រី ខួន រីឡា	មន្ត្រី នៃនាយកដ្ឋានសហប្រតិបត្តិការវប្បធម៌អន្តរជាតិ កិច្ចការអាស៊ាន
១៧-លោកស្រី យ៉ង់ សុភាព	មន្ត្រី នៃនាយកដ្ឋានគាំពារអភិរក្សសំណង់បុរាណ
១៨-លោកស្រី ជុំ ចំនួតញ្ញា	មន្ត្រី នៃនាយកដ្ឋានសារមន្ទីរ
១៩-លោកស្រី ភាន នីភា	មន្ត្រី នៃនាយកដ្ឋានសារមន្ទីរ
២០-លោកស្រី សួន អេឡៃន	មន្ត្រី នៃនាយកដ្ឋានសារមន្ទីរ
២១-លោកស្រី ហោ ចំនួលក្សី	មន្ត្រី នៃនាយកដ្ឋានសារមន្ទីរ
២២-លោកស្រី ហេង សុផារ៉ា	មន្ត្រី នៃនាយកដ្ឋានសារមន្ទីរ
២៣-លោកស្រី ស្រី សួស្តី	មន្ត្រី នៃនាយកដ្ឋានសិល្បៈសូនរូប សិប្បកម្ម
២៤-លោកស្រី យឹម ធីតា	មន្ត្រី នៃនាយកដ្ឋានសិល្បៈសូនរូប សិប្បកម្ម
២៥-លោកស្រី ស៊ឹម បូនី	មន្ត្រី នៃនាយកដ្ឋានសៀវភៅ និងការអាន
២៦-លោកស្រី ប៊ុក សារ៉ាម៉ានី	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៧-លោកស្រី ម៉ៅ ញាណសុភារុណ	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៨-លោកស្រី ប្រសិទ្ធ ទិច្ឆិកា	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
២៩-លោកស្រី ពុំ ឆារ៉ាចិន្តា	អនុប្រធានការិយាល័យ នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣០-លោកស្រី រ៉ែន សុវណ្ណបុប្ផា	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣១-លោកស្រី គុន ទីលាត	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣២-លោកស្រី ភុង សុផាត	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣៣-លោកស្រី ឃួន ណារី	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣៤-លោកស្រី ទី រតនា	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣៥-លោកស្រី អ៊ាត ភណរិកា	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣៦-លោកស្រី ប្រសិទ្ធ វីជីវី	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣៧-លោកស្រី តិប ឧងផ្កា	មន្ត្រី នៃនាយកដ្ឋានសិល្បៈទស្សនីយភាព
៣៨-លោកស្រី ស៊ុន ណាចំនួមុនី	មន្ត្រី នៃនាយកដ្ឋានបុរាណវិទ្យា បុរេប្រវត្តិវិទ្យា

មាត្រា២..រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៤៩ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងនាយកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៣៩ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ ស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យ លេខ ៧៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ស្តីពីការកំណត់អត្រាភាគទានសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ម៉ែន សុចិត្រ** តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជានាយកបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល សម្រាប់អាណត្តិ ទី៣ បន្ថែមលើមុខងារបច្ចុប្បន្ន ជំនួសឯកឧត្តម **សំហេង បុរស**។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:១២៤៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ញ៉ែម សារី** ឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៤ ជាអភិបាលរង នៃគណៈអភិបាលខេត្តស្ទឹងត្រែង ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៥០ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោក **សុក ម៉ៃ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ឱ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តព្រះវិហារ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ [illegible] ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៥១..អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង
មន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ឯក **ចាន់ ថ៉ាន់ធឿន** អត្តលេខ ០២១៥៩ ពីអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ទៅជាប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៥២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកវរសេនីយ៍ឯក **ពេជ្រ មុនីរតន៍** អត្តលេខ ៥៥៤១៦ ពីនាយនគរបាលជាន់ខ្ពស់ នាយកដ្ឋានច្រកទ្វារទី២ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ទៅជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

មាត្រា ២ : បទប្បញ្ញត្តទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៤៥៣ អនក.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ស្តីពីការបង្កើតនិងការប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១. បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ១៣រូប ដែលបានជួយឧបត្ថម្ភសម្ភារៈ ថវិកា ជួយកសាងកងពលតូចទ័ពពិសេសឆត្រយោង៩១១ កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

១-លោក	**ឃី**	**យ៉េន**	អភិបាលរងស្រុកមុខកំពូល
២-លោក	**ស៊ុយ**	**សុធី**	អនុប្រធានផ្នែកសេដ្ឋកិច្ចក្រសួងមហាផ្ទៃ

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

១-លោកស្រី	**ឃី**	**សុភា**	ប្រធានក្រុមហ៊ុនសេរីមង្គល
២-លោស្រី	**ឃី**	**រដ្ឋា**	ប្រធានក្រុមហ៊ុនរដ្ឋាគ្រុប
៣-លោក	**ឃី**	**សុធា**	បុគ្គលិកក្រុមហ៊ុនផានអ៊ីម៉ិច
៤-លោក	**ស៊ិន**	**សារឿន**	បុគ្គលិកក្រុមហ៊ុនផានអ៊ីម៉ិច
៥-លោក	**តាំង**	**ប៉េងហុង**	សប្បុរសជន

គ-មេធាវីមុនីសាពាក់ណ្ណ ថ្នាក់ អស្សឫទ្ធិ

១-លោកស្រី **ឡូច** **ហ៊ាង** បុគ្គលិកក្រុមហ៊ុនជានអ៊ីម៉ិច
២-លោកស្រី **ភោគ** **សុផល** បុគ្គលិកក្រុមហ៊ុនជានអ៊ីម៉ិច
៣-លោក **អ៊ឹង** **សុហេង** បុគ្គលិកក្រុមហ៊ុនជានអ៊ីម៉ិច
៤-លោក **ជឿន** **ប៉េងលីម** សប្បុរសជន
៥-លោក **ជី** **ឆេង** សប្បុរសជន
៦-លោក **គីម** **សុវណ្ណា** សប្បុរសជន

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិនិងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៥៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ស្តីពីការបង្កើតនិងការប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១. បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៤រូប ដែលមានស្នាដៃល្អ ក្នុងការចូលរួមជួយឧបត្ថម្ភសម្ភារ ថវិកា ដល់កងពលតូចទ័ពពិសេសឆត្រយោង៩១១ កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

-លោក **សំវ៉ាង ម៉ានភិម៉ុនឆៃ** Somwang Manpimonchai អគ្គនាយកក្រុមហ៊ុនស៊ីម៉ង់ត៍កំពត K.cement

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

១-អ្នកស្រី **ប៉ារ៉ាវី ធុមរ៉ុងស៊ីសគុល** Paravee Tumrongsiskul អគ្គនាយករងក្រុមហ៊ុនស៊ីម៉ង់ត៍កំពត K.cement

២-លោក **ស៊ូប៉ាកិត ភូចារឿនស៊ីល** Supakit Phucharoensilp នាយកផ្នែកផលិតក្រុមហ៊ុនស៊ីម៉ង់ត៍កំពត K.cement

៣-លោក **សាធីត សាតវនិត** Sathit Satvinig នាយកផ្នែករដ្ឋបាលក្រុមហ៊ុនស៊ីម៉ង់ត៍កំពត K.cement

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៥

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៧៣០ សហវ.ក.បក

ប្រកាសរួម

ស្តីពី

ការគ្រប់គ្រងចំណូលពីតំបន់រមណីយដ្ឋានទេសចរណ៍ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់មន្ទីរទេសចរណ៍ខេត្តបាត់ដំបង

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ញាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្ដីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសរួមលេខ ៩៩៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- បានឃើញសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីគោលការណ៍ និងនីតិវិធីផ្ដល់រង្វាន់លើកទឹកចិត្តលើការផ្ដល់សេវាសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ស ម្រេ ច

ប្រការ ១.-

តំបន់រមណីយដ្ឋានទេសចរណ៍ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរទេសចរណ៍ខេត្តបាត់ដំបង រួមមាន÷

១- រមណីយដ្ឋានទេសចរណ៍ ភ្នំសំពៅ

២- រមណីយដ្ឋានទេសចរណ៍ ឯកភ្នំ

៣- រមណីយដ្ឋានទេសចរណ៍ បាណន់

៤- រមណីយដ្ឋានទេសចរណ៍ អាងកំពីងពួយ។

ប្រការ ២.-

ត្រូវបានអនុញ្ញាតឱ្យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង ប្រមូលចំណូលពីតំបន់រមណីយដ្ឋានទេសចរណ៍ ដែលកំណត់នៅក្នុងប្រការ ១ នៃប្រកាសរួមនេះ ទៅតាមការកំណត់ដូចខាងក្រោម ÷

លរ	បរិយាយ	ឯកតាគិត	តម្លៃ (រៀល)			
			រមណីយដ្ឋានទេសចរណ៍ភ្នំសំពៅ	រមណីយដ្ឋានទេសចរណ៍ឯកភ្នំ	រមណីយដ្ឋានទេសចរណ៍បាណន់	រមណីយដ្ឋានទេសចរណ៍អាងកំពីងពួយ
១-	សំបុត្រចូលទស្សនា សម្រាប់ជនបរទេស					
	-អាយុចាប់ពី ១២ឆ្នាំ ឡើង	នាក់/ថ្ងៃ	៤.០០០៛	៤.០០០៛	៨.០០០៛	៤.០០០៛
	-អាយុក្រោម ១២	មិនគិតថ្លៃ				
២-	សំបុត្រសម្រាប់យានយន្តចូលរមណីយដ្ឋាន					
	-រថយន្តចំណុះ ចាប់ពី៧កន្លែងចុះ	គ្រឿង/ថ្ងៃ	៥.០០០៛	៥.០០០៛	៥.០០០៛	៥.០០០៛
	-រថយន្តចំណុះលើសពី ៧កន្លែង ដល់ ១៥កន្លែង	គ្រឿង/ថ្ងៃ	៦.០០០៛	៦.០០០៛	៦.០០០៛	៦.០០០៛
	-រថយន្តចំណុះលើសពី ១៥កន្លែង ដល់ ២៤កន្លែង	គ្រឿង/ថ្ងៃ	១០.០០០៛	១០.០០០៛	១០.០០០៛	១០.០០០៛
	-រថយន្តចំណុះលើសពី ២៤កន្លែង	គ្រឿង/ថ្ងៃ	១៥.០០០៛	១៥.០០០៛	១៥.០០០៛	១៥.០០០៛
	-រថយន្តចំណុះ ក្រោមពីរតោនកន្លះ	គ្រឿង/ថ្ងៃ	៦.០០០៛	៦.០០០៛	៦.០០០៛	៦.០០០៛
	-រថយន្តចំណុះ ចាប់ពីពីរតោនកន្លះ ឡើង	គ្រឿង/ថ្ងៃ	១០.០០០៛	១០.០០០៛	១០.០០០៛	១០.០០០៛
	-ម៉ូតូសណ្តោងរ៉ឺម៉ក / គោយន្ត	គ្រឿង/ថ្ងៃ	២.០០០៛	២.០០០៛	២.០០០៛	២.០០០៛
	-ម៉ូតូ	គ្រឿង/ថ្ងៃ	១.០០០៛	១.០០០៛	១.០០០៛	១.០០០៛
៣-	ការបង់ថ្លៃអនាម័យ និងសណ្តាប់ធ្នាប់សម្រាប់ទីកន្លែងប្រកបមុខរបរផ្សេងៗ					
	-តូបសម្រាប់ជួលអង្គុយកម្សាន្ត	តូប/ឆ្នាំ	១៥០.០០០៛	១៥០.០០០៛	១៥០.០០០៛	១៥០.០០០៛
	-កន្លែងចម្អិន និងលក់ម្ហូបអាហារ	កន្លែង/ឆ្នាំ	១១០.០០០៛	១១០.០០០៛	១១០.០០០៛	១១០.០០០៛
	-តូបលក់ចំណីអាហារ	តូប/ឆ្នាំ	៧៥.០០០៛	៧៥.០០០៛	៧៥.០០០៛	៧៥.០០០៛

ប្រការ ៣.–

រាល់ការប្រកបអាជីវកម្មសណ្ឋាគារ ផ្ទះភ្ញៀវ ភោជនីយដ្ឋាន កីឡាទេសចរណ៍ ក្លឹបកម្សាន្ត ឬប្រភេទអាជីវកម្មទេសចរណ៍ផ្សេងៗទៀត ដែលស្ថិតនៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ដែលកំណត់នៅក្នុងប្រការ ១ នៃប្រកាសរួមនេះ ម្ចាស់អាជីវកម្មត្រូវស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ និងបង់ថ្លៃសេវាសាធារណៈ ទៅតាមការកំណត់នៃប្រកាសរួមលេខ ៩៩៧ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងទេសចរណ៍។

ប្រការ ៤.–

មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(តាមរយៈមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង) សម្រាប់ការប្រមូលចំណូលដែលកំណត់ដោយប្រកាសរួមនេះ។

ប្រការ ៥.–

ប្រាក់ចំណូលដែលប្រមូលបានពីតំបន់រមណីយដ្ឋានទេសចរណ៍ ទៅតាមតម្លៃដែលបានកំណត់នៅក្នុងប្រការ ២ នៃប្រកាសរួមនេះ ត្រូវបានបែងចែកដូចខាងក្រោម ÷

ក. បង់ចូលថវិកាថ្នាក់ជាតិចំនួន ៥% នៃប្រាក់ចំណូលប្រមូលបាន

ខ. ផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ៣០% នៃប្រាក់ចំណូលប្រមូលបាន, ក្នុងនោះ÷

- សាលាខេត្តបាត់ដំបងចំនួន ១៥% នៃប្រាក់ចំណូលប្រមូលបាន
- សាលាក្រុង ឬស្រុកសាមីនៃតំបន់រមណីយដ្ឋានទេសចរណ៍ចំនួន ១០% នៃប្រាក់ចំណូលប្រមូលបាន
- សាលាឃុំ សង្កាត់នៃតំបន់រមណីយដ្ឋានទេសចរណ៍ចំនួន ៥ % នៃប្រាក់ចំណូលប្រមូលបាន

គ. ផ្តល់ជូនមន្ទីរទេសចរណ៍ខេត្តបាត់ដំបងចំនួន ៥៩% នៃប្រាក់ចំណូលប្រមូលបាន, សម្រាប់ការចំណាយដូចខាងក្រោម ÷

- ចំណាយលើការអភិរក្ស និងការអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍ចំនួន ៣០% នៃប្រាក់ចំណូលប្រមូលបាន
- ឧបត្ថម្ភលើកទឹកចិត្តមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូលចំនួន ២៩ % នៃប្រាក់ចំណូលប្រមូលបាន

ឃ. ផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងទេសចរណ៍ ចំនួន ៥% នៃប្រាក់ចំណូលប្រមូលបាន

ង. ផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបងចំនួន ១% នៃប្រាក់ចំណូលប្រមូលបាន។

ប្រការ ៦._

អនុញ្ញាតឱ្យមន្ទីរទេសចរណ៍ខេត្តបាត់ដំបងកាត់ទុកប្រាក់ចំណូលចំនួន៩៥% នៃប្រាក់ចំណូលប្រមូលបាន ដើម្បីចាត់ចែងសម្រាប់ការចំណាយដែលបានកំណត់នៅក្នុងចំណុច ខ, ចំណុច គ, ចំណុច ឃ និងចំណុច ង នៃប្រការ ៥ នៃប្រកាសរួមនេះ។ ការកាត់ទុកប្រាក់ចំណូលនេះ ត្រូវបានចាត់ទុកថាមន្ទីរទេសចរណ៍ខេត្តបាត់ដំបងបានបុរេប្រទានថវិកាពីចំណូលថវិកាជាតិ។

មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ត្រូវរៀបចំឯកសារទូទាត់ការចំណាយលើការប្រើប្រាស់ប្រាក់ចំណូលដែលបានកាត់ទុក ដោយអនុលោមតាមសារាចរណែនាំលេខ ០០១ សហវ.ចមព ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីគោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវាសាធារណៈ។

ប្រការ ៧._

រាល់ការចំណាយលើការអភិរក្ស និងការអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍ ដែលកំណត់នៅក្នុងប្រការ ៥ នៃប្រកាសរួមនេះ ត្រូវមានការឯកភាពជាមុនដោយអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង។ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ត្រូវអនុវត្តការចំណាយលើការអភិរក្ស និងការអភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍ប្រកបដោយតម្លាភាព និងមានគណនេយ្យភាព។

ប្រការ ៨._

មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ត្រូវគ្រោងចំណូល និងចំណាយប្រចាំឆ្នាំ, ទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន, បង់ប្រាក់ចំណូលចូលថវិកាថ្នាក់ជាតិ និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

ប្រការ ៩._

មន្ទីរទេសចរណ៍ខេត្តបាត់ដំបង ត្រូវធ្វើរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ស្តីពីការអនុវត្តចំណូលពីតំបន់រមណីយដ្ឋានទេសចរណ៍ ផ្ញើជូនក្រសួងទេសចរណ៍ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបាត់ដំបង ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ របាយការណ៍ស្តីពីការអនុវត្តចំណូលពីតំបន់រមណីយដ្ឋានទេសចរណ៍ ជាផ្នែកមួយនៃរបាយការណ៍រួមស្តីពីការអនុវត្តចំណូលរបស់មន្ទីរទេសចរណ៍ខេត្តបាត់ដំបង។

ប្រការ ១០._

ការកំណត់តម្លៃប្រមូលចំណូលពីតំបន់រមណីយដ្ឋានទេសចរណ៍ខេត្តបាត់ដំបង អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ប្រការ ១១._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ១២._

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមឱវាទក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៥

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងទេសចរណ៍

ថោង ខុន

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលាខេត្តបាត់ដំបង

«ដើម្បីជូនជ្រាប»

- ដូចប្រការ ១២ «ដើម្បីមុខការ»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៩០ ឧស.ក.ក្រ.កក.០៥

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១៥

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន គ្លូបិល អឺកែរឹល ថិចថាយ (ខេមបូឌា) មេនូហ្វេកធឺរីង ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥។

សម្រេច

ប្រការ១ៈ អនុញ្ញាតឱ្យក្រុមហ៊ុន គ្លូបិល អឺកែរឹល ថិចថាយ(ខេមបូឌា) មេនូហ្វេកធឺរីង ភីធីអ៊ី អិលធីឌី (GLOBAL APPAREL TEXTILE (CAMBODIA) MANUFACTURING PTE., LTD.) តំណាងដោយ លោក WU MING HUNG បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ដីឡូតិ៍លេខ ២២៣ ផ្លូវលេខ៣៧១ ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ គ្លូបិល អីកែរីល ចិចថាយ(ខេមបូឌា) មេនូហ្វេកធើរីង ភីធីអ៊ី អិលធីឌី "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤: ប្រកាសលេខ ១៧២ ឧស.កឱ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន គ្លូបិល អឺគែរីល ថិចថាយ (ខេមបូឌា) មេនូហ្វេកធឺរីង ភីធីអ៊ី អិលធីឌី ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

សាត សាមី

<u>ចម្លងជូន៖</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៩១.....ឧស.ភឧ.ប្រក.១៥

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រផលិតតុក្កតា និងសម្ភារៈប្រើក្នុងពិធីជប់លៀង របស់ក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥។

សម្រេច

ប្រការ១៖ អនុញ្ញាតឲ្យក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) (TAKEOFF (CAMBODIA) CO., LTD.) តំណាងដោយលោក **KIMURA TAKASHI** បង្កើតរោងចក្រ ផលិតតុក្កតា និងសម្ភារៈប្រើក្នុងពិធីជប់លៀង ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (សង្កាត់កន្ទោក សង្កាត់ក្លើងឆេះរទេះ និងសង្កាត់បឹងធំ) ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
១.តុក្កតា	៣២៤០
២.សម្ភារៈប្រើក្នុងពិធីជប់លៀង (ពីក្រណាត់)	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ ៖ "រោងចក្រផលិតតុក្កតា និងសម្ភារៈប្រើក្នុងពិធីជប់លៀង ថេកអហ្ស (ខេមបូឌា)"

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឲ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសលេខ ០៣៧៥ ឧស.កឧ.១២ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្តីពីការបង្កើតរោងចក្រផលិតតុក្កតា និងសម្ភារៈប្រើក្នុងពិធីជប់លៀង របស់ក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

សាត សាមី

ចម្លងជូន៖

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៥៤ ...ឧស.អឧក-ក្រសក.០៩

រាជធានីភ្នំពេញ, ថ្ងៃទី ៤៥ ខែ កញ្ញា ឆ្នាំ២០១៥

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ ជ្រលក់ពណ៌ និងខាត់អំបោះដេរ របស់ក្រុមហ៊ុន ខេភីថល អាយលែន (ខេមបូឌា) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥។

សម្រេច

ប្រការ១៖ អនុញ្ញាតឲ្យក្រុមហ៊ុន ខេភីថល អាយលែន (ខេមបូឌា) (CAPITAL ISLAND (CAMBODIA) CO., LTD.) តំណាងដោយ លោក គុង ចិនហ្វូ បង្កើតរោងចក្រ ជ្រលក់ពណ៌ និងខាត់អំបោះដេរ ដែលមានទីតាំងស្ថិតនៅ ផ្លូវ៣០ម៉ែត្រ ភូមិព្រៃតី.គ សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
អំបោះដេរ	១៣១១

<u>ប្រការ២៖</u> ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ៖ "រោងចក្រជ្រលក់ពណ៌ និងខាអំបោះដេរ ខេភីថល អាយលែន (ខេមបូឌា)"

<u>ប្រការ៣៖</u> ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

<u>ប្រការ៤៖</u> មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

<u>ប្រការ៥៖</u> ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>ប្រការ៦៖</u> ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>ប្រការ៧៖</u> ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឲ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>ប្រការ៨៖</u> ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>ប្រការ៩៖</u> ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

<u>ប្រការ១០៖</u> ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤: ប្រកាសលេខ ៨៥០ ឧរថ.កឧ.ប្រក. ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រជ្រលក់ពណ៌ និងខាអំបោះដេរ របស់ក្រុមហ៊ុន ខេភីថល អាយលែន (ខេមបូឌា) ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

សាត សាមី

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលារាជធានីភ្នំពេញ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ៥៩៥......ឧស.រកភ.ព្រស.ក.ប.៩

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ បោកគក់ ប៉ាក់ និងបោះពុម្ព របស់ក្រុមហ៊ុន យី ដា មេនូហ្វេកធឺរើ ខូ អិលធីឌី ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន យី ដា មេនូហ្វេកធឺរើ ខូ អិលធីឌី (YI DA MANUFACTURER CO., LTD.) តំណាងដោយ លោក **LO CHING LEUNG ANDREW** បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ បោកគក់ ប៉ាក់ និងបោះពុម្ព ដែលមានទីតាំងស្ថិតនៅ ភូមិឬស្សីស្រុក ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
១.សម្លៀកបំពាក់ (កាត់ដេរ)	១៤៣០
២.សម្លៀកបំពាក់ (បោកគក់ និងបោះពុម្ព)	១៣១៣
៣.សម្លៀកបំពាក់ (ប៉ាក់)	១៣៩៩

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការ ដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ ៖"រោងចក្រកាត់ដេរសម្លៀកបំពាក់ បោកគក់ ប៉ាក់ និងបោះពុម្ព យី ដា មេនូហ្វេកធឺរី ខូ អិលធីឌី"

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសលេខ ០០៨៨ ឧស.កឧ.ប្រក.៧ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និង សិប្បកម្ម ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ បោកគក់ ប៉ាក់ និងបោះពុម្ព របស់ក្រុមហ៊ុន យី ដា មេនូហ្វេកធឺរី ខូ អិលធីឌី ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

សាត សាមី

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាខេត្តកណ្តាល
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៥៥៧ ឧស.ក.រ.ភ.ច

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង របស់ក្រុមហ៊ុន ថុង ខាង (ខេមបូឌា) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥។

សម្រេច

ប្រការ១៖ អនុញ្ញាតឲ្យក្រុមហ៊ុន ថុង ខាង (ខេមបូឌា) (TONG KANG (CAMBODIA) CO., LTD.) តំណាងដោយ លោក YAN JINPING បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ដែលមានទីតាំងស្ថិតនៅភូមិធ្លក ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
គ្រឿងបន្សំស្បែកជើង	១៥២០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ ៖ " រោងចក្រផលិតគ្រឿងបន្សំស្បែកជើង ថុង ខាង (ខេមបូឌា)"

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឲ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

ប្រការ១៥៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

សាត សាមី

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាខេត្តកំពង់ស្ពឺ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៤៩៨៤ ឧស.ក.ន.ព្រក.០៩

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន អេសអ៊ីភីអាយអេ (ខេមបូឌា) ហ្គាមេន ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥។

សម្រេច

ប្រការ១៖ អនុញ្ញាតឲ្យក្រុមហ៊ុន អេសអ៊ីភីអាយអេ (ខេមបូឌា) ហ្គាមេន (SEPIA (CAMBODIA) GARMENT Co., Ltd.) តំណាងដោយ លោកស្រី XU GENXIAN បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ផ្លូវលំ ភូមិចាក់ជ្រូក សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
សម្លៀកបំពាក់	១៤១០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ផ្លាកឈ្មោះរោងចក្រ ៖ " រោងចក្រកាត់ដេរសម្លៀកបំពាក់ អេសអ៊ីភីអាយអេ (ខេមបូឌា) ហ្គាមេន"

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឲ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឲ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១១៖ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការ ជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១២៖ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

ប្រការ១៣៖ ម្ចាស់រោងចក្រ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹង វិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ប្រការ១៤៖ ប្រកាសលេខ ១៥៦ ឧស.ក.ឧ.ប្រក. ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងឧស្សាហកម្ម និង សិប្បកម្ម ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន អេសអ៊ីកីអាយអេ (ខេមបូឌា) ហ្គាមេន ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១៥៖ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

ប្រការ១៦៖ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

សាត សាមី

ចម្លងជូន៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៥ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ភ្នំពេញថ្ងៃទី ២១ **ខែ**មេសា **ឆ្នាំ** ២០១៥

លេខ ០៦៦៧ **ពណ.ចបព រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រោមអត្តលេខ Co. ០១៣០KH/២០១៥ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ២០១៥ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈ ច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ ដោយយោងសេចក្តីប្រកាសរបស់ក្រុមហ៊ុនដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **កែវ ពន្លឺ ខូ អិលធីឌី**
KEO PUNLOEU Co., Ltd.
មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន : លោក **កែវ ពន្លឺ**
៣- ដើមទុនក្រុមហ៊ុន : ៤០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៣ វិថីព្រះមុនីវង្ស សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។
៥- កម្មវត្ថុអាជីវកម្ម : -អាជីវកម្មទទួលបញ្ចាំនិងទិញ លក់ ទ្រព្យបញ្ចាំ-អាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
-ពាណិជ្ជកម្មៈ ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សម្ភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសម្ភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
- ប្តូរប្រាក់ កែច្នៃ ទិញ លក់ គ្រឿងអលង្ការ
- មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
- បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
- សេវាផ្នែកព័ត៌មានវិទ្យា
-សេវាផ្សាយពាណិជ្ជកម្ម
- បោះពុម្ពផ្សាយ
- ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូនៈ ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកម្រៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុលអគារ ស្ពាន ថ្នល់ ស្ថាបត្យកម្ម រចនាប្លង់ ត្រួតពិនិត្យ និងសិក្សាគម្រោងប្លង់សំណង់គ្រប់ប្រភេទ ។

-ទេសចរណ៍: សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកម្សាន្ត

-វិនិយោគលើវិស័យកសិកម្ម: ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម: រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ឡុយ សុផានី

ចម្លងជូន:

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសុខាភិបាល
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងព័ត៌មាន
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- អគ្គនាយកដ្ឋានពន្ធដារ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ក.ស.ន - ឯកសារ - កាលប្បវត្តិ